ការណែនាំឆ្ពោះទៅរក (GUIDE TO)

សេវាសុខភាពផ្លូវចិត្ត (Medi-Cal Mental Health Services)

ប្រសិនបើអ្នកមានអាសន្ន សូមហៅលេខ ៩-១-១ ឬ ទៅមន្ទីពេទ្យជិតអ្នកនៅបន្ទប់មានអាសន្ន។បើអ្នកចង់បានដំណឹងថែមឲ្យជួយអ្នកសំរេចចិត្តក្នុងរឿងអាសន្ននេះ សូមមើលដំណឹងទូទៅនៃរដ្ឋកាលីហ្វូនីទំព័រលេខ៦នៃសៀវភៅនេះ

តើខ្ញុំទទួលតារាងសេវាផ្លូវចិត្តតាមរបៀបណា :

អ្នកអាចសួររកមន្ទីសុខភាពគំរោងផ្លូវចិត្ត(Mental Health Plan) (MHP)គេនឹងផ្តល់តារាងណែនាំដល់បុគ្គលទាំងឡាយ គ្លីនីកនឹងមន្ទីពេទ្យទាំងឡាយដែលអ្នកអាចទទួលសេវាខាងផ្លូវចិត្តក្នុងដំបន់អ្នករស់នៅទាំងនេះហៅថា" តារាងជួយផ្តល់(provider list)មានរាយឈ្មោះលេខទូរស័ព្ទវេជ្ជបណ្ឌិតនឹងអស័យដ្ឋានវេជ្ជបណ្ឌិត ឯកទេសព្យាបាលផ្លូវចិត្ត ពេទ្យនឹងទីឯទៀតអាចជួយអ្នក។ប្រហែល ជាអ្នកត្រូវទាក់ទងនឹង MHP របស់អ្នកជាមុន មុនឲ្យគេជួយ អាចហៅMHP របស់អ្នកលេខខាងលើបាន២៤ម៉ោង អត់អស់លុយ ហើយសួរថាតើអ្នកត្រូវទាក់ទង MHP មុនទៅរកការិយាល័យសេវាផ្តល់ជូនគ្លីនីកនឹងមន្ទីពេទ្យទាំងឡាយ ឲ្យជួយអ្នក។

Disponible en Español

មានភាសាអ្វីដទៃខ្លះទៀត នឹងមានទំរង់បែបបទយ៉ាងណា

Este folleto (o información) esta disponible en Español. Usted puede solicitarlo llamando al número de teléfono gratuito mencionado anteriormente.

Có bản tiếng Việt của tập sách (hoặc tài liệu) này. Quý vị có thể gọi số điện thoại miễn phí ở trên để xin bản tiếng Việt.

本小冊子（或資訊）有繁體中文版，
請致電以上免費專線查詢。

Phau ntawv no (los sis cov lus no) muaj ua lus Hmoob. Koj nug tau cov no uas hu tus xov tooj hu dawb saum toj no.

يتوفر هذا الكتيب(او هذه المعلومات) باللغة العربية. و يمكنك طلب نسخة بواسطة الإتصال برقم الهاتف المجاني المبين أعلاه.

Դուք կարող եք ստանալ այս գրքույկը (կամ տեղեկությունը) հայերեն լեզվով՝ զանգահարելով վերը նշված անվճար հեռախոսահամարով:

កូនសៀវភៅ(រពត៌មាន)នេះ អាចមានជាភាសាខ្មែរ។ អ្នកអាចសុំវាដោយគ្រាន់តែ ទូរស័ព្ទទៅកាន់លេខដែលឥតគិតថ្លៃដូចបានរាយខាងលើ។

Данная брошюра также доступна на русском языке. Вы можете попросить предоставить ее вам, позвонив по бесплатному номеру телефона, указанному выше.

TAng buklet (o impormasyon) ay makukuha sa Tagalog. Maaari mo itong hilingin sa pamamagitan ng pagtawag sa walang bayad na telepono na nakalista sa itaas.

این دفترچه (یا اطلاعات) بزبان فارسی موجود است. شما میتوانید از طریق شماره تلفن رایگان درج شده در فوق آنرا درخواست کنید.

본 책자(또는 정보)는 한국어로 이용이 가능하며, 위에 수록된 무료전화번호로 연락하여 요청하실 수 있습니다.

ការណែនាំដល់ Medi-Cal

សេវាសុខភាពផ្លូវចិត្ត

ហេតុអ្វីបានជាគេឲ្យខ្ញុំ កូនសៀវភៅតូចនេះ ហើយហេតុអ្វីបានជាសំខាន់ម្លេះ?

អ្នកទទួលសៀវភៅតូចនេះ ពីព្រោះអ្នកទទួលបាននូវ Medi-Cal ហើយជាចាំបាច់អ្នកត្រូវការ ដឹងពីសេវាផ្លូវចិត្ត ដែលទីក្រុងឡូសអង់ជីលេស ផ្តល់ឲ្យអ្នក ហើយអាចទទួលបាន សេវានេះ ពេលអ្នកត្រូវការ។

បើពេលនេះអ្នកកំពុងទទួលសេវាពីក្រុង ឡូសអង់ជីលេស សៀវភៅតូចនេះ គ្រាន់តែប្រាប់អ្នកពីរបៀបធ្វើការ។
សៀវភៅតូចនេះប្រាប់ពីសេវាផ្លូវចិត្ត ប៉ុន្តែមិនប្តូរនូវសេវាដែលអ្នកកំពុង បានទទួលទេ។អ្នកទុកសៀវភៅតូចនេះសំរាប់មើលទៀត។

*បើអ្នកមានការមិនយល់ ពីកូនសៀវភៅនេះ សូមទាក់ទងនឹង **MHP** លេខ **(800) 854-7771** ដើម្បីជួយដោះស្រាយពី ផ្លូវឯទៀតឲ្យអ្នកបានទទួលពត៏មានពិសេសនេះ*

បើពេលនេះអ្នកមិនទាន់បានទទួលសេវាទេ អ្នកទុកសៀវភៅតូចនេះសំរាប់អ្នក ឬសំរាប់អ្នកណាម្នាក់ដែលអ្នកស្គាល់ ដែលត្រូវការចង់ដឹងពី សេវាសុខភាពផ្លូវចិត្ត ទៅថ្ងៃមុខ។

អ្វីទៅហៅថាការអាសន្ននៃសុភាពផ្លូវចិត្ត?

មានអាសន្ន នៅពេលមានជំងឺផ្លូវចិត្តខ្លាំង ឬវិបត្តិផ្លូវអារម្មណ៏ដូចជា:
កាលណាបុគ្គលម្នាក់ធ្វើឲ្យអន្តរាយដល់ខ្លួនគាត់ ដល់ខ្លួននាង ឬដល់អ្នកដ៏ ទៃទៀត ដោយហេតុពីមានជំងឺផ្លូវចិត្ត ឬបុគ្គលនោះមិនអាចទៅរក ឬប្រើអាហារ ទីជំរក សំលៀកបំពាក់ ដែលគេត្រូវការដោយសារ ប្រហែលមានជំងឺផ្លូវចិត្ត។

ពេលមានអាសន្នសូមទាក់ទង 9-1-1 ឬនាំបុគ្គលនោះទៅបន្ទប់មានអាសន្ននៅមន្ទីពេទ្យ។

តើខ្ញុំប្រើសៀវភៅតូចនេះរបៀបណា?

សៀវភៅតូចនេះជួយឲ្យអ្នកយល់ពី អ្វីទៅដែលមុខការសំខាន់របស់សេវាសុខភាពខាង ផ្លូវចិត្តទាំងឡាយ ហើយអ្នកអាចទទួល នឹងពីរបៀបដែលទីក្រុងឡូសអង់ជីលេស MHP អាចជួយអ្នកបាន។

សៀវភៅតូចនេះមានចែកជាពីរវគ្គ។ វគ្គទីមួយប្រាប់អ្នកពី របៀបដែលទីក្រុង ឡូសអង់ជីលេស MHP អាចជួយអ្នកបាន នឹងរបៀបដែលធ្វើការ។

វគ្គទីពីរ គឺពីរដ្ឋកាលីហ្វ័រញ៉ា ហើយដែលផ្តល់ដំណឹងជាទូទៅ ពីសេវាសំខាន់ពីសុខភាពផ្លូវចិត្ត។ ប្រាប់របៀបអ្នកត្រូវទទួលសេវា ពីរបៀបដោះស្រាយបញ្ហា នឹងសិទ្ធិអ្នកក្រោមកម្មវិធី។

សៀវភៅតូចនេះប្រាប់ពីរបៀបយកពត៏មានទាំងឡាយពីវេជ្ជបណ្ឌិត គ្លីនីគ នឹង មន្ទីពេទ្យ ដែលទីក្រុងឡូសអង់ជីលេស MHPប្រើដើម្បីផ្តល់សេវាដល់ទីដែល អ្នករស់នៅ។

តើគំរោងសុខភាពផ្លូវចិត្ត(MHP)?នៅដំបន់ស្រុកខ្ញុំមានយ៉ាងណា?

សេវាសុខភាពផ្លូវចិត្តធ្វើជូនដល់អ្នកមានទទួល Medi-Cal រាប់ទាំងក្មេងតូច ជនវ័យក្មេង ជនពេញវ័យ នឹង ជនចាស់ៗ ក្នុងទីស្រុកឡូសអង់ជីលេស។

ពេលខ្លះសេវានេះមានផ្តល់ឲ្យពីដុកទ័រធម្មតារបស់អ្នក។ពេលខ្លះផ្តល់ចេញពីអ្នកឯកទេសហៅថាសេវា"ពិសេស" របស់សុខភាពផ្លូវចិត្ត។ សេវាពិសេសបានផ្តល់ឲ្យតាមរយៈស្រុកឡូសអង់ជីលេស" សុខភាពផ្លូវចិត្ត " ឬ MHPដែលមិនទាក់ទាមនឹងដុកទ័រធម្មតារបស់អ្នក។ ស្រុកឡូសអង់ជីលេស MHPធ្វើការក្រោមច្បាប់រដ្ឋកាលីហ្វ័រញ៉ា នឹងច្បាប់រដ្ឋសហរដ្ឋ។ ស្រុកនិមួយៗក្នុង រដ្ឋកាលីហ្វ័រញ៉ាមាន MHP ផ្ទាល់ខ្លួន។

> បើសិនអ្នកមានអារម្មណ៏ថាអ្នកមានជំងឺ វិបត្តិផ្លូវចិត្តអ្នកអាចទាក់ទងនឹងស្រុកឡូសអង់ជីលេស MHP ផ្ទាល់លេខ **(800) 854-7771**. នេះជាលេខអត់ត្រូវអស់លុយ។ នេះជាលេខ អត់ត្រូវអស់លុយមានបំរើ 24 ម៉ោង១ថ្ងៃជាលាយល័ក្ខណ៏ ហើយបកស្រាយប្រាប់ពីសិទ្ធិអ្នក កំរៃ នឹងការព្យាបាលមានភាសារដែលអ្នកពេញចិត្ត។មិនបាច់ទៅរកដុកទ័រធម្មតាបស់អ្នជាមុនទេ។

បើអ្នកជឿថាមានលក្ខណៈទទួលសេវាសុខភាពផ្លូវចិត្តបាន ហើយអាចទទួល Medi-Calស្រុកឡូសអង់ជីលេសMHPនឹងជួយថាតើអ្នកត្រូវបានទទួលសេវានឹងការព្យាបាល សុខភាពផ្លូវចិត្តបាន ។បើចង់បានពត៌មានសេវាប្រាកដណាមួយ សូមមើលត្រង់វគ្គ" សេវា" នៅសៀវភៅតូចនេះ ត្រង់រដ្ឋកាលីហ្វ័រញ៉ា ទំព័រ 9

*អ្នកអាចស្នើសុំសវនាកាពីរដ្ឋ(**State Fair Hearing.**)សូមមើលទំព័រ **26** នៃរដ្ឋ កាលីហ្វ័រញ៉ាវគ្គសៀវភៅនេះជាដំណឹង។*

ឲ្យខ្ញុំធ្វើយ៉ាងម៉េចបើមានបញ្ហារកគេជួយមិនបាន?

បើមានបញ្ហារកគេជួយមិនបានសូមទូរស័ព្ទរកស្រុកឡូសអង់ជីលេស MHP ផ្ទាល់លេខ **(800) 854-7771** អត់ត្រូវអស់លុយមានបំរើ 24 ម៉ោង។ អ្នកអាចទាក់ទងអ្នកជួយគាំទ្រដល់អ្នកជំងឺក្នុងស្រុកលេខ **(800) 700-9996.**

បើនៅដោះបញ្ហារអ្នកមិនបានទៀតអ្នកអាចទូរស័ព្ទដល់រដ្ឋកាលីហ្វ័រញ៉ា អ្នកចាំជួយ

(Ombudsman)លេខ :

(800) 896-4042 - CA Only(កាលីហ្វ័រញ៉ាប៉ុណ្ណោះ)

(916) 654-3890
(800) 896-2512 TTY
FAX: (916) 653-9194
EMail: ombudsmn@dmhhq.state.ca.us

Medi-Cal សេវាសុខភាពផ្លូវចិត្ត

តារាងអត្ថាធិប្បាយ

ស្រុកឡូសអង់ជីលេស

ស្រុកឡូស អង់ជីលេស

ស្វាគមន៍ដល់គំរោងការណ៍ស្រុកឡូសអង់ជីលេស 1

ពត៌មានសំខាន់ពេលមានអាសន្ន

លេខទូរស័ព្ទសំខាន់ៗ 2

តើមានអ្វីដែលជាសញ្ញា ឲ្យខ្ញុំដឹងថា ជននោះត្រូវការជួយ? 2

តើស្រុកឡូអង់ជីលេស មានសេវាពិសេសអ្វីសំរាប់ផ្ដល់សុខភាពផ្លូវចិត្ត ? 2

ស្រុកឡូអង់ជីលេសគំរោងសេវាសុខភាពផ្លូវចិត្ត / ពត៌មាន

តើខ្ញុំទទួលសេវាបានដោយរបៀបណា? 3

តើមានន័យយ៉ាងណាពាក្យ " ចេញអនុញ្ញាត" ទើបទទួលសេវាសុខភាពបាន ហើយតើមានចំនួនពេល រយៈកាល និងឲ្យដឹងពីសេវាសុខភាព ? 3

តើធ្វើរបៀបណាឲ្យបានពត៌មានថែម ពីដុកទ័រ ដុកទ័រផ្នែកឯកទេស គ្លីនិក និងមន្ទីពេទ្យ? 4

មានភាសារអ្វីខ្លះ និងមានរបៀបយ៉ាងណាដែលមាននោះ ? 4

តើខ្ញុំអាចទៅរកដុកទ័រណាក៏បានដែរ ដុកទ័រផ្នែកឯកទេស គ្លីនិក និងមន្ទីពេទ្យ? ដែលមាននៅក្នុងតារាង ឈ្មោះមន្ទីផ្ដល់ឲ្យ ? 4

យ៉ាងម៉េចដែរបើខ្ញុំចង់ប្ដូរដុកទ័រ ដុកទ័រផ្នែកឯកទេសឬ គ្លីនិក ? 4

ឲ្យខ្ញុំធ្វើរបៀបណាទើបបាន "តារាងឈ្មោះមន្ទីផ្ដល់ឲ្យ " 4

តើខ្ញុំអាចប្រើ "តារាងឈ្មោះមន្ទីផ្ដល់ឲ្យ " ដើម្បីរកអ្នកជួយខ្ញុំបានទេ? 4

យ៉ាងម៉េចដែរបើខ្ញុំចង់ប្ដូរដុកទ័រ ដុកទ័រផ្នែកឯកទេស គ្លីនិក ឬពេទ្យគ្មានឈ្មោះ ក្នុង ស្រុកឡូអង់ជីលេសលើ "តារាងឈ្មោះមន្ទីផ្ដល់ឲ្យ ?" 5

ចុះបើខ្ញុំត្រូវការជាបន្ទាន់នូវសេវាសុខភាពផ្លូវចិត្តនៅចុងសប្ដាហ៍ ឬយប់ ? 5

ឲ្យខ្ញុំធ្វើរបៀបណាទើបបានទទួលនូវសេវាសុខភាពផ្លូវចិត្តដែលមន្ទីសុខភាពផ្លូវចិត្តរបស់ខ្ញុំគ្មានបានផ្ដល់ឲ្យនោះ ? 5

ឲ្យខ្ញុំធ្វើរបៀបណា បើខ្ញុំទៅរកដុកទ័រមើលជំងឺ ក្រៅពីជំងឺផ្លូវចិត្ត ព្យាបាលសុខភាព? 5

ឲ្យខ្ញុំធ្វើរបៀបណា បើខ្ញុំមិនពេញចិត្តនឹង ដែលមន្ទីសុខភាពផ្លូវ ចិត្តរបស់ខ្ញុំ ? 6

តើអ្វីដែលជាសេវាជំនួយ (Beneficiary Service)? គេធ្វើការអ្វី ទាក់ទងពួកគេយ៉ាងម៉េច? 6

តើស្រុកឡូអង់ជីលេសដាក់ទុកឯកសារសុខភាពផ្លូវចិត្តរបស់ខ្ញុំជាសំងាត់ទេ? 6

រដ្ឋកាលីហ្វ័រញ៉ា

រដ្ឋកាលី ហ្វ័រញ៉ា

ពត៌មានទូទៅក្នុងរដ្ឋ

ហេតុអ្វីបានជាចាំបាច់ត្រូវអានកូនសៀវភៅនេះ? 1

គំរោងសុខភាពផ្លូវចិត្តក្នុងតំបន់

តើអ្វីជាសេវាសុខភាពផ្លូវចិត្តឯកទេស(Special Mental Health Services)? 2

តើខ្ញុំអាចទទួលសេវាសុខភាពផ្លូវចិត្តនៅឯណា? 2

តើខ្ញុំអាចទទួលសេវាផ្សេងៗនៅឯគំរោងសុខភាពផ្លូវចិត្តនៃតំបន់របស់ខ្ញុំ ដោយរបៀបណា? 2

Medi-Cal សេវាសុខភាពផ្លូវចិត្ត

រដ្ឋកាលីហ្វ័រញ៉ា (ត)

ពត៌មានសំខាន់ពី Medi-Cal

តើអ្នកណាអាចទទួល **Medi-Cal**បាន**?** 4
តើខ្ញុំត្រូវតែបង់ថ្លៃឲ្យអោយ Medi-Cal ដែររឺទេ? 4
តើខ្ញុំអាចទទួលសេវាផ្សេងៗរបស់ **Medi-Cal** ដែលមិនត្រូវបាននារនារ៉ាប់រងដោយគំរោងសុខភាពផ្លូវចិត្ត **(Mental Health Plan)**ដែររឺទេ? 5
តើអ្វីជាកម្មវិធីការពារភាពពិការនិងសុខភាពរបស់កុមារ [Child Health And Disability Prevention(CHDP) Program] 7

ពត៌មានបន្ទាន់ជាមូលដ្ឋាន

អ្នកកំពុងមានភាពអាសន្ន? 8
តើសេវាដែលទាក់ទិននឹងភាពអាសន្នប្រភេទណាដែលត្រូវបានផ្តល់អោយ? 9
តើទំនួលខុសត្រូវសំរាប់ការថែទាំក្រោយពេលដែលធ្វើអោយមានភាពនឹងនរបស់**MHP** តំបន់របស់ខ្ញុំចប់ ? 10

សេវាផ្សេងៗ

(ជនពេញវ័យនឹងជនពេញវ័យចំណាស់)

តើខ្ញុំដឹងថាពេលណាត្រូវការជំនួយដោយរបៀបណា? 12
តើអ្វីខ្លះជាសញ្ញាថាខ្ញុំប្រហែលជាត្រូវការជំនួយរឺទេ ? 12
តើសេវាអ្វីខ្លះដែលមាន ? 13

(កុមារ កំលោះក្រមុំ និងមនុស្សក្មេងវ័យ)

តើខ្ញុំដឹងថានៅពេលណាកុមារត្រូវការជំនួយដោយរបៀបណា ? 17
តើខ្ញុំដឹងថាពេលណាដែលកំលោះក្រមុំរឺមនុស្សវ័យក្មេងត្រូវការជំនួយរបៀបណា ? 18
តើសេវាអ្វីដែលអាចមាន? 19
តើមានសេវាពិសេសសំរាប់កុមារ កំលោះក្រមុំ និងមនុស្សពេញវ័យដែលមានវ័យក្មេងដែររឺទេ? 19
តើអ្វីជាសេវាចំពោះអាកប្បកិរិយាដែលត្រូវការព្យាបាល(TBS)(Therapeutic Behavioral Services ? 20
តើនរណាអាចទទួល **TBS**? 21
តើមានអ្វីដែលត្រូវតែកើតឡើងចំពោះខ្ញុំដើម្បីទទួល **TBS**ដែររឺទេ? 21
តើខ្ញុំអាចទទួល **TBS**ដោយរបៀបណា**?** 22
តើនរណាជាអ្នកសំរេច ប្រសិនបើខ្ញុំត្រូវការ **TBS** ហើយតើកន្លែងណាដែលខ្ញុំអាចទទួលពួកគេ? 22
តើអ្វីគួរតែស្ថិតក្នុងគំរោង **TBS**របស់ខ្ញុំ **?** 22

លក្ខណះ ' ចាំផ្តែកវេជ្ជសាស្ត្រ '

តើអ្វីជា **"**ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ " ហើយហេតុអ្វីបានជាវាសំខាន់? 23

រដ្ឋកាលីហ្វ័រញ៉ា (ត)

"ភាពចាំច់ផ្នែកវេជ្ជសាស្ត្រ" ដើមទទួលការរ៉ាប់រងលើសេវា សុខភាពផ្លូវចិត្ត ឯកទេសលើកលែងតែសេវាមន្ទីរពេទ្យ? 23
តើអ្វីជាលក្ខណៈសម្បត្តិផ្នែកវេជ្ជសាស្រ(MedicalNecessity)ដើម្បីទទួលការរ៉ាប់រងលើសេវាសុខភាពផ្លូវចិត្តឯកទេសសំរាប់ជនដែលមានអាយុក្រោម21 ឆ្នាំ? 25

សេចក្តីជូនដំណឹង ពីវិធានការណ៍ ?

តើអ្វីជាសេចក្តីជូនដំណឹងពីវិធានការណ៍(Notice Of Action)? 27
តើនៅពេលណាដែលខ្ញុំទទួលសេចក្តីជូនដំណឹងពីវិធានការណ៍? 27
តើខ្ញុំតែងតែទទួលនូវសេចក្តីជូនដំណឹងពីវិធានការណ៍នៅពេលដែលខ្ញុំមិនបានទទួលសេវាដែលខ្ញុំចង់បាន? 28
តើអ្វីដែលសេចក្តីជូនដំណឹងពីវិធានការណ៍នឹងប្រាប់ខ្ញុំ? 28
តើអ្វីដែលខ្ញុំគួរតែធ្វើនៅពេលដែលខ្ញុំទទួលបាននូវសេចក្តីជូនដំណឹងពីវិធានការណ៍? 29

ដំណើរការ ដោះស្រាយ ជំលោះ

តើយ៉ាងដូចម្តេច បើខ្ញុំមិនទទួលសេវាដែលខ្ញុំចង់បានពី MHP នៃតំបន់របស់ខ្ញុំ? 30
តើខ្ញុំអាចទទួលជំនួយក្នុងការប្តឹងឧទរណ៍សាទុក រឺរដ្ឋសាវនាការយុត្តិធម៌ដែររឺទេ? 30
តើយ៉ាងដូចម្តេច បើសិនបើខ្ញុំត្រូវការជំនួយក្នុងការដោះស្រាយបញ្ហាមួយជាមួយនឹង **MHP**បុន្តែមិនចង់ធ្វើការបណ្តឹងសាទុក រឺទ្ធរណ៍? 31

ដំណើរការនៃឧទ្ធរណ៍ត្(ស្តង់ដានិងពន្លឿន)

តើអ្វីជាឧទ្ធរណ៍តាមក៏រិតស្តង់ដា? 32
តើនៅពេលណាដែលខ្ញុំអាចដាក់ពាក្យប្តឹងឧទ្ធរណ៍? 33
តើខ្ញុំអាចប្តឹងឧទ្ធរណ៍ដោយរបៀបណា? 34
តីខ្ញុំដឹងថាតើឧទ្ធរណ៍របស់ត្រូវបានសំរេចដោយរបៀបណា? 34
តើមានកាលបរិច្ឆេទឯទដើម្បីដាក់បណ្តឹងឧទ្ធរណ៍ដែររឺទេ? 34
តើនៅពេលណាដែលសេចក្តីសំរេចចិត្តមួយត្រូវបានធ្វើឡើងអំពីការប្តឹងឧទ្ធរណ៍របស់ខ្ញុំ? 34
តើដូចម្តេច ប្រើសិនបើខ្ញុំមិនអាចរង់ចាំរយៈពេល **45** ថ្ងៃ ដើម្បីទទួលការសំរេចចិត្តនៃឧទ្ធរណ៍ របស់ខ្ញុំ ? 34
តើអ្វីជាឧទ្ធរណ៍ដែលមានការពន្លឿន? 35
តើនៅពេលណាដែលខ្ញុំអាចដាក់ពាក្យប្តឹង ឧទ្ធរណ៍ដែលមានការពន្លឿន? 35
ដំណើរការផ្សេងៗនៃរដ្ឋសាវនាការយុត្តិធម៌((ស្តង់ដា និងពន្លឿន)
តើអ្វី ជារដ្ឋសាវនាការយុត្តិធម៌? 36
តើអ្វីជាសិទ្ធិសាវនាការយុត្តិធម៌របស់ខ្ញុំ? 36
តើនៅពេលណាខ្ញុំអាចដាក់ពាក្យសុំរដិសាវនាការយុត្តិធម៌របស់ខ្ញុំ? 36

រដ្ឋកាលីហ្វ័រញ៉ា (ត)

តើខ្ញុំស្នើសុំសវនាការយុត្តិធម៌មួយដោយរបៀបណា? 37
តើមានកាលបរិច្ឆេទផុតកំណត់សំរាប់ការដាក់ពាក្យឧស្សុំរដ្ឋសាវនាការដែរឬទេ? 37
តើខ្ញុំអាចបន្តសេវាទាំងឡាយនៅពេលដែលខ្ញុំកំពុងរង់ចាំការសំរេចិត្តរដ្ឋសាវនាការយុតឌីធម៌ដែរឬទេ? 37
តើអ្វីដែលខ្ញុំត្រូវធ្វើបើសិនបើខ្ញុំចង់បន្តសេវាទាំងឡាយ នៅពេលដែលកំពុងរង់ចាំការសំរេចចិត្តនៃរដ្ឋសាវនាការយុត្តិធម៌? 38
តើដូចម្តេច ប្រសិនបើខ្ញុំរង់ចាំរយះពេល 90ថ្ងៃ ដើម្បីទទួលការសំរេចចិត្តលើរដ្ឋសាវនាការយុត្តិធម៌? 38

ដំណើរការសាទុក្ខ

តើអ្វីជាសាទុក្ខ? 39
តើនៅពេលណាខ្ញុំអាចដាក់ពាក្យប្តឹងសាទុក្ខ? 39
តើខ្ញុំអាចដាក់ពាក្យបណ្តឹងសាទុក្ខដោយរបៀបណា? 39

សិទ្ធិរបស់លោកអ្នក

តើមានសិទ្ធិអ្វីខ្លះ? 41

សេចក្តីបង្គាប់ជាមុន

អ្វីទៅជាសេចក្តីបង្គាប់ជាមុន? 44

សមត្ថភាពវប្បធម៌

ហេតុអ្វីបានជាគិតគូរផ្នែកវប្បធម៌និងការប្រើប្រាស់ភាសា មានសារះសំខាន់? 45

របៀបដែលលោកអ្នកអាចទទួល)បានសេវា

តើខ្ញុំត្រូវទទួលសេវាសុខភាពឯកទេសផ្លូវចិត្តដោយរបៀបណា? 47
តើត្រូវស្វែងរកអ្នកផ្តល់សេវាសុភាពឯកទេសផ្លូវចិត្តដែលខ្ញុំត្រូវការ តាមរបៀបណា? 47
នៅពេលខ្ញុំរកបានអ្នកផ្តល់សេវា តើMHP អាចប្រាប់អ្នកផ្តល់សេវានោះអំពីសេវាដែលខ្ញុំត្រូវការបាន រឺទេ? 48
តើ MHP របស់ខ្ញុំប្រើអ្នកផ្តល់សេវាណាខ្លះ? 49

ស្វាគមន៍មកដល់ស្រុកឡូសអង់ជីលេស
គាំពារការសុខភាពផ្លូវចិត្ត

យើងសូមស្វាគមន៍អ្នក ពីស្រុកឡូសអង់ជីលេសអំពី សេវាសុខភាពផ្លូវចិត្ត នឹង ពី Medi-Cal គាំពារ សេវាសុខភាពផ្លូវចិត្ត

ក្រសួងសុខភាពផ្លូវចិត្តមានចិត្តរីករាយបំរើប្រជាជននៃស្រុកឡូសអង់ជីលេស តាមរយៈប្រព័ន្ធ នៃគ្លីនិកទាំងឡាយសេវាតាមគេហដ្ឋាន ពេទ្យ នឹងតាមរយៈ កន្លែងឯទៀតដែលដឹកនាំឡើងដោយស្រុក នឹងភ្នាក់ងារដែលមានចុះកុងត្រា។ យើងបំរើជូនដោយគុណភាពខ្ពស់ល្អ ដោយប្រឹតប្រៀន ថែទាំដោយមិនមាន របៀបតឹងរឹងដែលកំរឹតដោយសង្គមជិតខាងរបស់អ្នក។ នេះមានន័យថា យើងធ្វើការទទួលខុសត្រូវអស់ពីចិត្តដើម្បីប្រើប្រាស់ប្រាក់ជំនួយសាធារណៈ ដើម្បីសមតម្រូវការផ្នែកសុខភាពនៃស្រុក ស្រុកឡូសអង់ជីលេស ។សូម អានកូនសៀវភៅតូចនេះដោយហ្មត់ចត់ដែលមានពត៌មានសំខាន់ៗសំរាប់ឲ្យអ្នកដឹង។

ក្នុងឋានៈជាគាំពារសេវាសុខភាពផ្លូវចិត្តរបស់អ្នក យើងនឹង :

- ចាំឆ្លើយចម្លើយអ្នកពីការព្យាបាលសុខភាពផ្លូវចិត្ត
- ប្រាប់អ្នកតើគាំពារសេវាសុខភាពអ្វីខ្លះដែល Medi-Cal ចេញថ្លៃឲ្យ
- ពិនិត្យមើលតើគាំពារសេវាសុខភាពអ្វីខ្លះដែលអ្នកត្រូវការ ហើយជួយអ្នកទទួលឲ្យបាន
- ព្យាបាលអ្នកដោយក្តីគោរព
- មើលឲ្យប្រាកដថា អ្នកទទួលសេវាដោយបរិយាកាសសុខសាន្ត
- ជួយអ្នកព្យាបាលឲ្យតម្រូវសមនឹងវប្បធម៌

ក្នុងឋានៈជាអ្នកចូលរួម អ្នកមានការទទួលខុសត្រូវពិសែសដែរ :

- ផ្តល់ដំណឹងដោយស្មោះនឹងឲ្យអស់ពីតម្រូវការសុខភាពផ្លូវចិត្តរបស់អ្នក
- ចូលរួមដោយសកម្មក្នុងការព្យាបាលសុខភាពផ្លូវចិត្តរបស់អ្នក
- មកកុំឲ្យខានក្នុងការធ្វើការណាត់ជួបជាមុន
- ទូរស័ព្ទមកមុន បើមិនអាចមកតាមការណាត់ជួប
- ប្រឹងថែខ្លួនតាមគោលដៅរបស់ទីផ្តល់គាំពារការសុខភាពរបស់អ្នក

លេខទូរស័ព្ទសំខាន់ៗ

មានអាសន្ន	911
ចិត្ត មន្ទីសុខភាពផ្លូវ មជ្ឈមណ្ឌលទាក់ទង សេវាជំនួយកំរ៉ៃ(Beneficiary Services)	(800) 854-7771 (562) 651-2549 *(TDD/TTY)* (213) 738-4949
ការិយាល័យសិទ្ធអ្នកជំងឺ	(800) 700-9996
នាយក ពត៌មានឯកជន (Chief Information Privacy Officer)	(213) 974-2164

ធ្វើយ៉ាងណាទើបខ្ញុំដឹងថាគេត្រូវការឲ្យជួយ?
សូម្បីតែមិនមានអាសន្ន ជនដែលមានបញ្ហាសុខភាពផ្លូវចិត្ត ត្រូវការឲ្យគេជួយភ្លាមៗ បើសិនណាមានរឿងមួយ ឬទាំងរឿងនេះមានកើតពិត

- ឮសំលេង ឬ ឃើញអ្វីមួយដែលអ្នកដ៏ ទៃជឿថា មិនមែនទេ
- គឹតខ្លាំង គឹតជាញយៗដល់រឿងស្លាប់ ឬនិយាយពីរឿងស្លាប់
- ចែកឲ្យរបស់របរទៅឲ្យគេ
- គំរាមសំលាប់ខ្លួនគេ (សំលាប់ខ្លួនឯង)
- ចង់ធ្វើមានរបួសដល់ខ្លួនគេឬអ្នកដ៏ ទៃ

បើមានឃើញហេតុមួយឬទាំងនេះកើតឡើង ហៅ 911 ឬ ស្រុកឡូសអង់ជីលេស MHP លេខ (800) 854-7771 (24-ម៉ោង អត់អស់លុយ) អ្នកធ្វើការសុខភាពផ្លូវចិត្ត ចាំទទួលទូរស័ព្ទ 24-ម៉ោងមួយថ្ងៃ។

*សេវាឯទៀតដែលពេលខ្លះគេត្រូវការ មានមានរួមបញ្ចូលលើទំព័រទី **9** (ជនពេញវ័យ) ទំព័រ **12** (ក្មេងៗ) នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាក្នុងវគ្គនេះ*

ស្រុកឡូសអង់ជីលេសមានឯកទេសពិសេសអ្វីខ្លះជូនផ្នែកសេវាសុខភាពផ្លូវចិត្ត?
សេវាសុខភាពផ្លូវចិត្ត មានបំរើដល់អ្នក :

- **សេវាក្នុងមន្ទីពេទ្យរោគផ្លូវចិត្ត(Psychiatric Inpatient Hospital Services)** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្ត
- **សេវារោគផ្លូវចិត្ត(Psychiatry Services)** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្តពីសំណាក់គំពោងការសុខភាព ដែលមានលីសង់ព្យាបាលផ្លូវចិត្ត / ដុកទ័រជំនាញផ្លូវចិត្ត
- **សេវាចិត្តវិជ្ជា (Psychology Services)** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្តពីដែលមានលីសង់ព្យាបាលផ្លូវចិត្តពីសំណាក់គំពោងការសុខភាពដែលជំនាញស្ទង់មើលខាងចិត្តវិជ្ជាហើយព្យាបាលរោគផ្លូវចិត្ត
- **ចំណុចកែរណីការចាត់ចែង** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្តនឹងសកម្មភាពជួយប្រជាជនឲ្យបានលត្ថភាពទទួលសេវាសហគមន៍ ដើម្បីជួយ / ឬ ឲ្យមានការជួយខ្លួនឯងឲ្យមានឯករជ្យនៃផ្លូវជីវិតជីវិត ។
- **សេវាឲ្យមានការរស់នៅប្រសើរបាន** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្តជួយប្រជាជនឲ្យចំរើន រក្សា នឹងមានការរស់នៅប្រសើរឡើងក្នុងសហគមន៍ ។
- **មន្ទីព្យាបាលសេវារោគផ្លូវចិត្ត** – ជំនាញការខាងសេវាសុខភាពផ្លូវចិត្ត ក្នុងការរៀបចំដោយមានលីសង់ ដូចជាមន្ទីជំនាញពេទ្យ។

សេវាទាំងឡាយដូចមានខាងលើនេះ ជាសេវានៃស្រុក ឡូសអង់ជីលេស MHP គឺតថាជួយប្រជាជនច្រើន ដែលត្រូវការសេវាសុខភាពផ្លូវចិត្ត។ពេលខ្លះមានសេវាដ៏ ទៃទៀតដែលគេអាចត្រូវការ។ សេវាដ៏ ទៃទៀតដែលមានដែលពេលខ្លះគេត្រូវការ មានរួមនៅក្នុង តារាងលើទំព័រលេខ 9 (ពេញវ័យ) នឹងទី 12 (ក្មេងៗ) នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា នៅក្នុងវគ្គនៃសៀវភៅនេះ។

ធ្វើរបៀបណាទើបខ្ញុំបានទទួលសេវាទាំងនេះ ? ទូរស័ព្ទរកស្រុក ឡូសអង់ជីលេស MHP លេខសំរាប់ទាក់ទង់ (800) 854-7771 ។ បន្ទាប់មកគេនឹងណែនាំអ្នកដល់គំរោងការសុខភាពនឹងធ្វើការណាត់ជួបឲ្យអ្នក ដើម្បីសេវា TDD/ TTY សូមទូរស័ព្ទ (562) 651-2549.

តើមានន័យយ៉ាងណា "គេបានចេញអនុញ្ញាត" បានទទួលសេវាសុខភាពផ្លូវចិត្តហើយចំនួនពេលនឹងការប៉ាន់មើលនៃគំរោងការសុខភាព?

រូបអ្នក គំរោងការសុខភាពរបស់អ្នក នឹងស្រុក ឡូសអង់ជីលេស MHPចូលរួមសំរេចចិត្តថាតើសេវាណាមួយដែលអ្នកត្រូវទទួលតាមរយៈ MHPរួមទាំងញាប់ញយយ៉ាងណាដែលអ្នករត្រូវការសេវា ហើយយូរប៉ុន្មាន។

ស្រុក ឡូសអង់ជីលេស MHP អាចតម្រូវឲ្យទីគំរោងការសុខភាពរបស់អ្នក សួរ MHPសើរើហេតុផលថាហេតុអី ទីគំរោងការសុខភាពរបស់អ្នកគឺតថាអ្នកត្រូវកាសេមុននឹងគេធ្វើការជូវឲ្យ។ ស្រុក ឡូសអង់ជីលេស MHPប្រើអ្នកមានសមត្ថភាពខាង សុខភាពផ្លូវចិត្តអាជីព ធ្វើការសើរើមើល។ ធ្វើការសើរើមើល គឺហៅថា របៀប មានអំណាចចេញបង់លុយឲ្យ។ រដ្ឋតម្រូវឲ្យ ស្រុក ឡូសអង់ជីលេស MHP មានអំណាចឲ្យម្ចានការព្យាបាលជម្ងឺពេលថ្ងៃ មើលឲ្យជាស្បើយពេលថ្ងៃ នឹងសេវាព្យាបាលសុខភាពផ្លូវអារម្មណ៍ (TBS).

ឡូសអង់ជីលេស MHP ធ្វើតាមច្បាប់ រដ្ឋ ដើម្បីឲ្យ MHPមានរបៀបមានអំណាចចេញបង់លុយឲ្យ ដែលរៀបរាប់នៅលើទំព័រទី 3 នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ក្នុងវគ្គនៃសៀវភៅនេះ។ បើអ្នកចង់បានដំណឹងថែមពីរបៀបដែល ឡូសអង់ជីលេសMHP ធ្វើ MHPមានអំណាចចេញបង់លុយឲ្យ ឬកាលណាដែលយើងតម្រូវឲ្យទីគំរោងការសុខភាពរបស់អ្នកសួរ MHPពីMHP ពីMHPមានអំណាចចេញបង់លុយឲ្យសេវា សូមទាក់ទងនឹងស្រុក ឡូសអង់ជីលេស MHP នៅលេខ **(213) 738-4949**

ធ្វើរបៀបណាឲ្យខ្ញុំយកពត៌មានថែមពីស្រុក ឡូសអង់ជីលេស សេវាសុខភាពផ្លូវចិត្ត រួមទាំងដុកទ័រ ឯកទេសផ្លូវចិត្ត គ្លីនីក នឹងពេទ្យទាំងឡាយ?

ដើម្បីរកតារាងឈ្មោះ គំរោងការសុខភាព នឹងពត៌មានឯទៀតនឹងពត៌មានថែមទៀតនៅលើរបៀបធ្វើការរបស់ស្រុក ឡូសអង់ជីលេស MHP ទាក់ទងសេវាជំនួយកំរ៉ៃនៅលេខ (213) 738-4949 ឬបើកវ៉េបសៃ DMH website: www.dmh.co.la.ca.us.

អ្នកក៏អាចដើរចូលទៅយកពត៌មាននៅឯក្រសួងសុខភាពផ្លូវចិត្ត Department of Mental Health (550 S. Vermont Ave., Los Angeles, CA 90020).អ្នកជួយគាំទ្រអ្នកជំងឺ នឹងចាំជួបអ្នកដើម្បីជួយឆ្លើយសំណួរទាំងឡាយរបស់អ្នក។

មានភាសាអ្វីដទៃខ្លះទៀត នឹងមានទំរង់បែបបទយ៉ាងណា ?

ស្រុក ឡូសអង់ជីលេស MHP ផ្តល់ជាសម្ភារៈ ក្នុងបាន10 ភាសារ ។ អ្នកអាចទូរស័ព្ទទីដែលអ្នកមានលទ្ធភាពប្រើបានលេខ **(800) 854-7771** ហើយ/ឬ ទីសិទ្ធិអ្នកជំងឺលេខ**(800) 700-9996** (ចំពោះតារាងឈ្មោះទីគំរោងការសុខភាព ដែលតម្រូវតាមភាសាររបស់គាត់/នាង) អ្នកជំងឺក៏អាចបើកបានវ៉េបសៃ(MHP website: **www.dmh.co.la.ca.us**). ស្រុក ឡូស

អង់ជីលេស MHP ផ្តល់ជាពត៌មានចំពោះអ្នកមានចក្ខែក ឬ ត្រចៀកពិការ(ឧ. ជាអក្សរធំៗឬជាកាសែតសំលេង) ហើយប្រើរបៀបបច្ចេកទេសរដ្ឋកាលីហ្វ័រញ៉ាជំនួយ(California Relay system and sign)ដើម្បីបកប្រែជួយមនុស្សថ្លង់ឬត្រចៀកធ្ងន់។ទាក់ទងនឹងការិយាល័យសិទ្ធិអ្នកជំងឺ លេខ**(800) 700-9996** ឬ **(213) 738-4888** ឬ បីរបៀបបច្ចេកទេសរដ្ឋកាលីហ្វ័រញ៉ាជំនួយ លេខ**(800) 735-2929**.

តើខ្ញុំអាចទៅរកដុកទ័រ ឯកទេសព្យបាល គ្លីនីក ឬ ពេទ្យណាក៏បានដែលនៅលើតារាង"គំរោងការសុខភាព" នៃស្រុក ឡូសអង់ជីលេស ?

បើជាអ្នកមានសិទ្ធិជ្រើសរើសយកគំរោងការសុខភាពរបស់អ្នកបាន ។ បើគំរោងការសុខភាពដែលអ្នកបានជ្រើសមិននៅក្រោមស្រុក ឡូសអង់ជីលេស MHP ស្រុកឡូសអង់ជីលេស MHP អត់មានអំណាចអ្វីលើសេវាទាំងឡាយដែលបានផ្តល់ចេញពីគំរោងការសុខភាព ណាមួយពីតប្រាកដនោះទេ។ហើយគំរោងការសុខភាពខ្លះៗក៏មិនទទួលយក Medi-Cal ជាអ្នកអ្នកចេញលុយឲ្យទេ មុននឹងបានទទួលសេវា។បើអ្នកជ្រើសយកសេវាដែលមិនចេញឲ្យដោយ Medi-Cal នោះអត់មានការជំទាស់ក្នុងបែបសេវាដែលអ្នកទទួលនោះទេ។

បើអ្នកមានសំណួរសូមទូរស័ព្ទទីអ្នកមានលទ្ធភាពប្រើបាន(ACCESS) 24ម៉ោង១ថ្ងៃ លេខ **(800) 854-7771** សេវាជំនួយកំរ៉ៃ(Beneficiary Services) **(213) 738-4949.**

តើយ៉ាងម៉េចដែរបើខ្ញុំចង់ដូរ ដុកទ័រ ឯកទេសព្យាបាល ឬគ្លីនិក?

អ្នកអាចនិយាយផ្ទាល់នឹងទី គំរោងការសុខភាពរបស់អ្នកស្នើរសុំប្តូរដុកទ័រ ។ បើគេមិនធ្វើតាមការស្នើររបស់អ្នកឬ សេវាជំនួយកំរ៉ៃ គឺតថាគេត្រូវការជំនួយទៅមុខទៀត អ្នកអាច ទាក់ទងទីសិទ្ធិអ្នកជំងឺដើម្បី ជួយឆ្លើយសំណួរទាំងឡាយរបស់អ្នក។

តើធ្វើយ៉ាងម៉េចទើបខ្ញុំយកបានក្រដាសចំឡងតារាង "គំរោងការសុខភាព " ?

ហៅទី សេវាជំនួយកំរ៉ៃ(Beneficiary Services) **(213) 738-4949** ឬទៅយកនៅមន្ទីការសុខភាពផ្លូវចិត្ត (550 S. Vermont Ave., Los Angeles, CA 0020).

តើខ្ញុំអាចប្រើទី "តារាង គំរោងការសុខភាព " ?ដើម្បីរកអ្នកឲ្យជួយខ្ញុំ?

ទីជំនួយកំរ៉ៃ(Beneficiary)អាចស្នើរសុំទីដែលគេចូលចិត្ត ដើម្បីទៅឲ្យទី គំរោងការសុខភាពពីបុគ្គលិកទីមានលទ្ធភាពប្រើបានឬក៏ទីបុគ្គលិកទីការិយាល័យសិទ្ធិអ្នកជំងឺ។ អ្នកអាចរកបានទៀតនៅទី គំរោងការសុខភាពនៅក្នុងតំបន់ដែលអ្នករស់នៅដែលអ្នកមានលទ្ធភាពប្រើបាននៅស្រុកឡូសអង់ជីលេស MHP វ៉ែបសៃ។

តើខ្ញុំអាចទៅរកដុកទ័រ ឯកទេសព្យបាល គ្លីនីក ឬ ពេទ្យណាដែលមិនមាន នៅលើតារាង"គំរោងការសុខភាព"នៃស្រុក ឡូសអង់ជីលេស ?

បើជាអ្នកមានសិទ្ធិជ្រើសរើសយកគំរោងការសុខភាពរបស់អ្នកបាន ។ បើគំរោងការសុខភាពដែលអ្នកបានជ្រើសមិននៅក្រោមស្រុក ឡូសអង់ជីលេស MHP ស្រុកឡូសអង់ជីលេស MHP អត់មានអំណាចអ្វីលើសេវាទាំងឡាយដែលបានផ្តល់ចេញពីគំរោងការសុខភាព ណាមួយពីតប្រាកដនោះទេ។ហើយគំរោងការសុខភាពខ្លះៗក៏មិនទទួលយក Medi-Cal ជាអ្នកអ្នកចេញលុយឲ្យទេ មុននឹងបានទទួលសេវា។បើអ្នកជ្រើសយកសេវាដែលមិនចេញឲ្យដោយ Medi-Cal នោះអត់មានការជំទាស់ក្នុងបែបសេវាដែលអ្នកទទួលនោះទេ។

បើអ្នកមានសំណួរសូមទូរស័ព្ទទីអ្នកមានលទ្ធភាពប្រើបាន(ACCESS) 24ម៉ោង១ថ្ងៃ លេខ **(800) 854-7771** សេវាជំនួយកំរ៉ៃ(Beneficiary Services) **(213) 738-4949.**

តើយ៉ាងម៉េចដែរបើខ្ញុំត្រូវការសេវាសុខភាពផ្លូវចិត្តជាបន្ទាន់ នៅចុងសប្តាហ៍ ឬ នៅពេលយប់ ?

សូមទាក់ទងលេខ 911 ឬ ទីអ្នកមានលទ្ធភាពប្រើបាន(ACCESS) **(800) 854-7771** ឬទៅទីបន្ទប់ពេទ្យទទួលមើលជាបន្ទាន់ឬបន្ទប់អាសន្ន។

ឬអ្នកអាចទាក់ទងនឹងមន្ទីចាត់ចែងការខាងក្រោម24 ម៉ោង១ថ្ងៃ ប្រាំពីរថ្ងៃ មួយអាទិត្យ។

ការពារមិនឲ្យសំលាប់ខ្លួននឹង

ដើម្បីរស់ នៅលេខ(Survivor Hotline).......... **(877) 727-4747** (ក្នុងស្រុក LA)

.... **(310) 391-1253** (ក្រៅស្រុក LA)

សង្គមវង្វេងវង្វន់(Alzheimer)លេខជួយ .... **(800) 660-1993**

វិបត្តិយុវវ័យរដ្ឋកាលីហ្វ័រញ៉ា លេខផ្ទាល់ .... **(800) 843-5200**

ធ្វើបាបក្មេង(Child Abuse) លេខផ្ទាល់................ **(800) 540-4000**

ឈ្លោះប្រកែកនៅផ្ទះ –

រំលោភដោយផ្លូវកាម លេខផ្ទាល់ .... **(800) 339-3940**

ធ្វើបាបមនុស្សចាស់ លេខផ្ទាល់ .... **(800) 992-1660**

រោគអេដស៍(National HIV/AIDS) លេខផ្ទាល់ **(800) 342-2437**

គ្រឿងញៀនស្រវឹង លេខផ្ទាល់.................. **(800) 564-6600** *(9 a.m. - 5 p.m.*
(ថ្ងៃចន្ទ - ថ្ងៃសុក្រ)

ធ្វើរបៀបណាឲ្យខ្ញុំយក សេវាសុខភាពផ្លូវចិត្ត ដែល គំរោងសេវាសុខភាព ផ្លូវចិត្តរបស់ខ្ញុំ មិនមានធ្វើជូនឲ្យ?

បើ គំរោងការសុខភាពមិនជ្រើសរើសសេវាសុខភាពផ្លូវចិត្តដែលអ្នករតូវការ អ្នកអាចសួរ គំរោងការសុខភាពរបស់អ្នកដើម្បីរកទីដែលគួរទុកចិត្តបាន។អ្នកអាចហៅទីអ្នកមាន លទ្ធភាពប្រើបាន(ACCESS)ដើម្បីរកទីសេវាសុខភាពផ្លូវចិត្តដែលគួរទុកចិត្តលេខ**(800) 854-7771.**

តើយ៉ាងម៉េចដែរបើខ្ញុំត្រូវការទៅរកដុកទ័រមើលជម្ងឺមួយដែលមិនទាក់ទងនឹង ការពយាបាលសុខភាពផ្លូវចិត្ត? របៀបណាដែលគេប្រើបាននូវ សេវា Medi-Cal ក្រៅពីមន្ទីសុខភាពផ្លូវចិត្ត ស្រុក ឡូសអង់ជីលេស ?

បើអ្នកត្រូវការរកដុកទ័រឲ្យព្យាបាលរោគអ្វីមួយក្រៅពីការពយាបាលនៃសុខបាលផ្លូវចិត្ត អ្នកអាចសួរ គំរោងការសុខភាពរបស់អ្នកដើម្បីរកទីដែលគួរទុកចិត្តបាន។ អ្នកអាចសួរមន្ទីគំរោងការសុខភាព ធម្មតារបស់អ្នកនូវពត៌មានបន្ថែមទៀត។ យើងសូមឲ្យអ្នកបើកមើលតាមទំព័រលឿងនៃសៀវភៅទូរស័ព្ទស្រុកអ្នក ដើម្បីរកដុកទ័រនៅជិតអ្នករស់នៅ

តើឲ្យខ្ញុំធ្វើយ៉ាងម៉េច បើខ្ញុំមានបញ្ហារ ឬមិនពេញចិត្តនឹងការព្យាបាលរបស់ មន្ទីសុខភាពផ្លូវចិតរបស់ខ្ញុំ?

បើអ្នកមានបញ្ហារ ឬមិនពេញចិត្តនឹងការព្យាបាលរបស់ សេវាសុខភាពផ្លូវចិត្ត។ MHP ចង់ដោះស្រាយ រឿងនេះឲ្យបានងាយឆាប់។សូមទាក់ទង MHPលេខ**(800) 854-7771** ដើម្បីរកផ្លូវដោះស្រាយរឿងទាក់ទងអ្នក។

មានរបៀបពយ៉ាងដើម្បីធ្វើការជាមួយ MHP ដើម្បីដោះរសាយរឿងអ្នកពីសេវា ឬបញ្ហាដ៏ទៃ។ អ្នកអាចដាក់ពាក្យតវ៉ា ដោយសំដីឬដោយលាយលក្ខណ៍ជាមួយនឹងMH អំពីMHណាដែលមានទាក់ទាមនឹងបញ្ហារនេះ។ អ្នកអាចដាក់ពាក្យតវ៉ា ដោយសំដីហើយ(ដោយលាយលក្ខណ៍ តាម

ក្រោយ)។ ឬដោយលាយល័ណ្ឌជាមួយនឹងMH ហើយអ្នកអាចដាក់ពាក្យសុំធ្វើសវនាការតាមក្រសួងសេវាសង្គម(Department of Social Services.)

ដើម្បីយកពត៌មានថែមអំពី MHP ធ្វើរបៀបតវ៉ា វិនិច្ឆ័យជាថ្មីនឹងរបៀបធ្វើការរបស់រដ្ឋលើសវនាការ។ សូមបើកមើលត្រង់វគ្គ អំពី ដាក់ពាក្យតវ៉ា សវនាការរដ្ឋលីទំព័រ 22 រដ្ឋ កាលីហ្វ័រញ៉ា នៃវគ្គកូនសៀវភៅ។

ជាដំណឹងបន្ថែមលើការតវ៉ា វិនិច្ឆ័យជាថ្មី នឹងសវនាការរដ្ឋ សូមបើកត្រង់អំពី ’បញ្ហារការដោះស្រាយ របៀបធ្វើ ’ **(Problem Resolution Processes’)***ក្នុងរដ្ឋកាលីហ្វ័រញ៉ា ទំព័រ* **22** *ក្នុងកូនសៀវភៅ*

បញ្ហារអ្នកនឹងដោះស្រាយដោយឆាប់នឹងងាយបំផុត។នឹងរក្សាទុកជាការសំងាត់។
គេមិនប្រកាន់
ឬ ពិន័យ ដោយសារអ្នកដាក់ពាក្យបឹដងតវ៉ា ឬសវនាការរដ្ឋ។ អ្នកអាចអនុញ្ញាតិឲ្យជនម្នាក់ទៀតជាតំណាងអ្នកក្នុងការតវ៉ា វិនិច្ឆ័យជាថ្មីនឹងរបៀបធ្វើការរបស់រដ្ឋលើសវនាការ។

អ្វីទៅដែលហៅថាសេវាជំនួយកំរ៉ែ(Beneficiary Services)?មានមុខងារយ៉ាងម៉េចខ្លះ? ធ្វើរបៀបណាឲ្យខ្ញុំទាក់ទងនឹងបុគ្គលិកបាន?
សេវាជំនួយកំរ៉ៃ(Beneficiary Services) ជាភាគមួយនៃការិយាល័យ សិទ្ធិអ្នកជំម្ងឺបុគ្គលិកនៃសេវាជំនួយកំរ៉ៃ(Beneficiary Services)អាចជួយអ្នកជាមួយសេវាសុខភាពផ្លូវចិត្ត ដោយ ផ្តល់ដំណឹង នឹងទីដែលទុកចិត្តបានជំនួយជាមួយការ ជួយដោះស្រាយបញ្ហារ ហើយស៊ើបការពីការតវ៉ា នឹង ការស្នើឲ្យវិនិច្ឆ័យជាថ្មីទាំងឡាយ។

បុគ្គលិកសេវាជំនួយអ្នកជំងឺ(Patient Beneficiary)ទាក់ទងនៅលេខ :
(213) 738-4949 សំរាប់ការតវ៉ាមិនមែនពេទ្យ/ស៊ុំវិនិច្ឆ័យឡើងវិញ
(213) 738-4888 សំរាប់ការតវ៉ា ពេទ្យ/ស៊ុំវិនិច្ឆ័យឡើងវិញ

តើស្រុកឡូសអង់ជីលេសរក្សាទុកនូវសំណុំរឿងសុខភាពរបស់ខ្ញុំជាកាសម្ងាត់ទេ?
ពិតប្រាកដហើយសំណុំរឿងសុខភាពរបស់អ្នកគេរក្សាទុកជាការសម្ងាត់ ការពារដោយច្បាប់ប្រទេស។យើងជាអ្នកបង្កើតឲ្យមានសុខភាពនេះនឹងសេវាអ្នកទទួល។
យើងត្រូវការទុកសំណុំដើម្បីជួយអ្នករកមន្ទីពយាបាលមានគុណភាពល្អ តម្រូវនឹងច្បាប់។
បើត្រូវការ កាលណាដល់ពេល យើងនឹងផ្តល់ចេញនូវសំណុំរឿងអ្នកដើម្បីឲ្យត្រូវការព្យាបាលជំងឺអ្នក។

ព័ត៌មានទូទៅទូទាំងរដ្ឋ

ហេតុអ្វីបានជាចាំបាច់ត្រូវអានកូនសៀវភៅនេះ?

ផ្នែកទីមួយនៃកូនសៀវភៅនេះ ប្រាប់អ្នកពីរបៀបក្នុងការទទួលសេវាសុខភាពផ្លូវចិត្ត របស Medi-Cal តាមរយៈគំរោងសុខភាពផ្លូវចិត្ត (Mental Health Plan) នៃតំបន់របស់ អ្នក។ ផ្នែកទីពីរនៃសៀវភៅនេះ ប្រាប់អ្នកបន្ថែមទៀត ថាតើកម្មវិធីរបស់ Medi-Cal មានដំណើរការទៅដោយរបៀបណា និងថាតើសេវាសុខភាពឯកទេសរបស់ Medi-Cal មានដំណើរការទៅនៅក្នុងតំបន់ទាំងអស់របស់រដ្ឋមួយដោយរបៀបណា។

ប្រសិនបើអ្នកមិនអានផ្នែកនេះក្នុងពេលឥឡូវទេ អ្នកអាចរក្សាទុកសៀវភៅណែនាំនេះ ដើម្បីអោយអ្នកអាចអានវាបាននៅពេលក្រោយ។

គំរោងសុខភាពផ្លូវចិត្តក្នុងតំបន់

ប្រសិនបើអ្នកគិតថាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលMedi-Cal ហើយអ្នកគិតថាអ្នកត្រូវការនូវសេវាសុខភាពផ្លូវចិត្ត សូមទូរស័ព្ទទៅគំរោងសុខភាពផ្លូវចិត្ត (Mental Health Plan) ក្នុងតំបន់របស់អ្នក ហើយនិយាយថា ខ្ញុំចង់ដឹងអំពីសេវាសុខភាពផ្លូវចិត្ត។

តើអ្វីជាសេវាសុខភាពផ្លូវចិត្តឯកទេស (Specialty Mental Health Services)?

សេវាសុខភាពផ្លូវចិត្តឯកទេសជាសេវាថែទាំព្យាបាលសុខភាពយ៉ាងពិសេសសំរាប់មនុស្សទាំងឡាយដែលមានជំងឺផ្លូវចិត្ត រឺបញ្ហាផ្លូវអារម្មណ៍ដែលវេជ្ជបណ្ឌិតធម្មតាមិនអាចព្យាបាលបាន។

សេវាសុខភាពផ្លូវចិត្តឯកទេសរួមមាន:

- ការពិគ្រោះយោបល់ស្តីពីវិបត្តិដើម្បីជួយដល់អ្នកដែលកំពុងតែមានមានវិបត្តិផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរ
- ការព្យាលក្នុងលក្ខណ:បុគ្គល ក្រុម រឺគ្រួសារ
- ការធ្វើនិតិសម្បទា រឺសេវាចំពោះការជាសះស្បើយឡើងវិញផ្សេងៗដែលជួយមនុស្សម្នាក់ដែលមានជំងឺផ្លូវចិត្តអោយអភិវឌ្ឍន៍ជំនាញនៃការចំលងធ្វើតាមសំរាប់ការរស់នៅជាប្រចាំថ្ងៃ
- កម្មវិធីប្រចាំថ្ងៃពិសេសៗសំរាប់មនុស្សដែលមានជំងឺផ្លូវចិត្ត
- វេជ្ជបញ្ជចំពោះឱសថដែលជួយព្យាបាលជំងឺផ្លូវចិត្ត
- ជួយរៀបចំគ្រប់គ្រងឱសថដែលជួយព្យាបាលជំងឺផ្លូវចិត្ត
- ជួយស្វែងរកសេវាសុខភាពផ្លូវចិត្តដែលអ្នកត្រូវការ

តើខ្ញុំអាចទទួលសេវាសុខភាពផ្លូវចិត្តនៅឯណា?

អ្នកអាចទទួលសេវាសុខភាពផ្លូវចិត្តក្នុងតំបន់ដែលអ្នករស់នៅ។ តំបន់និមួយៗមានគំរោងសុខភាពផ្លូវចិត្តសំរាប់កុមារ ក្មេងជំទង់ មនុស្សពេញវ័យ និងមនុស្សពេញវ័យដែលមានវ័យចំណាស់។ គំរោងសុខភាពផ្លូវចិត្តនៃតំបន់របស់អ្នក មានអ្នកផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត (វេជ្ជបណ្ឌិតដែលជាអ្នកឯកទេសខាងព្យាបាលផ្លូវចិត្ត រឺអ្នកចិត្តសស្រ្ត និងអ្នកផ្សេងដទៃទៀត)។

តើខ្ញុំអាចទទួលសេវាផ្សេងៗនៅឯគំរោងសុខភាពផ្លូវចិត្តនៃតំបន់របស់ខ្ញុំដោយរបៀបណា?

សូមទូរស័ព្ទទៅគំរោងសុខភាពផ្លូវចិត្តនៃតំបន់របស់អ្នក និងស្នើសុំសេវាទាំងឡាយ។ អ្នកមិនចាំបាច់សុំការអនុញ្ញាតពីវេជ្ជបណ្ឌិតធម្មតារបស់អ្នក រឺទទួលការណែនាំអោយទៅរកឡើយ។ គ្រាន់តែទូរស័ព្ទទៅលេខទូរស័ព្ទសំរាប់តំបន់របស់អ្នកនៅក្នុងផ្នែកខាងមុខនៃសៀវភៅនេះចុះ។ ការទូរស័ព្ទពុំមានគិតថ្លៃឡើយ។

អ្នកអាចទៅកាន់មជ្ឈមណ្ឌលសុខភាពដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សំរាប់ការណែនាំ មជ្ឈមណ្ឌលសុខភាពជនបទ រឺគ្លីនិកសុខភាពឥណ្ឌានៅក្នុងតំបន់របស់អ្នកផងដែរ ដើម្បីទទួលសេវាសុខភាពផ្លូវចិត្តរបស់ Medi-Cal។ (ទាំងនេះគឺជាឈ្មោះជាផ្លូវការសំរាប់គ្លីនិកប្រភេទផ្សេងៗក្នុងតំបន់របស់អ្នក។ ប្រសិនបើអ្នកមិនដឹងច្បាស់អំពីគ្លីនិកនៅក្នុងតំបន់របស់អ្នកទេ សូមសួរបុគ្គលិកប្រចាំគ្លីនិក។ គ្លីនិកប្រភេទទាំងនេះ ជាទូទៅ បំរើសេវាដល់ពលរដ្ឋដែលមិនមានការធានារ៉ាប់រង Medi-Cal)។

ជាផ្នែកមួយនៃការផ្តល់សេវាសុខភាពផ្លូវចិត្តដល់អ្នក គំរោងសុខភាពផ្លូវចិត្តនៃតំបន់របស់អ្នក មានការទទួលខុសត្រូវចំពោះ:

*ប្រសិនបើអ្នកគិតថាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល **Medi-Cal** ហើយអ្នកគិតថាអ្នកត្រូវការនូវសេវាសុខភាពផ្លូវចិត្ត សូមទូរស័ព្ទទៅគំរោងសុខភាពផ្លូវចិត្ត **(Mental Health Plan)** ក្នុងតំបន់របស់អ្នក ហើយនិយាយថា ខ្ញុំចង់ដឹងអំពីសេវាសុខភាពផ្លូវចិត្ត។*

- រកមើលថាតើមានអ្នកណាម្នាក់ មានសិទ្ធទទួលសេវាសុខភាពផ្លូវចិត្តឯកទេសពី MHP ដែររឺទេ។
- ដោយផ្តល់នូវលេខទូរស័ព្ទដែលឥតគិតថ្លៃ ដែលឆ្លើយ 24-ម៉ោងក្នុងមួយថ្ងៃ និង 7 ថ្ងៃក្នុងមួយសប្តាហ៍ ដែលអាចប្រាប់អ្នកថាតើត្រូវទទួលសេវាផ្សេងៗពី MHP ដោយរបៀបណា។
- ធ្វើអោយមានអ្នកផ្តល់សេវាគ្រប់គ្រាន់ ដើម្បីមើលអោយច្បាស់ថាអ្នកអាចទទួលសេវាសុខភាពផ្លូវចិត្តឯកទេសដែលត្រូវបានធានារ៉ាប់រងដោយ MHP ប្រសិនបើអ្នកត្រូវការពួកវា។
- ជំរាបជូន និងអប់រំអ្នកអំពីសេវាទាំងឡាយដែលមានពី MHP របស់តំបន់របស់អ្នក។
- ផ្តល់អោយអ្នកនូវសេវាផ្សេងៗជាភាសាតាមជំរើសរបស់អ្នក រឺដោយមានអ្នកបកប្រែ (ប្រសិនបើចាំបាច់) ដោយឥតគិតថ្លៃ និងអោយអ្នកដឹងថាសេវាផ្តល់នូវអ្នកបកប្រែទាំងនេះអាចរកបាន។
- ផ្តល់អោយអ្នកនូវពត៌មានជាលាយល័ក្ខអក្សរ ស្តីអំពីអ្វីដែលមានចំពោះអ្នកជាភាសាផ្សេងៗ រឺជាទំរង់ផ្សេងៗ ដោយផ្អែកលើសេចក្តីត្រូវការក្នុងតំបន់របស់អ្នក។

ពត៌មានសំខាន់ស្ដីអំពី Medi-Cal

តើអ្នកណាអាចទទួល Medi-Cal បាន?

អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបាននូវ Medi-Cal ប្រសិនបើអ្នកស្ថិតក្នុងក្រុមណាមួយ ក្នុងចំណោមក្រុមទាំងនេះ:

- មានអាយុ 65ឆ្នាម រឺចាស់ជាង
- មានអាយុក្រោម 21ឆ្នាំ
- ជាមនុស្សពេញវ័យ មានអាយុចន្លោះពី 21 ទៅ 65ឆ្នាំ ដែលមានកូនជាអនិតិជន (minor child) រស់នៅជាមួយអ្នក (កូនដែលមិនទាន់រៀបការ ហើយមានអាយុក្រោម 21)។
- មានភាពពិការផ្នែក រឺពិការអវៈយវៈ
- មានគត៌
- ជាជនភៀសខ្លួនមួយចំនួន រឺជាជនអន្តោប្រវេស្តន៍ជនជាតិគុយបា/ ហៃទី (Cuban/Haitian)
- កំពុងទទួលការថៃទាំព្យាបាលពីមជ្ឈមណ្ឌលសំរាប់សំរាកថែទាំព្យាបាល



ប្រសិនបើអ្នកមិនមែនជាក្រុមក្នុងចំណោមក្រុមទាំងនេះទេ សូមទូរស័ព្ទទៅទីភ្នាក់ងារសេវាសង្គមប្រចាំតំបន់របស់អ្នក ដើម្បីពិនិត្យមើលថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះកម្មវិធីជំនួយផ្នែកវេជ្ជសាស្ត្រដែលប្រតិបត្តិការដោយតំបន់។

អ្នកត្រូវតែកំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល Medi-Cal។ សូមទូរស័ព្ទទៅ រឺទៅកាន់ការិយាល័យសេវាសង្គមប្រចាំតំបន់របស់អ្នកដើម្បីសុំពាក្យសុំ Medi-Cal រឺទទួលពាក្យសុំមួយតាមអ៊ីនធឺណិត តាមអាស័យដ្ឋានៈ
www.dhs.ca.gov/mcs/medi-calhome/MC210.htm

តើខ្ញុំត្រូវតែបង់ថ្លៃអោយ Medi-Cal ដែររឺទេ?

អ្នកអាចត្រូវបង់ថ្លៃអោយ Medi-Cal អាស្រ័យលើចំនួនលុយដែលអ្នកទទួល រឺរកបានក្នុងមួយខែ។

- ប្រសិនបើចំណូលរបស់អ្នកតិចជាងការកំណត់របស់ Medi-Cal សំរាប់ទំហំគ្រួសាររបស់អ្នក អ្នកនឹងមិនចាំបាច់ត្រូវបង់ថ្លៃចំពោះសេវារបស់ Medi-Cal ទេ។
- ប្រសិនបើចំណូលរបស់អ្នកច្រើនជាងកំរិតកំណត់របស់ Medi-Cal សំរាប់ទំហំគ្រួសាររបស់អ្នក អ្នកណឹងត្រូវបង់ប្រាក់ខ្លះ សំរាប់សេវាសុខភាពផ្លូវចិត្តរឺវេជ្ជសាស្ត្ររបស់អ្នក។ ចំនួនដែលអ្នកបង់ត្រូវបានគេហៅថា "ការរួមចំណែកការចំណាយ (‘share of cost’)" របស់អ្នក។ នៅពេលដែលអ្នកបានបង់ចំណែកការចំណាយ ‘share of cost,’ របស់អ្នក Medi-Cal នឹងបង់ថ្លៃដែលនៅសល់ នៃវិក័យប័ត្រផ្នែកវេជ្ជសាស្ត្រដែលត្រូវបានធានារ៉ាប់រងរបស់អ្នកសំរាប់ខែនោះ។ ចំពោះខែដែលអ្នកមិនមានការចំណាយផ្នែកវេជ្ជសាស្ត្រទេ អ្នកមិនចាំបាច់បង់អ្វីទាំងអស់។

ជានិច្ចកាល ត្រូវយកកាតសំគាល់ខ្លួននិងកាតគំរោងសុខភាពទៅជាមួយ ប្រសិនបើអ្នកមាន នៅពេល ទៅជួបវេជ្ជបណ្ឌិត ទៅកាន់គ្លីនិក រឺមន្ទីរពេទ្យ។

- អ្នកប្រហែលជាត្រូវបង់ "ការបង់ថ្លៃរួម" ('co-payment') សំរាប់ការព្យាបាលណាដែលនៅក្រោម Medi-Cal។ អ្នកអាចប្រហែលជាត្រូវបង់ $1.00 ក្នុងពេលម្តងៗដែលអ្នកទទួលសេវាសុខភាពផ្លូវចិត្ត ថ្នាំ(ឱសថ)ដែលត្រូវបានចេញវេជ្ជបញ្ជា និង $5.00 ប្រសិនបើអ្នកទៅកាន់បន្ទប់សង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យ ដើម្បីទទួលសេវាធម្មតាផ្សេងៗរបស់អ្នក។

អ្នកផ្តល់សេវារបស់អ្នក នឹងប្រាប់អ្នកថាតើអ្នកនឹងចាំបាច់ត្រូវបង់ថ្លៃរួម (co-payment) ដែររឺអត់។

តើខ្ញុំអាចទទួលសេវាផ្សេងៗរបស់ Medi-Cal ដែលមិនត្រូវបានធានារ៉ាប់រងដោយគំរោងសុខភាពផ្លូវចិត្ត (Mental Health Plan) ដែររឺទេ?

មានវិធីពីរយ៉ាងដើម្បីទទួលបាននូវសេវារបស់ Medi-Cal:

1. ដោយចូលរួមក្នុងគំរោងសុខភាពដែលមានការថែគ្រប់គ្រងទាំរបស់ Medi-Cal។

ប្រសិនបើអ្នកជាសមាជិកនៃគំរោងសុខភាពដែលមានការថែទាំគ្រប់គ្រងរបស់ Medi-Cal:

- គំរោងសុខភាពរបស់អ្នក ចាំបាច់ត្រូវរកអ្នកផ្តល់សេវាណាមួយអោយអ្នក ប្រសិនបើអ្នកត្រូវការការថែទាំសុខភាព។
- អ្នកទទួលការថែទាំសុខភាពរបស់អ្នកតាមរយៈគំរោងសុខភាពមួយដែលជា HMO (health maintenance organization=អង្គការថែទាំសុខភាព) រឺអ្នកគ្រប់គ្រងករណីថែទាំជាបឋម។
- អ្នកត្រូវតែប្រើអ្នកផ្តល់សេវា រឺគ្លីនិកដែលនៅក្នុងគំរោងសុខភាព ប្រសិនបើអ្នកមិនត្រូវការនូវការថែទាំជាបន្ទាន់ទេនោះ។
- អ្នកអាចប្រើប្រាស់អ្នកផ្តល់សេវាក្រៅពីគំរោងសុខភាពរបស់អ្នកចំពោះសេវារៀបចំផែនការគ្រួសារ។
- អ្នកអាចចូលរួមតែក្នុងគំរោងសុខភាពប៉ុណ្ណោះ ប្រសិនបើអ្នកមិនបង់ថ្លៃចំណែកការចំណាយទេនោះ។

2. ពីអ្នកផ្តល់សេវាថែទាំសុខភាព រឺគ្លីនិកទាំងឡាយដែលទទួលយក Medi-Cal។

- អ្នកអាចទទួលការថែទាំព្យាបាលពីអ្នកផ្តល់សេវា រឺគ្លីនិកនិមួយៗ ដែលទទួលយក Medi-Cal
- អ្នកត្រូវតែប្រាប់អ្នកផ្តល់សេវារបស់អ្នកថាអ្នកមានMedi-Cal ជាមុនសិន មុនពេលដែលអ្នកទទួលសេវាផ្សេងៗ។ បើមិនដូច្នោះទេ អ្នកអាចត្រូវបានគេគិតថ្លៃសំរាប់សេវាទាំងនោះ។
- អ្នកផ្តល់សេវាថែទាំសុខភាពដល់បុគ្គល និងគ្លីនិកនាន មិនចាំបាច់ត្រូវតែពិនិត្យអ្នកជំងឺដែលមាន Medi-Cal patients រឺអាចមើលតែអ្នកជំងឺដែលមាន Medi-Cal ពីរបីនាក់ប៉ុណ្ណោះទេ។
- អ្នករាល់គ្នាដែលមានចំណែកមួយក្នុងការចំណាយ (a share of cost) (សូមមើលទំព័រទីក្នុងផ្នែករដ្ឋកាលីហ្វ័រញ៉ា) នឹងទទួលការថែទាំសុខភាពរបៀបនេះ។

ប្រសិនបើអ្នកត្រូវការសេវាថែទាំសុខភាពផ្លូវចិត្ត ដែលមិនត្រូវបានធានារ៉ាប់រងដោយគំរោងសុខភាពផ្លូវចិត្ត (Mental Health Plan):

- ហើយអ្នកស្ថិតក្នុងគំរោងសុខភាពមួយ អ្នកអាចទទួលសេវាទាំងនេះពីគំរោងសុខភាពរបស់អ្នក។ ប្រសិនបើអ្នកត្រូវការសេវាថែទាំសុខភាពផ្លូវចិត្តដែលគំរោងនោះមិនធានារ៉ាប់រង អ្នកផ្តល់សេវាថែទាំសុខភាពបឋមរបស់អ្នកនៅឯគំរោងសុខភាពនោះ អាចជួយអ្នកស្វែងរកអ្នកផ្តល់សេវា រឺគ្លីនិកដែលអាចជួយអ្នកបាន។
- លើកលែងតែក្នុងតំបន់San Mateo ឱសថស្ថានរបស់គំរោងសុខភាពរបស់អ្នក នឹងបំពេញវេជ្ជបញ្ជាដើម្បីព្យាបាលជំងឺផ្លូវចិត្តរបស់អ្នក ទោះបីជាវេជ្ជបញ្ជាទាំងឡាយត្រូវបានសរសេរដោយអ្នកឯកទេសខាងផ្លូវចិត្តរបស់គំរោង សុខភាពផ្លូវចិត្តរបស់អ្នក រឺប្រាប់អ្នកពីរបៀបទទួលការបំពេញវេជ្ជបញ្ជារបស់អ្នកពីឱសថស្ថានរបស់Medi-Cal ធម្មតាក៏ដោយ។ (នៅក្នុងតំបន់San Mateo គំរោងសុខភាពផ្លូវចិត្ត នឹងបំពេញវេជ្ជបញ្ជារបស់អ្នក)។
- ហើយអ្នកមិនស្ថិតក្នុងគំរោងសុខភាពមួយទេ អ្នកអាចទទួលសេវាផ្សេងៗពីអ្នកផ្តល់សេវាដល់បុគ្គល រឺគ្លីនិកណាដែលទទួលយក Medi-Cal។ លើកលែងតែក្នុងតំបន់ San Mateo ឱសថស្ថានណាដែលទទួល Medi-Cal អាចបំពេញវេជ្ជបញ្ជាដើម្បីព្យាបាលជំងឺផ្លូវចិត្តរបស់អ្នក ទោះបីជាវេជ្ជបញ្ជាត្រូវបានសរសេរដោយអ្នកឯកទេសខាងព្យាបាលផ្លូវចិត្តរបស់ MHP ក៏ដោយ។ (នៅក្នុងតំបន់ San Mateo គំរោងសុខភាពផ្លូវចិត្ត នឹងបំពេញវេជ្ជបញ្ជារបស់អ្នក)។
- គំរោងសុខភាពផ្លូវចិត្ត អាចជួយអ្នកស្វែងរកអ្នកផ្តល់សេវា រឺគ្លីនិកដែលអាចជួយអ្នក រឺផ្តល់អោយអ្នកនូវគំនិតខ្លះៗស្តីពីរបៀបរកអ្នកផ្តល់សេវា រឺគ្លីនិក។

ប្រសិនបើអ្នកមានបញ្ហាក្នុងការទទួលការណាត់ជួបដើម្បីពិនិត្យសុខភាព រឺសុខភាពផ្លូវចិត្តរបស់អ្នក កម្មវិធី **Medi-Cal** អាចជួយអ្នកស្វែងរកការដឹកជញ្ជូនបាន។

ប្រសិនបើអ្នកមានបញ្ហាក្នុងការទទួលការណាត់ជួបដើម្បីពិនិត្យសុខភាព រឺសុខភាពផ្លូវចិត្តរបស់អ្នក កម្មវិធី Medi-Cal អាចជួយអ្នកស្វែងរកការដឹកជញ្ជូន។

- សំរាប់កុមារ កម្មវិធីការពារភាពពិការនិងសុខភាពកុមារប្រចាំតំបន់ (Child Health and Disability Prevention (CHDP)) អាចជួយបាន។ រឺ អ្នកអាចចង់ទាក់ទងទៅការិយាល័យសេវាសង្គមកិច្ចរបស់តំបន់របស់អ្នក។ លេខទូរស័ព្ទទាំងនេះ អាចត្រូវបានរកឃើញនៅក្នុងទំព័រផ្នែក "រដ្ឋាភិបាលតំបន់ " សៀវភៅលេខទូរស័ព្ទក្នុងតំបន់ របស់អ្នក។ អ្នកអាចទទួលព័ត៌មានទាំងនេះតាមអ៊ីនធឺណិតដោយចូលទៅអាស័យដ្ឋាន: **www.dhs.ca.gov** រួចហើយចុចលើពាក្យថាសេវា (‘Services’) និងពាក្យថាព័ត៌មាន Medi-Cal (‘Medi-Cal Information’)។

- សំរាប់ព័ត៌មានបន្ថែម ការិយាល័យសេវាសង្គមនៃតំបន់របស់អ្នក អាចជួយបាន។ អ្នកអាចទទួលព័ត៌មានអំពីការិយាល័យសេវាសង្គមកិច្ចរបស់តំបន់របស់អ្នក ដោយឆែករកក្នុងសៀវភៅលេខទូរស័ព្ទ។ រឺអ្នកអាចទទួលព័ត៌មានតាមអ៊ីនធឺណិត ដោយចូលទៅអាស័យដ្ឋាន: **www.dhs.ca.gov** រួចហើយចុចលើពាក្យ ‘Services’ រួចហើយចុចលើ ‘Medi-Cal Information’។

តើអ្វីជាកម្មវិធីការពារភាពពិការនិងសុខភាពរបស់កុមារ [Child Health And Disability Prevention (CHDP) Program]?

កម្មវិធី CHDP គឺជាកម្មវិធីការពារដែលបំរើដល់កុមារនិងយុវជនរបស់រដ្ឋកាលីហ្វ័រញ៉ាចាប់ពីកំណើតដល់អាយុ 21ឆ្នាំ។ CHDP រៀបចំអោយមានការថែទាំព្យាបាលសំរាប់កុមារនិងយុវជនដែលមានបញ្ហាផ្នែកសុខភាពព្រមជា មួយអ្នកទាំងឡាយណាដែលទំនងជាមានសុខភាពល្អផងដែរ។ កុមារនិងយុវជនអាចទទួលការវាយតំលៃសុខភាពដើម្បីការការពារជាធម្មតាផ្សេងៗ។ កុមារនិងយុវជនដែលមានបញ្ហាសង្ស័យត្រូវបានណែនាំអោយទៅរកការធ្វើរោគសញ្ញានិងការព្យាបាល។ បញ្ហាសុខភាពជាច្រើនអាចត្រូវបានការពារ រឺកែតំរូវ កាត់បន្ថយនូវភាពធ្ងន់ធ្ងរ តាមរយៈការតាមដាននិងការពិនិត្យរោគសញ្ញាភ្លាម និងការព្យាបាលពីដំបូង។





CHDP ធ្វើការជាមួយអ្នកផ្តល់សេវាថែទាំព្យបាលសុខភាពមួយចំនួនធំ និងអង្គការផ្សេងៗ ដើម្បីធានាថាកុមារនិងយុវជនដែលមានសិទ្ធទទួលបាននូវសេវាសមស្រប។ ទាំងនេះអាចរួម បញ្ចូលទាំងវេជ្ជបណ្ឌិតឯកជន នាយកដ្ឋានសុខាភិបាលប្រចាំតំបន់ សាលារៀន វេបណ្ឌិតជាគិលានុបដ្ឋាយិកា ទន្តបណ្ឌិតអ្នកអប់រំផ្នែកសុខភាព អ្នកឯកទេសខាងចំណីអាហារូបត្ថម្ភ មន្ទីរពិសោធន៍ គ្លីនិកតាមសហគមន៍ ទីភ្នាក់ងារសុខភាពដែលមិនរកកំរៃ និងទីភ្នាក់ងារសេវាសហគមន៍ និងសង្គមនានា។ CHDP អាចជួយផងដែរ ដល់គ្រួសារដែលមានកាលវិភាគណាត់ជួបដើម្បីពិនិត្យសុខភាព ការដឹកជញ្ជូន និងសិទ្ធចេញចូលដល់សេវាធ្វើរោគសាស្ត្រ និងព្យាបាល។

អ្នកអាចស្វែងរកបន្ថែមទៀតអំពី CHDP ដោយទាក់ទងទៅនាយកដ្ឋានសុខាភិបាលក្នុងតំបន់របស់អ្នក រឺចូលទៅអ៊ីនធឺណិតតាមអាស័យដ្ឋាន: **www.dhs.ca/gov.pcfh/cms/chdp/directory.htm**។

តើខ្ញុំអាចទទួលព័ត៌មានបន្ថែមនៅឯណា?

អ្នកអាចទទួលព័ត៌មានបន្ថែមអំពីសេវាសុខភាពផ្លូវចិត្តផ្សេងៗ ដោយចូលទៅគេហទំព័ររបស់នាយកដ្ឋានសុខភាពផ្លូវចិត្តរបស់រដ្ឋកាលីហ្វ័រញ៉ាតាមអាស័យដ្ឋាន **www.dmh.ca.gov**។

អ្នកអាចទទួលព័ត៌មានបន្ថែមស្តីពី Medi-Cal ដោយសួរបុគ្គលិកផ្នែកសិទ្ធទទួលនៃតំបន់របស់អ្នក រឺដោយចូលទៅគេហទំព័រ **www.dhs.ca.gov/mcs/medi-calhome**។

ពត៌មានបន្ទាន់ជាមូលដ្ឋាន

ក្នុងករណីមានស្ថានភាពភាពអាសន្នផ្នែកវេជ្ជសាស្ត្រ រឺផ្នែកផ្លូវចិត្ត សូមទូរស័ព្ទទៅលេខ **9-1-1** *រឺទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ដើម្បីទទួលជំនួយ។*

អ្នកកំពុងមានភាពអាសន្ន?

ស្ថានភាពវេជ្ជសាស្ត្រដែលបន្ទាន់ មានរោគសញ្ញាធ្ងន់ធ្ងរខ្លាំង (ដែលអាចរួមទាំងការឈឺចាប់ធ្ងន់ធ្ងរ) ដែលមនុស្សធម្មតាអាចរំពឹងថាអ្វីខាងក្រោមអាចនឹងកើតឡើងនៅពេលណាមួយ:

- សុខភាពរបស់បុគ្គល (រឺ ដោយទាក់ទិននឹងស្ត្រីមានគត៌ សុខភាពរបស់ស្ត្រី រឺកូនដែលមិនទាន់កើតរបស់នាង) អាចស្ថិតក្នុងបញ្ហាភាពធ្ងន់ធ្ងរ។
- បញ្ហាធ្ងន់ធ្ងរផ្សេងៗដែលទាក់ទិននឹងដំណើរការផ្នែករាងកាយ។
- បញ្ហាធ្ងន់ធ្ងរដែលទាក់ទងនឹងផ្នែក រឺសរីរាង្គនៃរាងកាយ។

ស្ថានភាពផ្នែកផ្លូវចិត្តធ្ងន់ធ្ងរ កើតឡើងនៅពេលដែលមនុស្សធម្មតាគតិតថានរណាម្នាក់:

- គឺជាគ្រោះថ្នាក់នាពេលបច្ចុប្បន្នដល់ខ្លួនគេ រឺនាង រឺអ្នកផ្សេងណាម្នាក់ទៀត ដោយសារតែអ្វីមួយដែលហាក់ដូចជាជំងឺផ្លូវចិត្ត។
- មិនអាចផ្តល់អោយភ្លាម រឺបរិភោគអាហារ រឺប្រើប្រាស់សំលៀកបំពាក់ រឺទីជំរក ដោយសារតែជំងឺផ្លូវចិត្ត។

ក្នុងករណីដែលមានស្ថានភាពផ្លូវចិត្ត រឺផ្នែកវេជ្ជសាស្ត្របន្ទាន់ សូមទូរស័ព្ទមកលេខ 9-1-1 រឺទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ណាមួយដើម្បីអោយគេជួយ។

កម្មវិធី Medi-Cal នឹងធានារ៉ាប់រងលើស្ថានភាពអាសន្ន ទោះជាស្ថានភាពនោះជាផ្នែកវេជ្ជសាស្ត្រ រឺចិត្តសស្ត្រ (ផ្លូវអារម្មណ៍ រឺផ្លូវចិត្ត) ក៏ដោយ។ ប្រសិនបើអ្នកស្ថិតក្នុង Medi-Cal អ្នកនឹងទទួលវិក័យប័ត្រមួយអោយបង់ថ្លៃការទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ ទោះបីជាវាត្រូវបានប្រែទៅជាមិនមែនជាភាពអាសន្នវិញក៏ដោយ។
ប្រសិនបើអ្នកមិនច្បាស់ថាតើស្ថានភាពនោះពិតជាភាពអាសន្នយ៉ាងពិតប្រាកដទេ រឺអ្នកមិនច្បាស់ថាតើស្ថានភាពនោះជាផ្នែកផ្លូវចិត្ត រឺផ្លូវកាយវេជ្ជសាស្ត្រទេ អ្នកនៅតែអាចទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ ហើយអនុញ្ញាតអោយអ្នកជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ ធ្វើការសំរេចចិត្តអំពីអ្វីដែលចាំបាច់។ ប្រសិនបើអ្នកជំនាញនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់សំរេចថាមានភាពបន្ទាន់ផ្នែកផ្លូវចិត្ត អ្នកនឹងត្រូវបានអនុញ្ញាតអោយចូលមន្ទីរពេទ្យ ដើម្បីទទួលការជួយគាំពារជាបន្ទាន់ពីអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត។ ប្រសិនបើមន្ទីរពេទ្យមិនមានប្រភេទសេវាដែលចាំបាច់ទេ មន្ទីរពេទ្យនឹងរកមន្ទីរពេទ្យផ្សេងទៀតដែលមានសេវានោះ។

មនុស្សម្នាក់អាចត្រូវបានជួយតាមរយៈវិបត្តិសុខភាពផ្លូវចិត្ត ដោយសេវាផ្សេងៗពីគំរោងសុខភាពផ្លូវចិត្ត (Mental Health Plan (MHP)) របស់តំបន់របស់អ្នក នៅតាមមធ្យោបាយផ្សេងៗ ជាជាងទៅកាន់មន្ទីរពេទ្យ។ ប្រសិនបើអ្នកគិតថាអ្នកត្រូវការជំនួយ ប៉ុន្តែមិនគិតថាអ្នកចាំបាច់ត្រូវទៅមន្ទីរពេទ្យ អ្នកអាចទូរស័ព្ទទៅ MHP នៅក្នុងតំបន់របស់អ្នក តាមលេខទូរស័ព្ទដែលឥតគិតថ្លៃ ហើយសុំជំនួយ។

តើសេវាដែលទាក់ទិននឹងភាពអាសន្នប្រភេទណាដែលត្រូវបានផ្តល់អោយ?

សេវាបន្ទាន់ ត្រូវបានបង់ថ្លៃដោយ Medi-Cal នៅពេលដែលអ្នកទៅកាន់មន្ទីរពេទ្យ រឺប្រើប្រាស់សេវាសំរាប់អ្នកជំងឺសំរាកខាងក្រៅ (ដែលពុំមានការស្នាក់នៅមួយយប់ឡើយ) ត្រូវបានដាក់នៅក្នុងបន្ទប់សង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យ ដោយអ្នកផ្តល់សេវាដែលមានលក្ខណៈសម្បត្តិ (វេជ្ជបណ្ឌិត អ្នកឯកទេសខាងព្យាបាលរោគផ្លូវចិត្ត រឺអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តដទៃទៀត)។ ពួកគេត្រូវបានគេត្រូវការដើម្បីវាយតំលៃ រឺធ្វើអោយនរណាម្នាក់ដែលមានភាពបន្ទាន់មានភាពនឹងនរ។

គំរោងសុខភាពផ្លូវចិត្ត (MHP) របស់តំបន់របស់អ្នក គួរតែផ្តល់អោយនូវពត៌មានដែលជាក់លាក់អំពីរបៀបដែលសេវាបន្ទាន់ត្រូវបានគ្រប់គ្រងដឹកនាំនៅក្នុងតំបន់របស់អ្នក។ ក្បួនច្បាប់រដ្ឋនិងសហព័ន្ធដូចខាងក្រោម អនុវត្តន៏ចំពោះសេវាជាបន្ទាន់ដែលត្រូវបានធានារ៉ាប់រងដោយ MHP:

- មន្ទីរពេទ្យមិនត្រូវការទទួលនូវការអនុម័តយល់ព្រមជាមុនពី MHP (ជួនកាលត្រូវបានគេហៅថា "ការអនុញ្ញាតជាមុន") រឺមានកិច្ចសន្យាជាមួយ MHP របស់អ្នក ដើម្បីទទួលការបង់ថ្លៃសំរាប់សេវាជាបន្ទាន់ដែលមន្ទីរពេទ្យផ្តល់អោយអ្នក។
- MHP ត្រូវការប្រាប់អ្នកពីរបៀបទទួលសេវាជាបន្ទាន់ ដែលរួមមានការប្រើប្រាស់លេខទូរស័ព្ទ 9-1-1។
- MHP ចាំបាច់ត្រូវប្រាប់អ្នកអំពីទីតាំងនៃកន្លែងផ្សេងៗដែលអ្នកផ្តល់សេវា និងមន្ទីរពេទ្យផ្តល់នូវសេវាជាបន្ទាន់ដែលមានភាព និងសេវាក្រោយពេលធ្វើអោយមានភាពនឹងនរហើយ។
- អ្នកអាចទៅកាន់មន្ទីរពេទ្យដើម្បីទទួលការព្យាបាលជាបន្ទាន់ ប្រសិនបើអ្នកជឿថាមាននូវភាពបន្ទាន់ផ្នែកព្យាបាលផ្លូវចិត្ត។
- សេវាសុខភាពផ្លូវចិត្តដែលមានលក្ខណៈឯកទេស ដើម្បីព្យាបាលស្ថានភាពបន្ទាន់របស់អ្នកមានរយៈពេល 24 ម៉ោង ក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៏។ (ស្ថានភាពជាបន្ទាន់មានន័យថាវិបត្តិសុខភាពផ្លូវចិត្តដែលនឹងប្រែក្លាយទៅជាភាពអាសន្ន ប្រសិនបើអ្នកមិនទទួលជំនួយជាបន្ទាន់នោះទេ)។
- អ្នកអាចទទួលសេវាពីមន្ទីរពេទ្យសំរាប់អ្នកជំងឺដែលស្នាក់នៅទាំងនេះ ពី MHP លើមូលដ្ឋានស្ម័គ្រចិត្ត ប្រសិនបើអ្នកត្រូវបានបំរើយ៉ាងត្រឹមត្រូវ ដោយគ្មានភាពដែលត្រូវបានធ្វើឡើងដោយមិនស្ម័គ្រចិត្ត។ ច្បាប់រដ្ឋដែលក្តោបទៅលើការអនុញ្ញាតអោយចូលដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត ទៅកាន់មន្ទីរពេទ្យដើម្បីទទួលការព្យាបាលជំងឺផ្លូវចិត្ត មិនមែនជាផ្នែកនៃក្បួនច្បាប់របស់ Medi-Cal របស់រដ្ឋ រឺសហព័ន្ធនោះទេ ប៉ុន្តែវាអាចមានសារៈសំខាន់សំរាប់អ្នកក្នុងការដឹងបន្តិចបន្តួចអំពីវា:
    1. **ការអនុញ្ញាតអោយចូលដោយស្មគ្រចិត្ត:** នេះមានន័យថា អ្នកផ្តល់អោយនូវការយល់ព្រមរបស់អ្នកក្នុងការចូលទៅក្នុង និង/រឺ ស្នាក់នៅក្នុងមន្ទីរពេទ្យ។
    2. **ការអនុញ្ញាតិដោយមិនស្ម័គ្រចិត្ត:** នេះមានន័យថាមន្ទីរពេទ្យរក្សាអ្នកអោយនៅក្នុងមន្ទីរពេទ្យ អស់រយៈពេលរហូតដល់

*គំរោងសុខភាពផ្លូវចិត្ត **(MHP)** នៃតំបន់របស់អ្នក គួរតែបង់ថ្លៃចំពោះសេវាថែទាំក្រោយពេលធ្វើអោយមានភាពនឹងនរឡើងវិញ ដែលទទួលបានក្នុងតារាងរាយនាមអ្នកផ្តល់សេវា រឺ តំបន់រ៉ាប់រង។ **MHP** របស់អ្នកនឹងបង់ថ្លៃសំរាប់សេវាបែបដូច្នោះ ប្រសិនបើពួកគេត្រូវបានយល់ព្រមជាមុន ដោយអ្នកផ្តល់សេវារបស់ **MHP** រ៉ អ្នកតំណាងដទៃទៀតរបស់ **MHP**។*

72 ម៉ោង ដោយគ្មានការយល់ព្រមរបស់អ្នក។ មន្ទីរពេទ្យអាចធ្វើដូច្នេះ នៅពេលដែលមន្ទីរពេទ្យ គិតថាអ្នកទំនងជាធ្វើអោយគ្រោះថ្នាក់ដល់ខ្លួនឯង រឺអ្នកដទៃ រឺថា អ្នកមិនអាចចាត់ចែងរឿងម្ហូបអាហារផ្ទាល់ខ្លួន សំលៀកបំពាក់ និងតំរូវការផ្ទះសំបែងរបស់អ្នកបាន។ មន្ទីរពេទ្យនឹងប្រាប់អ្នកជាលាយល័ក្ខអក្សរ នូវអ្វីដែលមន្ទីរពេទ្យកំពុងធ្វើសំរាប់អ្នក និងអ្វីជាសិទ្ធរបស់អ្នក។ ប្រសិនបើវេជ្ជបណ្ឌិតដែលព្យាបាលអ្នក គិតថាអ្នកត្រូវការពេលច្រើនជាង 72 ម៉ោង អ្នកមានសិទ្ធទៅកាន់មេធាវី និងសាវនាការ មុនពេលចៅក្រម និងមន្ទីរពេទ្យប្រាប់អ្នកថាតើសុំអ្វីនេះដោយរបៀបណា។

សេវាថែទាំព្យាបាល*ក្រោយពេលធ្វើអោយមានភាពនឹងនរមក* គឺជាសេវាដែលត្រូវបានធានារ៉ាប់រង ដែលត្រូវបានគេត្រូវការបន្ទាប់ពីមានភាពបន្ទាន់។ សេវាទាំងនេះ ត្រូវបានផ្តល់អោយ បន្ទាប់ពីភាពបន្ទាន់ចប់ ដើម្បីបន្តបង្កើន រឺដោះស្រាយស្ថានភាពនោះ។

MHP របស់អ្នក ទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះ (នឹងបង់ថ្លៃ) សេវាថែទាំក្រោយពេលដែលមានភាពនឹងនរ ដើម្បីរក្សា បង្កើន រឺដោះស្រាយស្ថានភាពដែលត្រូវបានគេធ្វើអោយនឹងនរ ប្រសិនបើៈ

- MHP មិនឆ្លើយតបចំពោះសំណើរពីអ្នកផ្តល់សេវាចំពោះការយល់ព្រមជាមុនក្នុងអំឡុងពេល 1 ម៉ោងទេ។
- MHP មិនអាចត្រូវបានទាក់ទងដោយអ្នផ្តល់សេវាឡើយ
- អ្នកតំណាងរបស់ MHP និងវេជ្ជបណ្ឌិតដែលព្យាបាល មិនអាចចុះកិច្ចព្រមព្រៀងដែលទាក់ទិននឹងការថែទាំរបស់អ្នក ហើយវេជ្ជបណ្ឌិតនៃ MHP មិនអាចមានសំរាប់ការពិគ្រោះយោបល់។ ក្នុងស្ថានភាពបែបនេះ MHP ត្រូវតែផ្តល់អោយវេជ្ជបណ្ឌិតដែលព្យាបាល នូវឱកាសដើម្បីពិគ្រោះយោបល់ ជាមួយវេជ្ជបណ្ឌិតរបស់ MHP។ វេជ្ជបណ្ឌិតដែលព្យាបាលអាចបន្តជាមួយនឹងការថែទាំអ្នកជំងឺនោះ រហូតដល់ស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំងនោះសំរាប់ការថែទាំព្យបាលក្រោយពេលធ្វើអោយមានភាពនឹងនរ ត្រូវបានឆ្លើយតប។ MHP ត្រូវតែពិនិត្យមើលអោយច្បាស់ថាអ្នកមិនបាច់បង់ថ្លៃអ្វីបន្ថែមសំរាប់ការថែទាំក្រោយពេលដែលធ្វើអោយមានភាពនឹងនរទេ។

តើទំនួលខុសត្រូវសំរាប់ការថែទាំក្រោយពេលដែលធ្វើអោយមានភាពនឹងនររបស់ MHP នៃតំបន់របស់ខ្ញុំចប់ ?

MHP នៃតំបន់របស់អ្នក មិនត្រូវបានទាមទារអោយបង់ថ្លៃសេវាថែទាំព្យាបាលក្រោយពេលធ្វើអោយមានភាពនឹងនរ មិនត្រូវបានអនុម័តយល់ព្រមជាមុន នៅពេលដែលៈ

- វេជ្ជបណ្ឌិតរបស់ MHP ដែលមានអភ័យឯកសិទ្ធនៅឯមន្ទីរពេទ្យដែលកំពុងព្យាបាល មានទំនួលខុសត្រូវចំពោះការថែទាំរបស់អ្នក។

- វេជ្ជបណ្ឌិតរបស់ MHP មានទំនួលខុសត្រូវចំពោះ ការថែទាំរបស់អ្នក តាមរយៈការផ្ទេរ។
- អ្នកតំណាងរបស់ MHP និងវេជជបណ្ឌិតដែលព្យាបាល ចុះកិច្ចព្រមព្រៀងទាក់ទិនទៅនឹងការថែទាំរបស់អ្នក (MHPនិងវេជ្ជបណ្ឌិត នឹងអនុវត្តតាមកិច្ចព្រមព្រៀងរបស់ពួកគេអំពីការថែទាំដែលអ្នកត្រូវការ)។
- អ្នកត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យ (បញ្ជូនទៅផ្ទះ ចេញពីអាគារមន្ទីរពេទ្យ ដោយវេជ្ជបណ្ឌិត រឺអ្នកជំនាញដទៃទៀត)។

មនុស្សពេញវ័យ និងមនុស្សពេញវ័យដែលចំណាស់



តើខ្ញុំដឹងថាពេលខ្ញុំត្រូវការជំនួយដោយរបៀបណា?

មនុស្សជាច្រើន មានភាពលំបាកក្នុងជីវិត និងប្រហែលជាឆ្លងកាត់បញ្ហាសុខភាពផ្លូវចិត្ត។ នៅពេលដែលមនុស្សជាច្រើន គិតថាភាពមិនប្រក្រតីផ្នែកផ្លូវអារម្មណ៍ និងផ្លូវចិត្តចំបងៗកំរនឹងមាន រឿងពិតនោះគឺ បុគ្គលម្នាក់ក្នុងចំណោមបុគ្គលប្រាំអ្នក នឹងមានភាពមិនប្រក្រតីផ្នែកផ្លូវចិត្ត (ផ្នែកចិត្តសាស្ត្រ) ក្នុងចំណុចណាមួយក្នុងជីវិតរបស់គេ។ ដូចជំងឺជាច្រើនដទៃទៀតដែរ ជំងឺផ្លូវចិត្តអាចត្រូវបានបង្កឡើងដោយអ្វីៗផ្សេងៗជាច្រើន។

រឿងដែលសំខាន់បំផុតត្រូវចងចាំនោះគឺ នៅពេលដែលសួរខ្លួនអ្នក ថាតើអ្នកត្រូវការជំនួយពីអ្នកជំនាញ គឺដើម្បីជឿលើអារម្មណ៍របស់អ្នករីយ៉ាងណា។ ប្រសិនបើអ្នកមានសិទ្ធទទួល Medi-Cal ហើយអ្នកមានអារម្មណ៍ថាអ្នកអាចត្រូវការជំនួយជំនាញ អ្នកគួរតែស្នើសុំ ការវាយតំលៃពី MHP នៃតំបន់របស់អ្នកដើម្បីរកអោយឃើញអោយបានច្បាស់។

តើអ្វីខ្លះជាសញ្ញាថាខ្ញុំប្រហែលជាត្រូវការជំនួយរឺទេ?

ប្រសិនបើអ្នកអាចឆ្លើយថា "មែន (yes)" ចំពោះចំនុចមួយ រឺច្រើនក្នុងចំណោមចំណុចទាំងឡាយដូចខាងក្រោម **ហើយ** រោគសញ្ញាទាំងនេះនៅមានជាប់ជាច្រើនសប្តាហ៍ **ហើយ** ពួកគេមានការជ្រៀតជ្រែកយ៉ាងខ្លាំងទៅនឹងសមត្ថភាពរបស់អ្នក ក្នុងដំណើរការរាល់ថ្ងៃ **ហើយ** រោគសញ្ញាមិនមានជាប់ទាក់ទងទៅនឹង ការប្រើប្រាស់មិនត្រឹមត្រូវនូវជាតិសុរា រឺថ្នាំញៀន។ ប្រសិនបើនេះជាករណី អ្នកគួរតែពិចារណាទាក់ទងគំរោងសុខភាពផ្លូវចិត្តក្នុងតំបន់របស់អ្នក។

អ្នកជំនាញមកពី MHP នឹងកំណត់ថាតើអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេសពី MHP ដែររឺទេ។ ប្រសិនបើអ្នកជំនាញ សំរេចថាអ្នកមិនត្រូវការនូវសេវាសុខភាពផ្លូវចិត្តឯកទេសទេ អ្នកអាចនៅតែត្រូវបានព្យាបាលដោយវេជ្ជបណ្ឌិតធម្មតារបស់អ្នក រឺអ្នកផ្តល់សេវាថែទាំព្យាបាលបឋម រឺអ្នកអាចប្តឹងឧទ្ធរណ៍ការសំរេចចិត្តនោះ (សូមមើលទំព័រទី 23)។

អ្នកអាចត្រូវការជំនួយ ប្រសិនបើអ្នកមានចំណុចដូចខាងក្រោមជាច្រើន:

- មានភាពថមថយទឹកចិត្ត (រឺមានអារម្មណ៍អស់សង្ឃឹម រឺខ្វះការជួយយកអាសារ រឺមិនមានតំលៃ រឺបាក់ទឹកចិត្តយ៉ាងខ្លាំង) ភាគច្រើនក្នុងពេលនៃថ្ងៃ ស្ទើរតែរៀងរាល់ថ្ងៃ
- បាត់បង់ការចាប់អារម្មណ៍ ក្នុងសកម្មភាពដែលគួរអោយរីករាយ
- ទំងន់ចុះ រឺកើនច្រើនជាង 5% ក្នុងមួយខែ
- ការដេកច្រើនហួសហេតុ រឺកង្វះដំណេក

ប្រសិនបើអ្នកគិតថាអ្នកមានទូវសញ្ញាទាំងឡាយដែលរាយនាម ហើយគិតថាមានរបៀបនេះជាច្រើនសប្តាហ៍ អ្នកអាចត្រូវបានវាយតំលៃដោយអ្នកជំនាញបាន។ ប្រសិនបើអ្នកមិនច្បាស់លាស់ អ្នកគួរតែសួរវេជ្ជបណ្ឌិតគ្រួសាររបស់អ្នក រឺអ្នកជំនាញខាងថែទាំសុខភាពដទៃទៀត ដើម្បីទទួលយោបល់របស់គេ។

- ចលនាផ្លូវកាយមានភាពយឺតពេក រឺលើសលប់ជ្រុល
- ហត់រីអស់កំលាំងស្ទើរតែរៀងរាល់ថ្ងៃ
- មានអារម្មណ៏ថាគ្មានតំលៃ រឺទោសកំហុសលើសលប់ពេក
- មានការពិបាកក្នុងការគិត រឺការផ្តោតការយកចិត្តទុកដាក់ រឺការសំរេចចិត្ត
- តំរូវការដំណេកថយចុះ – មានអារម្មណ៏ថា " សំរាក (rested)" បន្ទាប់ពីការដេកតែពីរបីម៉ោងប៉ុណ្ណោះ
- គំនិត "ប្រណាំង (Racing)" មានល្បឿនលឿនពេកសំរាប់អ្នកក្នុងការទប់
- និយាយយ៉ាងលឿន ហើយមិនអាចឈប់និយាយ
- មានអារម្មណ៏ថាមនុស្ស " ទៅទីនោះដើម្បីចាំអ្នក " ('out to get you')
- លឺសូរ និងសំលេងដែលអ្នកដទៃមិនលឺ
- ឃើញអ្វីដែលមនុស្សដទៃទៀតមើលមិនឃើញ
- មិនអាចទៅធ្វើការ រឺទៅសាលា
- មិនខ្វល់ពីអនាម័យផ្ទាល់ខ្លួន (ភាពស្អាត)
- មានបញ្ហាផ្នែកទំនាក់ទំនងជិតស្និទ
- នៅឯកកោ រឺដកខ្លួនចេញពីមនុស្សដទៃ
- យំជាហឹកញាប់ ហើយដោយ "គ្មានហេតុផល"
- ខឹងជាញឹកញាប់ និង "ពុះកំហឹងឡើង" ដោយ "គ្មានហេតុផល"
- មានទំនោរអារម្មណ៏ធ្ងន់ធ្ងរ
- មានអារម្មណ៏រសាប់រសល់ និងព្រួយបារម្ភជាច្រើនលើកច្រើនសារ
- មានទូវអ្វីដែលអ្នកដទៃហៅថាចំលែក រឺអាកប្បកិរិយាប្លែក

តើសេវាអ្វីខ្លះដែលមាន?

ក្នុងនាមជាមនុស្សពេញវ័យនៅក្នុង Medi-Cal អ្នកអាចមានសិទ្ធិទទួលសេវាសុខភាពផ្លូវចិត្តជំនាញពី MHP។ MHPរបស់អ្នក ត្រូវបានតំរូវអោយជួយកំណត់ថាតើអ្នកត្រូវការសេវាទាំងនេះដែររឺទេ។ សេវាខ្វះ ក្នុងចំណោមសេវារបស់ MHPនៃតំបន់របស់អ្នក ត្រូវបានតំរូវអោយមាន ប្រសិនបើអ្នកត្រូវការវា រួមមាន:

សេវាសុខភាពផ្លូវចិត្ត – សេវាសុខភាពទាំងនេះ រួមមានសេវាព្យាបាលសុខភាពផ្លូវចិត្ត ដូចជាការពិគ្រោះយោបល់ រឺការព្យាបាលដោយប្រើចិត្តសាស្ត្រ ដែលត្រូវបានផ្តល់ដោយអ្នកឯកទេសខាងព្យាបាលផ្លូវចិត្ត អ្នកចិត្តសាស្ត្រ បុគ្គលិកសង្គមកិច្ចនៅតាមគ្លីនិកដែលមានអាជ្ញាប័ណ្ណ ការព្យាបាលដោយការរៀបការនិងគ្រួសារ និងគិលានុបដ្ឋាយិកាផ្នែកព្យាបាលផ្លូវចិត្ត។ សេវានៃគំរោងសុខភាពផ្លូវចិត្ត អាចត្រូវបានហៅផងដែរថាជាការធ្វើនិតិសម្បទា រឺជាសេវាធ្វើអោយរើបសះស្បើយឡើងវិញ ហើយពួកគេជួយមនុស្សម្នាក់ដែលមានជំងឺផ្លូវចិត្ត អោយអភិវឌ្ឍន៏ជំនាញចំលងធ្វើតាមសំរាប់ការរស់នៅជាប្រចាំថ្ងៃ។ សេវាសុខភាពផ្លូវចិត្ត

អាចត្រូវបានផ្តល់អោយ នៅក្នុងគ្លីនិក ឬការិយាល័យអ្នកផ្តល់សេវា តាមទូរស័ព្ទ ឬនៅក្នុងផ្ទះ ឬតាមកន្លែងផ្សេងៗទៀតក្នុងសហគមន៍។

- សេវាទាំងនេះ ជួនកាលអាចត្រូវបានគេផ្តល់អោយទៅមនុស្សម្នាក់ម្តង (ការព្យបាល ឬការធ្វើនិតិសម្បទាដោយបុគ្គល) ពីរនាក់ ឬច្រើននៅពេលតែមួយ (ការព្យបាលជាក្រុម ឬសេវាធ្វើនិតិសម្បទាជាក្រុម) និងដល់គ្រួសារ (ការព្យាបាលជាគ្រួសារ)។

សេវាគាំទ្រផ្នែកឱសថ – សេវាទាំងនេះ រួមមាន ករចេញវេជ្ជបញ្ជា ការដឹកនាំគ្រប់គ្រង ការចែក និងការត្រួតពិនិត្យឱសថព្យាបាលផ្លូវចិត្ត។ ការគ្រប់គ្រងឱសថដោយអ្នកជំនាញខាងព្យបាលផ្លូវចិត្ត និង ការអប់រំ និងការត្រួតពិនិត្យដែលទាក់ទងនឹងឱសថផ្លូវចិត្ត។ សេវាគាំទ្រផ្នែកឱសថ អាចត្រូវបានផ្តល់អោយនៅក្នុងគ្លីនិកមួយ ឬការិយាល័យរបស់អ្នកផ្តល់សេវា តាមទូរស័ព្ទ ឬនៅក្នុងផ្ទះ ឬតាមទីកន្លែងផ្សេងៗដទៃទៀតក្នុងសហគមន៍។

ការគ្រប់គ្រងករណីគោលដៅ – សេវានេះ ជួយជាមួយនឹងការទទួលសេវាវេជ្ជសាស្ត្រ អប់រំ សង្គម មុនជំនាញវិជ្ជាជីវៈ ធ្វើនិតិសម្បទា ឬសេវាសហគមន៍ដទៃផ្សេងទៀត នៅពេលដែលសេវាទាំងនេះ អាចមានភាពលំបាកសំរាប់មនុស្សដែលមានជំងឺផ្លូវចិត្ត ធ្វើដោយផ្ទាលខ្លួនរបស់ពួកគេ។ ការគ្រប់គ្រងករណីគោលដៅ រួមមានករបង្កើតផែនការ ការទំនាក់ទំនង ការសំរបសំរួល និងការណែនាំ ការផ្តល់សេវាត្រួតពិនិត្យ ដើម្បីធានាអោយបានថា សិទ្ធិចេញចូលរបស់មនុស្សនោះ ចំពោះសេវា និងប្រព័ន្ធផ្តល់សេវា និងការត្រួតពិនិត្យដំនើរការវិវត្តន៍របស់មនុស្សនោះ។

ការធ្វើអន្តរាគមន៍ផ្នែកវិបត្តិ និងការធ្វើអោយវិបិត្តិមានភាពនឹងនរ – សេវាទាំងនេះ ផ្តល់នូវការព្យាបាលសុខភាពផ្លូចិត្ត សំរាប់មនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត ដែលមិនអាចរង់ចាំការណាត់ជួបដែលគ្រោងទុកធម្មតា។ ការធ្វើអន្តរាគមន៍ចំពោះវិបត្តិ អាចមានរយៈពេលរហូតដល់ប្រាំបីម៉ោង ហើយអាចត្រូវបានផ្តល់អោយនៅក្នុងគ្លីនិក ឬការិយាល័យអ្នកផ្តល់សេវា តាមទូរស័ព្ទ ឬនៅក្នុងផ្ទះ ឬតាមកន្លែងនានាក្នុងសហគមន៍។ ការធ្វើអោយវិបិត្តិមានភាពនឹងនរ អាចមានរយៈពេលរហូតដល់ 20 ម៉ោង ហើយត្រូវបានផ្តល់អោយនៅតាមគ្លីនិក ឬទីកន្លែងនៃអាគារផ្សេងទៀត។

សេវាព្យាបាលតាមលំនៅដ្ឋាន – សេវាទាំងនេះ ផ្តល់នូវការព្យាបាលសុខភាពផ្លូវចិត្តសំរាប់មនុស្សដែលកំពុងរស់នៅក្នុងអាគារ ដែលមានអាជ្ញាប័ណ្ណ ដែលផ្តល់នូវសេវាលំនៅដ្ឋានសំរាប់មនុស្សដែលមានជំងឺផ្លូវចិត្ត។ សេវាទាំងនេះមាន 24 ម៉ោង ក្នុងមួយថ្ងៃ ប្រាំពីថ្ងៃក្នុងមួយសប្តាហ៍។ Medi-Cal មិនរ៉ាប់រងលើការចំណាយថ្លៃបន្ទប់ និង ម្ហូបអាហារ នៅក្នុងអាគារដែលផ្តល់សេវាព្យាបាលដល់លំនៅដ្ឋានសំរាប់មនុស្សពេញវ័យ។

សេវាព្យាបាលដល់លំនៅដ្ឋានចំពោះវិវត្តិ – សេវាទាំងនេះ ផ្តល់នូវការព្យាបាលសុខភាពផ្លូវចិត្តសំរាប់ មនុស្ស ដែលមានបញ្ហា ឬវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ប៉ុន្តែដែលមិនស្តែងអោយឃើញនូវភាពស្មុគ្រស្មាញផ្នែក វេជ្ជសាស្ត្រ ដែលទាមទារនូវការថែទាំឡើយ។ សេវាមានរយៈពេល 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ នៅក្នុងអាគារដែលមានអាជ្ញាប័ណ្ណ

__MHP__ នៃតំបន់និមួយៗ អាចមានមធ្យោបាយខុសៗគ្នាបន្តិចបន្តួច ក្នុងការកធ្វើអោយសេវាទាំងនេះមានអាចរកបានដច្នេះ សូមពិនិត្យមើលផ្នែកខាងមុខ នៃសៀវភៅណែនាំនេះ ដើម្បីរកពត៌មានបន្ថែម ឬទាក់ទងទៅលេខឥតគិតថ្លៃរបស់ __MHP__ របស់អ្នកដើម្បីសួររកពត៌មានបន្ថែមទៀត។

ដែលផ្តល់នូវសេវាចំពោះផ្នែកវិបិត្តអោយស្នាក់នៅ ដល់មនុស្សដែលមានជំងឺផ្លូវចិត្ត។ Medi-Cal មិនធានារ៉ាប់រង លើការចំណាយថ្លៃបន្ទប់ និងម្ហូបអាហារឡើយ ដើម្បីអោយស្ថិតនៅក្នុងអាគារដែលផ្តល់នូវសេវាព្យាបាលអោយស្នាក់នៅ។

ការបង្កើនការព្យាបាលនៃថ្ងៃ – នេះជាកម្មវិធីនៃការព្យាបាលសុខភាពផ្លូវចិត្ត ដែលមានការរៀបចំ ដែលត្រូវបានផ្តល់អោយ ដល់ក្រុមមនុស្សដែលផ្ទុយទៅវិញ អាចត្រូវការស្នាក់ក្នុងមន្ទីរពេទ្យ រឺអាគារសំរាប់ការថែទាំ 24-ម៉ោងទៀត។ កម្មវិធីនោះមានរយៈពេល យ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃ។ មនុស្សអាចទោកាន់ផ្ទះសំបែងផ្ទាល់ខ្លួនរបស់គេនៅពេលយប់។ កម្មវិធីនោះ រួមមានសកម្មភាពបង្កើតជំនាញ (ជំនាញជីវិត ការសំរបចូលក្នុងសង្គមជាមួយមនុស្សដទៃទៀត ។ល។) និងការព្យាបាលផ្សេងៗ (សិល្បៈ ការកាំសាន្ត តន្ត្រី ការរាំរែក ។ល។) ព្រមទាំងការព្យាបាលដោយចិត្តសាស្ត្រផងដែរ។

ការធ្វើនិតិសម្បទានៃថ្ងៃ – នេះជាកម្មវិធីព្យបាលសុខភាពផ្លូវចិត្តដែលមានការរៀបចំជារចនាសម្ព័ន្ធ ដើម្បីបង្កើន រក្សា រឺការធ្វើនិតិសម្បទាឡើងវិញ នូវភាពឯករាជ្យ និងការធ្វើអោយមានដំណើរការប្រព្រឹត្តទៅ។ កម្មវិធី ត្រូវបានរៀបចំដើម្បីជួយមនុស្សដែលមានជំងឺផ្លូវចិត្ត រៀន និងអភិវឌ្ឍន៍ជំនាញផ្សេងៗ។ កម្មវិធី មានរយៈពេលយ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃ។ មនុស្សទៅកាន់ផ្ទះផ្ទាល់ខ្លួនរបស់គេនៅពេលយប់។ កម្មវិធីនោះ រួមមានសកម្មភាពបង្កើតជំនាញ (ជំនាញជីវិត ការចូលប្រឡូកសំរបនឹងសង្គម ជាមួយមនុស្សដទៃ ។ល។) និងការព្យាបាលផ្សេងៗ (សិល្បៈ ការកំសាន្ត តន្ត្រី របាំ ។ល។)។

សេវាមន្ទីរពេទ្យសំរាប់អ្នកជំងឺដែលមានជំងឺផ្លូវចិត្ត – ទាំងនេះ ជាសេវាដែលត្រូវបានផ្តល់អោយ ក្នុងមន្ទីរពេទ្យមួយដែលមនុស្សស្នាក់នៅមួយយប់ ដោយសារតែមាននូវភាពបន្ទាន់ផ្នែកផ្លូវចិត្ត រឺដោយសារតែមនុស្ស ត្រូវការនូវការព្យាបាលសុខភាពផ្លូវចិត្ត ដែលអាចត្រូវបានធ្វើឡើងតែនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះ។

សេវានៃអាគារសុខភាពផ្លូវចិត្ត – ទាំងនេះ គឺជាសេវាដែលត្រូវបានផ្តល់អោយ នៅក្នុងកន្លែងមួយដែលរៀបចំដូចមន្ទីរពេទ្យ ដែលមនុស្សស្នាក់នៅមយយយប់ ដោយសារតែ មាននូវភាពបន្ទាន់ផ្នែកផ្លូវចិត្ត រឺដោយសារតែមនុស្ស ត្រូវការនូវការព្យាបាលសុខភាពផ្លូវចិត្ត ដែលអាចត្រូវបានធ្វើឡើងតែនៅក្នុងកន្លែងដែលរៀបចំដូចមន្ទីរពេទ្យប៉ុណ្ណោះ។ អាគារសុខភាពផ្លូវចិត្ត ត្រូវតែមាននូវការរៀបចំ ជាមួយនឹងមន្ទីរពេទ្យ រឺគ្លីនិកដែលនៅក្បែរនោះ ដើម្បីឆ្លើយតបតាម តំរូវការនៃការថែទាំសុខភាពផ្លូវកាយរបស់មនុស្សនោក្នុងអាគារ។

សេវាទាំងនេះ ក៏រួមមានផងដែរ នូវការងារដែលអ្នកផ្តល់សេវាធ្វើ ពិតជាជួយធ្វើអោយសេវាមានដំណើរការកាន់តែប្រសើរ សំរាប់អ្នកដែលទទួលសេវា។ អ្វីៗទាំងនេះ រួមមានការវាយតំលៃ ដើម្បីពិនិត្យមើលថាតើអ្នកត្រូវការសេវាដែររឺទេ និងថាតើសេវានោះមានដំណើរការរឺទេ។ ការបង្កើតគំរោងដើម្បីសំរេចថាតើគោលដៅទាំងឡាយនៃការព្យបាលសុខភាពផ្លូវចិត្តរបស់បុគ្គលនោះ

និងសេវាជាលាក់ដែលនឹងត្រូវបានផ្តល់អោយ។ “ស្របគ្នា” ដែលមានន័យថា ធ្វើការជាមួយសមាជិកគ្រួសារ និងមនុស្សសំខាន់ៗ នៅក្នុងជីវិតរបស់មនុស្សនោះ (ប្រសិនបើមនុស្សនោះផ្តល់នូវការអនុញ្ញាត) ប្រសិនបើវានឹងជួយមនុស្សបង្កើន រឺរក្សាស្ថានភាពសុខភាពផ្លូវចិត្ត របស់គាត់ រឺនាង។

កុមារ កំលោះក្រមុំ និងមនុស្សក្មេងវ័យ



តើខ្ញុំដឹងថានៅពេលណាកុមារត្រូវការជំនួយដោយរបៀបណា?

សំរាប់កុមារពីកំណើតដល់អាយុ 5 ឆ្នាំ

មាននូវសញ្ញាដែលអាចបង្ហាញពីតំរូវការសេវាសុខភាពផ្លូវចិត្តឯកទេស។ ទាំងនេះរួមមាន:

- ឪពុកម្តាយដែលមានអារម្មណ៍ហួសហេតុ ដោយធ្វើជាឪពុកម្តាយ រឺដែលមានបញ្ហាសុខភាពផ្លូវចិត្ត
- ប្រភពសំខាន់នៃស្រេស្តនៅក្នុងគ្រួសារ ដូចជាការលែងលះ រឺការស្លាប់ នៃសមាជិកគ្រួសារ
- ការប្រើប្រាស់សុរា រឺថ្នាំប្រភេទដទៃទៀត ដោយនរណាម្នាក់នៅក្នុងផ្ទះ
- អាកប្បកិរិយាពិបាក រឺមិនធម្មតាដោយកុមារ
- អំពើហឹង្សា រឺការរំខាននៅក្នុងផ្ទះ

ប្រសិនបើស្ថានភាពណាមួយក្នុងចំណោមស្ថានភាពខាងលើ មានវត្តមាននៅក្នុងផ្ទះដែលកុមារមានអាយុរហូតដល់ 5 ឆ្នាំកំពុងរស់នៅ សេវាសុខភាពផ្លូវចិត្តឯកទេសអាចត្រូវបានត្រូវការ។ អ្នកត្រូវតែទាក់ទង MHPនៃតំបន់របស់អ្នកដើម្បីស្នើសុំពត៌មានបន្ថែម និងការវាយតំលៃសំរាប់សេវាទាំងឡាយដើម្បីមើលថាតើ MHP អាចជួយអ្នករឺក៏អត់។

ចំពោះកុមារដែលមានវ័យត្រូវចូលសាលា តារាងផ្ទៀងផ្ទាត់ខាងក្រោមនេះ រួមមានសញ្ញាខ្លះ ដែលអាចជួយអ្នកសំរេចថាតើ កូនរបស់អ្នក នឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខភាពផ្លូវចិត្តរឺអត់។ កូនរបស់អ្នក:

- ការបង្ហាញនូវការប្រែប្រួលមិនធម្មតានៅក្នុងផ្លូវមនោសញ្ចេតនា រឺអាកប្បកិរិយា
- មិនមានមិត្តភក្តិ រឺមានការលំបាកក្នុងការចុះសំរុងជាមួយក្មេងដទៃ
- កំពុងតែរៀនយ៉ាងខ្សោយនៅក្នុងសាលា ខាកខានមិនបានចូលសាលា ជាញឹកញាប់ រឺមិនចង់ចូលសាលា
- មានជំងឺនិងគ្រោះថ្នាក់តិចតួចច្រើន
- មានការភ័យខ្លាចខ្លាំង
- មានភាពចចេស (aggressive)
- មិនចង់ឃ្លាតឆ្ងាយពីអ្នក
- មានការយល់សប្តិ៍ដែលរំខានជាច្រើន
- មានការលំបាកក្នុងការដេកអោយលក់ ដើបពីដំណេកក្នុងពេលយប់ រឺទទូចចង់ដេកជាមួយអ្នក
- បដិសេធភ្លាមៗមិនព្រមនៅម្នាក់ឯងជាមួយនឹងសមាជិកគ្រួសារខ្លះ រឺមិត្តភក្តិ រឺមានសកម្មភាព យ៉ាងរំខាន នៅពេលដែលសមាជិកគ្រួសារ រឺមិត្តភក្តិមានវត្តមាន
- ស្តែងអោយឃើញនូវការប៉ះពាល់ដោយមិនសមរម្យ រឺមានកាយវិការទាក់ទិននឹងផ្លូវភេទ ខុសធម្មតា រឺពាក្យសំដី

- ក្លាយជាដកខ្លួន រឺខឹងភ្លាមៗ
- បដិសេធមិនព្រមបរិភោគ
- មានទឹកភ្នែកជាញឹកញាប់

អ្នកអាចទាក់ទង MHP នៃតំបន់របស់អ្នក ដើម្បីធ្វើការវាយតំលៃសំរាប់កូនរបស់អ្នក ប្រសិនបើអ្នកមានអារម្មណ៍ថាគាត់ រឺនាងកំពុងតែមានសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងឡាយខាងលើ។ ប្រសិនបើកូនរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល Medi-Cal និងការវាយតំលៃរបស់ MHP បង្ហាញថា សេវាសុខភាពផ្លូវចិត្តឯកទេសដែលត្រូវបានធានារ៉ាប់រងដោយ MHP ត្រូវបានត្រូវការ MHP នឹងរៀបចំចាត់ចែងសំរាប់កុមារ ដើម្បីទទួលសេវាទាំងនោះ។

តើខ្ញុំដឹងថានៅពេលណាដែលកំលោះក្រមុំ រឺមនុស្សវ័យក្មេងត្រូវការជំនួយដោយរបៀបណា?

កំលោះក្រមុំ (អាយុពី 12-18 ឆ្នាំ) ស្ថិតនៅក្រោមសម្ពាធជាច្រើន ដែលប្រឈមមុខទៅនឹងវ័យជំទង់។ មនុស្សវ័យក្មេងទាំងឡាយដែលមានអាយុពី 18 ទៅ 21 គឺជាវ័យដែលប្តូរផ្លាស់ ដែលមានសម្ពាធតែមួយគត់ផ្ទាល់ខ្លួនរបស់គេ និង ដោយសារតែពួកគេជាមនុស្សពេញវ័យតាមផ្លូវច្បាប់ អាចស្វែងរកសេវានានាក្នុងនាមជាមនុស្សពេញវ័យ។

*មនុស្សវ័យក្មេងដែលមានអាយុ ពី **18** ទៅ**21**ឆ្នាំ គួរតែមើលក្នុងតារាងទោខាងស្តាំ និង តារាងនៃច្បាប់សំរាប់មនុស្សពេញវ័យ នៅលើទំព័រ ទី **9** និង**10** ដើម្បីជួយសំរេចថាតើសេវាសុខភាពផ្លូវចិត្តអាចត្រូវបានត្រូវការរឺទេ។*

អាកប្បកិរិយាដែលមិនធម្មតាខ្លះដែលប្រព្រឹត្តដោយមនុស្សដែលមានវ័យកំលោះក្រមុំ រឺក្មេងវ័យ អាចមានការទាក់ទងទៅនឹងការប្តូរផ្លាស់ផ្លូវចិត្ត និងផ្លូវកាយដែលកើតឡើង នៅពេលដែលពួកគេក្លាយជាមនុស្សពេញវ័យ។ មនុស្សពេញវ័យក្មេង កំពុងតែបង្កើតនូវអត្ថន័យនៃអត្តសញ្ញាណខ្លួនឯង និងប្តូរផ្លាស់ពីការពឹងពាក់លើឪពុកម្តាយ ទៅជាឯករាជ្យ។ ឪពុកម្តាយ រឺមិត្តភក្តិដែលពាក់ព័ន្ធ រឺមនុស្សវ័យក្មេង អាចមានបញ្ហាលំបាកក្នុងការសំរេចរវាងអ្វីជា “អាកប្បកិរិយាធម្មតា” និងតើអ្វីជាសញ្ញានៃបញ្ហាផ្លូវចិត្ត រឺផ្លូវអារម្មណ៍ ដែលទាមទារនូវការជួយលក្ខណៈជំនាញ។

ជំងឺផ្លូវចិត្តខ្លះ អាចចាប់ផ្តើមនៅក្នុងអាយុរវាង 12 និង 21។ តារាងផ្ទៀងផ្ទាត់ខាងក្រោម គួរតែជួយអ្នកសំរេចថាតើ កំលោះក្រមុំម្នាក់ទាមទារជំនួយរឺក៏អត់។ ប្រសិនបើសញ្ញាថេច្រើនជាងមួយ មានវត្តមាន រឺបន្តក្នុងរយៈពេលយូរ វាអាចបញ្ជាក់នូវបញ្ហាដែលកាន់តែធ្ងន់ធ្ងរដែលទាមទារនូវជំនួយជំនាញ។ ប្រសិនបើកំលោះក្រមុំនោះ:

- ដកខ្លួនចេញពីគ្រួសារ មិត្តភក្តិ និង/រឺ សកម្មភាពធម្មតា
- ឆ្លងកាត់ការបដិសេធដោយមិនមានហេតុផលនៅក្នុងកិច្ចការសាលា
- ធ្វេសប្រហែសចំពោះរូបរាងខាងក្រៅរបស់គេ
- បង្ហាញងោយឃើញនូវការប្តូរផ្លាស់ទំងន់គួរអោយកត់សំគាល់
- រត់ចោលផ្ទះ
- មានអាកប្បកិរិយាហឹង្សា រឺច្រឡោងខាមយ៉ាងខ្លាំង

- មានរោគសញ្ញាផ្លូវកាយដែលគ្មានជំងឺដែលអាចប្រមើលបាន
- ប្រើប្រាស់ថ្នាំញៀន រឺសុរាមិនត្រឹមត្រូវ

ឪពុកម្តាយ រឺអ្នកថែទាំកំលោះក្រមុំ រឺកំលោះក្រមុំ អាចទាក់ទងមក MHP នៃតំបន់របស់អ្នក ដើម្បីទទួលការវាយតំលៃ ដើម្បីពិនិត្យមើលថាតើ សេវាសុខភាពផ្លូវចិត្តត្រូវបានត្រូវការរឺអត់។ ក្នុងនាមជាមនុស្សពេញវ័យ មនុស្សវ័យក្មេង (ដែលមានអាយុពី 18 ទៅ 20) អាចស្នើសុំពី MHP នូវការវាយតំលៃ។ ប្រសិនបើកំលោះក្រមុំ រឺមនុស្សវ័យក្មេង មានលក្ខណៈសម្បត្តិ ក្នុងការទទួល Medi-Cal ហើយការវាយតំលៃរបស់ MHP បង្ហាញថាសេវាសុខភាពផ្លូវចិត្តឯកទេសដែលរ៉ាប់រងដោយ MHP ត្រូវបានត្រូវការ MHP នឹងរៀបចំអោយកំលោះក្រមុំ រឺមនុស្សក្មេងវ័យ ទទួលនូវសេវាផ្សេងៗ។

តើសេវាអ្វីដែលអាចមាន?

សេវាដដែលទាំងឡាយ ដែលមានសំរាប់មនុស្សពេញវ័យ ក៏មានសំរាប់កុមារ កំលោះក្រមុំ និងមនុស្សវ័យក្មេងផងដែរ។ សេវាទាំងឡាយដែលមាន គឺសេវាសុខភាពផ្លូវចិត្ត សេវាគាំទ្រដល់ការផ្តល់ឱសថ ការគ្រប់គ្រងករណីគោលដៅ ការធ្វើអន្តរាគមន៍វិបត្តិ ការធ្វើអោយមានភាពនឹងនរផ្នែកវិបត្តិ ការបង្កើនការព្យាបាលពេលថ្ងៃ ការធ្វើនិតិសម្បទាឡើងវិញពេលថ្ងៃ សេវាព្យបាលមនុស្សពេញវ័យដោយអោយស្នាក់នៅ សេវាមន្ទីរពេទ្យសំរាប់អ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យផ្នែកផ្លូវចិត្ត និង សេវាអាគារសុខភាពផ្លូវចិត្ត។ MHP ក៏រ៉ាប់រងផងដែរនូវសេវាពិសេសបន្ថែមដទៃទៀតដែលមានសំរាប់កុមារ កំលោះក្រមុំ និងមនុស្សវ័យក្មេងដែលមានអាយុ 21ឆ្នាំ និងមានសិទ្ធទទួលMedi-Cal យ៉ាងពេញលេញ (Medi-Cal ពេញលេញ (full-scope Medi-Cal) មានន័យថា ជាការរ៉ាប់រងរបស់ Medi-Cal ដែលមិនមានការរិត្បិតទៅលើប្រភេទនៃសេវាជាក់លាក់ណាមួយ ឧទាហរណ៍ សេវាបន្ទាន់តែប៉ុណ្ណោះ)។

MHP របស់តំបន់និមួយៗ អាចមានភាពខុសប្លែកគ្នារវាងការធ្វើអោយសេវាទាំងនេះមានអាចរកបាន ដូច្នេះ សូមពិគ្រោះយោបល់នឹងផ្នែកខាងមុខនៃសៀវភៅនេះ ដើម្បីរកមើលពត៌មានបន្ថែម រឺទាក់ទង MHP របស់អ្នក តាមទូរស័ព្ទលេខឥតគិតថ្លៃ ដើម្បីសួររកពត៌មានបន្ថែម។

តើមានសេវាពិសេសសំរាប់កុមារ កំលោះក្រមុំ និងមនុស្សពេញវ័យដែលមានវ័យក្មេងដែររឺទេ?

មានសេវាពិសេសៗ ដែលមានពី MHP សំរាប់កុមារ កំលោហក្រមុំ និងមនុស្សវ័យក្មេង ដែលហៅថា ការពិនិត្យតាមរយកាល និងតំណាក់កាលដំបូង (Early and Periodic Screening), ការធ្វើរោគសញ្ញា (Diagnosis), និង ការព្យាបាល (Treatment), សេវាសិខភាបផ្លូវចិត្តឯកទេសបន្ថែម (EPSDT)។ សេវា EPSDT ទាំងនេះ រួមមានសេវាមួយ ដែលហៅថាសេវាអាកប្បកិរិយាដែលត្រូវព្យាបាល (Therapeutic Behavioral Services) រឺ TBS ដែលត្រូវបានបកស្រាយនៅក្នុងផ្នែកបន្ទាប់ និងរួមទាំងសេវាថ្មីៗផងដែរ ពីព្រោះថា ពួកគេត្រូវបានបញ្ជាក់អត្តសញ្ញាណដោយ

អ្នកជំនាញការខាងព្យាបាលជំងឺផ្លូវចិត្តជាសេវាដែលពិតជាមានប្រសិទ្ធភាព។ សេវាទាំងនេះ មានពី MHP ប្រសិនបើពួកវាត្រូវបានត្រូវការ ដើម្បីកែតំរូវ រឺ ធ្វើអោយប្រសើរឡើង (កែលំអ) សុខភាពផ្លូវចិត្ត សំរាប់មនុស្សដែលមានអាយុក្រោម 21 ដែលមានសិទ្ធិទទួល Medi-Cal ពេញលេញ និងមានជំងឺផ្លូវចិត្ត ដែលត្រូវបានធានារ៉ាប់រងដោយ MHP (សូមមើលទំព័រទី 10 ដើម្បីបានពត៌មានបន្ថែម ស្តីពីជំងឺផ្លូវចិត្តដែលត្រូវបានធានារ៉ាប់រងដោយ MHP)។

MHP មិនត្រូវបានទាមទារដើម្បីផ្តល់អោយនូវសេវាទាំងនេះទេ ប្រសិនបើ MHP សំរេចថាសេវាមយយក្នុងចំណោមសេវាធម្មតាទាំងឡាយដែលរ៉ាប់រងដោយ MHP មានអាចរកបាន និងនឹងឆ្លើយតបតាមតំរូវការរបស់កុមារ កំលោះក្រមុំ រឺមនុស្សក្មេងវ័យ។ MHP ក៏មិនត្រូវបានទាមទារផងដែរអោយផ្តល់សេវាពិសេសទាំងនេះនៅតាមទីតាំងនៅផ្ទះ រឺក្នុងសហគមន៍ ប្រសិនបើ MHP កំណត់ថា ការចំណាយសរុបនៃការផ្តល់សេវាទាំងនេះនៅផ្ទះ រឺក្នុងសហគមន៍ មានភាពធំធេងជាង
ការចំណាយសរុបនៃការផ្តល់សេវាដែលស្រដៀងគ្នានៅតាមកំរិតស្ថាប័នថៃទាំសមស្រប។

តើអ្វីជាសេវាចំពោះអាកប្បកិរិយាដែលត្រូវការព្យាបាល (Therapeutic Behavioral Services (TBS))?

TBS គឺជាប្រភេទនៃសេវាសុខភាពផ្លូវចិត្តឯកទេស តាមរយៈ MHP នៃតំបន់និមួយៗ ប្រសិនបើអ្នកបញ្ហាផ្លូវអារម្មណ៏ធ្ងន់ធ្ងរ។ អ្នកត្រូវតែមានអាយុក្រោម 21 ឆ្នាំ និងមាន Medi-Cal ពេញលេញ ដើម្បីទទួល TBS។

- ប្រសិនបើអ្នកកំបុងរស់នៅក្នុងផ្ទះ បុគ្គលដែលជាបុគ្គលិក TBS អាចធ្វើការម្នាក់ទល់ម្នាក់ជាមួយអ្នក ដើម្បីកាត់បន្ថយបញ្ហាអាកប្បកិរិយាធ្ងន់ធ្ងរ ដើម្បីព្យាយាមរារាំងអ្នកមិនអោយទៅកាន់កំរិតនៃការថៃទាំខ្ពស់ជាងនេះ ដូចជាផ្ទះជាក្រុមសំរាប់កុមារ កំលោះក្រមុំ និងមនុស្សវ័យក្មេងដែលមានបញ្ហាផ្លូវអារម្មណ៏ធ្ងន់ធ្ងរខ្លាំង។
- ប្រសិនបើអ្នកកំពុងរស់នៅក្នុងផ្ទះជាក្រុមសំរាប់កុមារ កំលោះក្រមុំ និងមនុស្សវ័យក្មេងដែលមានបញ្ហាផ្លូវអារម្មណ៏ធ្ងន់ធ្ងរ បុគ្គលដែលជាបុគ្គលិក TBS អាចធ្វើការជាមួយអ្នក ដើម្បីអោយអ្នកអាចធ្វើដំណើរទៅកាន់កំរិតថៃទាំដែលទាបជាង ដូចជាផ្ទះសំរាប់ចិញ្ចឹមបីបាច់ រឺត្រឡប់ទៅផ្ទះ។ TBS នឹងជួយអ្នក និងគ្រួសាររបស់អ្នក អ្នកថៃទាំ និងអាណាព្យាបាល សិក្សាពីវិធីថ្មីៗនៃការគ្រប់គ្រងអាកប្បកិរិយាដែលមានបញ្ហា និងរបៀបផ្សេងៗនៃការបង្កើតប្រភេទអាកប្បបកិរិយាដែលនឹងអនុញ្ញាតិអោយអ្នកមានជោគជ័យ។ អ្នក បុគ្គលជាបុគ្គលិក TBS និងគ្រួសាររបស់អ្នក អ្នកថៃទាំ រឺអាណាព្យាបាល នឹងធ្វើការជាមួយគ្នាយ៉ាងខ្លាំងក្លាក្នុងរយៈពេលមួយយ៉ាងខ្លី រហូតទាល់តែអ្នកលែងត្រូវការ TBS។ អ្នកនឹងមានគំរោង TBS នដែលនឹងនិយាយថាតើអ្វីដែលអ្នក គ្រួសាររបស់អ្នក អ្នកថៃទាំ រឺអាណាព្យាបាល និងបុគ្គលជាបុគ្គលិក TBS នឹងធ្វើក្នុងអំឡុង TBS, ហើយនៅពេលណា និងកន្លែងណាដែល TBS នឹងកើតឡើង។ បុគ្គលជាបុគ្គលិក

TBS អាចធ្វើការជាមួយអ្នក
នៅតាមកន្លែងជាច្រើនដែលអ្នកទំនងជាត្រូវការទទួលជំនួយជាមួយនឹងអាកប្បកិរិយាដែលមានបញ្ហា។ នេះរួមមាន ផ្ទះរបស់អ្នក ផ្ទះសំរាប់ចិញ្ចឹមបីបាច់ ផ្ទះនៅជាក្រុម សាលារៀន កម្មវិធីព្យាបាលនៅថ្ងៃ និងតំបន់ដទៃទៀតនៅក្នុងសហគមន៍។

តើនរណាអាចទទួល TBS?

អ្នកអាចទទួល TBS ប្រសិនបើអ្នកមាន Medi-Cal ពេញលេញ មានអាយុក្រោម 21 ឆ្នាំ មានបញ្ហាផ្លូវអារម្មណ៍ធ្ងន់ធ្ងរ និង:

- រស់នៅក្នុងផ្ទះនៅជាក្រុមសំរាប់កុមារ កំលោះក្រមុំ និងមនុស្សវ័យក្មេង ដែលមានបញ្ហាផ្លូវអារម្មណ៍យ៉ាងខ្លាំង។ [ផ្ទះជាក្រុមទាំងនេះ ជួនកាលត្រូវបានគេហៅថា ផ្ទះជាក្រុមកំរិតចំណាត់ថ្នាក់អត្រា [Rate Classification Level (RCL)] 12, 13 រឺ 14] រឺ
- រស់នៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្តរបស់រដ្ឋ អាគារថែទាំដែលមានជំនាញខាងព្យាបាលសុខភាពផ្លូវចិត្ត រឺមជ្ឈមណ្ឌលធ្វើនិតិសម្បទាឡើងវិញ (Mental Health Rehabilitation Center) (កន្លែងទាំងនេះ ក៏ត្រូវបានគេហៅផងដែរថាស្ថាប័នសំរាប់ជំងឺផ្លូវចិត្ត រឺ IMDs) រឺ
- កំពុងមានគ្រោះថ្នាក់ក្នុងការដែលត្រូវតែរស់នៅក្នុងផ្ទះជាក្រុម (RCL 12, 13 រឺ 14) មន្ទីរពេទ្យសុខភាពផ្លូចិត្ត រឺ IMD; រឺ
- ត្រូវបានអោយសំរាកក្នុងមន្ទីរពេទ្យ ក្នុងអំឡុងពេល 2 ឆ្នាំកន្លងទៅ ដោយសារបញ្ហាសុខភាពផ្លូវចិត្តមានភាពបន្ទាន់។

តើមានអ្វីៗដែលត្រូវតែកើតឡើងចំពោះខ្ញុំដើម្បីទទួល TBS ដែររឺទេ ?

ប្រាដណាស់។ អ្នកត្រូវតែទទួល សេវាសុខភាពផ្លូវចិត្តឯកទេសផ្សេងៗដទៃទៀត។ TBS បន្ថែមទៅលើសេវាសុខភាពផ្លូវចិត្តឯកទេសដទៃទៀត។ វាមិនជំនួសសេវាដទៃតេ។ ដោយសារតែ TBS ជារយៈពេលខ្លី សេវាសុខភាបផ្លូវចិត្តឯកទេសដទៃ អាចត្រូវបានបន្ថែមដើម្បីរារាំងបញ្ហាមិនអោយត្រឡប់មកវិញ រឺកាន់តែដុនដាបទៅ បន្ទាប់ពី TBS បានចប់។

TBS មិនត្រូវបានផ្តល់អោយទេ ប្រសិនបើហេតុផលដែលវាត្រូវការគឺ:

- គ្រាន់តែដើម្បីជួយអ្នកអនុវត្តន៍តាមបញ្ជតុលាការ អំពីបញ្ហា
- គ្រាន់តែការពារសុវត្ថិភាពផ្លូវកាយរបស់អ្នក រឺសុវត្ថិភាពរបស់អ្នកដទៃ
- គ្រាន់តែធ្វើអោយអ្វីៗមានភាពកាន់តែងាយស្រួលសំរាប់គ្រួសាររបស់អ្នក អ្នកថែទាំ អាណាព្យាបាល រឺគ្រូបង្រៀន
- គ្រាន់តែជួយអ្នកជាមួយនឹងអាកប្បកិរិយាដែលមិនមែនជាផ្នែកមួយនៃបញ្ហាសុខភាពផ្លូវចិត្ត

អ្នកអាចទទួល TBS នៅពេលដែលអ្នកស្ថិតក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត IMD រឺត្រូវបានឃុំឃាំងក្នុងកន្លែងទីឃុំឃាំងអនិតិជន ដូចជាសាលាអនិតិជនជាដើម។ ប្រសិនបើអ្នកនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត រឺ IMD អ្នកអាចចាកចេញពីមន្ទីរពេទ្យផ្លូវចិត្ត រឺ IMD ឆាប់ជាងនេះ ពីព្រោះ TBS អាចត្រូវបានបន្ថែមទៅលើសេវាសុខភាពផ្លូវចិត្តឯកទេសដទៃទៀត ដើម្បីជួយអ្នកអោយស្នាក់នៅត្រឹមកំរិតថែទាំដែលទាបជាងមុន (ផ្ទះ ផ្ទះសំរាប់ចិញ្ចឹមបីបាច់ រឺផ្ទះសំរាប់នៅជាក្រុម)។

តើខ្ញុំអាចទទួល TBS ដោយរបៀបណា?

ប្រសិនបើអ្នកគិតថាអ្នកត្រូវការ TBS សូមសួរអ្នកឯកទេសខាងព្យាបាលផ្លូវចិត្តរបស់អ្នក អ្នកព្យាបាល រឺអ្នកគ្រប់គ្រងករណី ប្រសិនបើអ្នកមានរួចជាស្រេចហើយ រឺទាក់ទង MHP ហើយស្នើរសុំសេវាទាំងនេះ។ សមាជិកគ្រួសារ អ្នកថែទាំ អាណាព្យាបាល វេជ្ជបណ្ឌិត អ្នកចិតសាស្ត្រ អ្នកពិគ្រោះយោបល់ រឺបុគ្គលិកសង្គមកិច្ច អាចទូរស័ព្ទទៅសួររកពត៌មានស្ដីពី TBS រឺសេវាសុខភាពផ្លូវចិត្តឯកទេសដទៃទៀត សំរាប់អ្នក។ អ្នកអាចទូរស័ព្ទទៅ MHP ផងដែរ ហើយសួរអំពី TBS។

តើនរណាជាអ្នកសំរេច ប្រសិនបើខ្ញុំត្រូវការ TBS ហើយតើកន្លែងណាដែលខ្ញុំអាចទទួលពួកគេ?

MHP សំរេចថាតើអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេស ដែលរួមមាន TBS ជាដើម។ ជាធម្មតា បុគ្គលជាបុគ្គលិក MHP នឹងជជែកជាមួយអ្នក គ្រួសាររបស់អ្នក អ្នកថែទាំ រឺអាណាព្យាបាល និង អ្នកដទៃទាំងឡាយ ដែលសំខាន់ក្នុងជីវិតរបស់អ្នក និងនឹងបង្កើតនូវគំរោងមួយសំរាប់សេវាសុខភាព ផ្លូវចិត្តដែលអ្នកត្រូវការ ដែលរាប់បញ្ចូលទាំងគំរោង TBS ប្រសិនបើ TBS ត្រូវបានត្រូវការ។ ប្រការនេះ អាចត្រូវការកិច្ចប្រជុំមួយរឺពីរ ទល់មុខគ្នា ជួនកាល ច្រើនជាងនេះទៀត។ ប្រសិនបើអ្នកត្រូវការ TBS, នរណាម្នាក់នឹងត្រូវបានប្រគល់ការងារអោយជាបុគ្គលិក TBS របស់អ្នក។

តើអ្វីគួរតែស្ថិតក្នុងគំរោង TBS របស់ខ្ញុំ?

គំរោង TBS របស់អ្នក នឹងបញ្ជាក់ច្បាស់ពីអាកប្បកិរិយាដែលបង្កជាបញ្ហាដែលត្រូវការផ្លាស់ប្តូរ និងអ្វីដែលបុគ្គលិក TBS, អ្នក និងជួនកាលគ្រួសាររបស់អ្នក អ្នកថែទាំ រឺអាណាព្យាបាលនឹងធ្វើ នៅពេលដែល TBS កើតឡើង។ គំរោង TBS នឹងនិយាយថាតើប៉ុន្មានម៉ោងក្នុងមួយថ្ងៃ និងចំនួនថ្ងៃក្នុងមួយសប្តាហ៍ ដែលបុគ្គលិក TBS នឹងធ្វើការជាមួយអ្នក និងគ្រួសាររបស់អ្នក អ្នកថែទាំ និងអាណាព្យាបាល។ ចំនួនម៉ោងនៅក្នុងគំរោង TBS អាចស្ថិតក្នុងពេលថ្ងៃ ព្រឹកព្រលឹម ល្ងាច រឺយប់។ ចំនួនថ្ងៃនៅក្នុងគំរោង TBS អាចស្ថិតនៅពេលចុងសប្តាហ៍ ព្រមទាំងថ្ងៃធ្វើការផងដែរ។ គំរោង TBS នឹងនិយាយថាតើរយៈពេលប៉ុន្មានដែលអ្នកនឹងទទួលបាន TBS។ គំរោង TBS នឹងត្រូវបានពិនិត្យសើរើ ជាទៀងទាត់។ TBS អាចបន្តក្នុងរយបាពេលកាន់តែវែង ប្រសិនបើការពិនិត្យសើរើបង្ហាញថាអ្នក កំពុងតែមានភាពរីកចំរើន ប៉ុន្តែត្រូវការពេលវេលាបន្ថែមទៀត។

លក្ខណៈ ‘ ចាំបាច់ផ្នែកវេជ្ជសាស្ត្រ’

តើអ្វីជា “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” ហើយហេតុអ្វីបានជាវាសំខាន់?

ស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំងឡាយដែលចាំបាច់សំរាប់ការទទួលសេវាសុខភាពផ្លូវចិត្តឯកទេស តាមរយៈ MHP នៃតំបន់របស់អ្នក គឺអ្វីដែលត្រូវបានគេហៅថា ‘ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ’។ នេះមានន័យថា វេជ្ជបណ្ឌិត រឺអ្នកឯកទេសសុខភាពផ្លូវចិត្តដទៃទៀត នឹងនិយាយជាមួយអ្នកដើម្បីសំរេចថាតើមាននូវភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងថាតើអ្នកអាចត្រូវបានជួយដោយសេវាទាំងឡាយដែររឺទេ ប្រសិនបើអ្នកទទួលពួកវា។

ពាក្យថា “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” (‘medical necessity’) មានសារៈសំខាន់ ពីព្រោះវានឹងជួយសំរេចថាតើសេវាប្រភេទណាដែលអ្នកអាចទទួល និងថាតើអ្នកអាចទទួលវាដោយរបៀបណា។ ការសំរេចថាតើ “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” ជាផ្នែកដែលសំខាន់នៃដំណើរការទទួលសេវសុខភាពផ្លូវចិត្តឯកទេស។

តើអ្វីជាលក្ខណៈសម្បត្តិចំពោះ “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” ដើម្បីទទួលការរ៉ាប់រងលើសេវា សុខភាពផ្លូវចិត្តឯកទេស លើកលែងតែសេវាមន្ទីរពេទ្យ?

ជាផ្នែកមួយនៃការសំរេចថាតើអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេសរឺអត់នោះ MHP នៃតំបន់របស់អ្នក នឹងធ្វើការជាមួយអ្នកនិងអ្នកផ្តល់សេវារបស់អ្នក ដើម្បីសំរេចថាតើសេវាទាំងឡាយជា“ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ”ដូចដែលបានពន្យល់ខាងលើដែររឺទេ។ ផ្នែកនេះពន្យល់ថាតើ MHP នឹងធ្វើការសំរេចចិត្តនោះដោយ របៀបណា។ អ្នកមិនចាំបាច់ត្រូវដឹងថាតើអ្នកមានរោគសញ្ញា រឺ ជំងឺផ្លូវចិត្តជាក់លាក់រឺគ្មាន ដើម្បីសុំជំនួយនោះទេ។ MHP នឹង ជួយអ្នកអោយទទួលពត៌មាននេះ ព្រមជាមួយនឹង “ការវាយតំលៃ”។ មាននូវល័ក្ខខ័ណ្ឌចំនួនបួនដែល MHP នឹង ស្វែងរកដើម្បីសំរេចថាតើសេវាទាំងឡាយរបស់អ្នកជា “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” ហើយមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ដើម្បីទទួលការធានារ៉ាប់រងដោយ MHP រឺទេ:

1) អ្នកត្រូវតែត្រូវបានធ្វើរោគសញ្ញាដោយ MHP ថាមាននូវជំងឺផ្លូវចិត្តមួយក្នុងចំណោមជំងឺផ្លូវចិត្តដូចដែល បានពិពណ៌នានៅក្នុងក្បួនណែនាំពីស្ថិតិនិងការធ្វើរោគសញ្ញា (Diagnostic and Statistical Manual) ច្បាប់បោះពុម្ពផ្សាយលើកទីបួន ដែលបោះពុម្ពដោយសមាគមជំងឺផ្លូវចិត្តអាមេរិកកាំង (American Psychiatric Association):

- ភាពមិនប្រក្រតីផ្នែកល្បួតលាស់ដែលរាលដាល លើកលែងតែភាពមិនប្រក្រតីដែលមិនទទួលស្គាល់ការពិត៌ៅតិសតិច ឱសឲ្យរដរេសិ
- ភាពមិនប្រក្រតីដែលមានអាកប្បកិរិយារំខាន និងការធ្លាក់ចុះនូវការយកចិត្តទុកដាក់
- ភាពមិនប្រក្រតីផ្នែកការញាំ និងការបរិភោគនៃវ័យជាកូនក្មេងនិងកុមារ

- ភាពមិនប្រក្រតីនៃការលប់បំបាត់ចោល
- ភាពមិនប្រក្រតីនៃភាពជាកូនក្មេង កុមារភាព រឺភាពជាកំលោះក្រមុំ
- បែកកម្មដ្ឋាន និង ភាពមិនប្រក្រតីផ្លូវចិត្ត
- ភាពមិនប្រក្រតីផ្នែកអារម្មណ៍
- ភាពមិនប្រក្រតីនៃភាពអន្ទះសារ
- ភាពមិនប្រក្រតីដែលគ្មានរោគសញ្ញ
- ភាពមិនប្រក្រតីដែលមិនមែនធម្មជាតិ
- ភាពមិនប្រក្រតីដែលស្មុគ្រស្មាញ
- ភាពមិនប្រក្រតីទាក់ទិននឹងផ្លូវភេទ ៊ភារាផហិលិាស៊
- ភាពមិនប្រក្រតីក្នុងការកំណត់អត្តសញ្ញាណភេទ
- ភាពមិនប្រក្រតីដែលទាក់ទិននឹងអត្តសញ្ញាណភេទ ៊អនេជវេ ីជនេតិតយ ឱស ឲ្យរជរ៉ែ
- ភាពមិនប្រក្រតីក្នុងការបរិភោគ
- ភាពមិនប្រក្រតិផ្នែកគ្រប់គ្រងជីពចរ ដែលមិនមានចាត់ចំណាត់ថ្នាក់នៅកន្លែងផ្សេងៗ
- ភាពមិនប្រក្រតីក្នុងការកែតំរូវ
- ភាពមិនប្រក្រតីផ្នែកបុគ្គលិកលក្ខណៈ
  ដោយផាត់ចោលនូវភាពមិនប្រក្រតីផ្នែកប្រឆាំងនឹងភាពចូលរួមក្នុងសង្គម
- ភាពមិនប្រក្រតីផ្នែកចលនាដែលទាក់ទិន នឹងការបញ្ចូលថ្នាំដែលទាក់ទិននឹងរោគសញ្ញា
  ដទៃទៀត

និង

(2) អ្នកត្រូវតែមានយ៉ាងហោចណាស់បញ្ហាមួយក្នុងចំណោមបញ្ហាដូចខាងក្រោម ដែលជាលទ្ធផល នៃរោគសញ្ញា:

- បញ្ហាលំបាកសំខាន់ នៅក្នុងផ្នែកសំខាន់នៃដំណើរការនៃជីវិត
- ភាពប្រហាក់ប្រហែលនៃភាពទ្រុឌទ្រោមក្នុងផ្នែកសំខាន់នៃដំណើរការជីវិត
- លើកលែងតែដូចដែលបានផ្តល់អោយនៅក្នុងផ្នែកសំរាប់មនុស្សដែលមានអាយុក្រោម 21ឆ្នាំ
  ភាពប្រហាក់ប្រហែលដែលកុមារម្នាក់នឹងមិនលូតលាស់ដូច ដែលបុគ្គលម្នាក់ៗលូតលាស់

និង

(3) ការរំពឹងទុកគឺថា ការព្យាបាលដែលស្នើរឡើងនឹង :

- កាត់បន្ថយយ៉ាងខ្លាំងក្លានូវបញ្ហា
- ទប់ស្កាត់នូវការចុះអន់ថយយ៉ាងខ្លាំងក្លានូវផ្នែកដែលសំខាន់ នៃដំណើរការជីវិត
- អនុញ្ញាតអោយកុមារម្នាក់មានការលូតលាស់ដូចដែល បុគ្គលម្នាក់មានភាពសមស្រប

និង

(4) លក្ខខ័ណ្ឌ នឹងមិនមានការឆ្លើយតបចំពោះការថែទាំសុខភាពផ្លូវកាយដែលផ្អែក លើការព្យាបាល។

នៅពេលដែលសេចក្តីត្រូវនៃផ្នែក “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” នេះ ត្រូវបានឆ្លើយតប អ្នកមានសិទ្ធទទួលសេវាសុខភាពផ្លូវចិត្តឯកទេសពី MHP។

តើអ្វីជាលក្ខណ:សម្បត្តិ “ចាំបាច់ផ្នែកវេជ្ជសាស្ត្រ” (‘Medical Necessity’) ដើម្បីទទួលការរ៉ាប់រងលើសេវាសុខភាពផ្លូវចិត្តឯកទេសសំរាប់មនុស្សដែលមានអាយុក្រោម 21 ឆ្នាំ?

ប្រសិនបើអ្នកមានអាយុក្រោម 21ឆ្នាំ មាន Medi-Cal ពេញលេញ និងមានរោគសញ្ញាមួយក្នុងចំណោមរោគសញ្ញាដែលមានរាយនាមក្នុងលេខ (1)ខាងលើ ប៉ុន្តែមិនឆ្លើយតបទៅនឹងលក្ខណ:សម្បត្តិក្នុងលេខ (2) និងលេខ (3) ខាងលើ MHP ចាំបាច់ត្រូវធ្វើការជាមួយអ្នក និងអ្នកផ្តល់សេវារបស់អ្នក ដើម្បីសំរេចថាតើការព្យាបាលសុខភាពផ្លូវចិត្តរបស់អ្នក នឹងមានភាពត្រឹមត្រូវ រឺធ្វើប្រសើរ (កែលំអ) សុខភាពផ្លូវចិត្តរបស់អ្នក។ ប្រសិនបើសេវាទាំងឡាយដែលត្រូវបានរ៉ាប់រងដោយ MHP នឹងមានភាបត្រឹមត្រូវ រឺធ្វើអោយប្រសើរសុខភាពផ្លូវចិត្តរបស់អ្នក MHP នឹងផ្តល់នូវសេវាផ្សេងៗ។

*អ្នកមិនចាមបាច់ដឹងអំពីរោគសញ្ញា ដើម្បីសួរ **MHP** រកការវាយតំលៃ ដើម្បីមើលថាតើ អ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេសពី**MHP** ទេ។*

*ប្រសិនបើអ្នក **មិន** ឆ្លើយតបតាមលក្ខណ: សម្បត្តិទាំងនេះទេ វាមិនមានន័យថាអ្នកមិនអាចទទួលជំនួយទេ។ ជំនួយអាចមានពីវេជ្ជបណ្ឌិតធម្មតារបស់ **Medi-Cal** រឺតាមរយ:កម្មវិធី **Medi-Cal** ។*

តើអ្វីជាលក្ខណ:សម្បត្តិនៃ “ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ” ដើម្បីទទួលករបន្ទុះបន្ទយចំពោះសេវាមន្ទីរពេទ្យសំរាប់អ្នកជំងឺសំរាកនៅមន្ទីរពេទ្យដែលមានជំងឺផ្លូវចិត្ត?

វិធីមួយដែល MHPរបស់អ្នក សំរេចថាតើអ្នកត្រូវការស្នាក់នៅមួយយប់ នៅក្នុងមន្ទីរពេទ្យ ដើម្បីទទួលការព្យាបាលសុខភាពផ្លូវចិត្ត គឺថាតើ “ភាពចាំបាច់ផ្នែកសុខភាព” ដោយរបៀបណាចំពោះ ការព្យាបាលរបស់អ្នក។ វាមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដូចដែលបានពន្យល់ខាងលើ នៅពេលនោះ MHP នឹងបង់ថ្លៃចំពោះការស្នាក់នៅរបស់អ្នកនៅក្នុងមន្ទីរពេទ្យ។ ការវាយតំលៃ នឹងត្រូវបានធ្វើឡើង ដើម្បីជួយធ្វើការកំណត់នេះ។

នៅពេលដែលអ្នក និង MHP រឺអ្នកផ្តល់សេវានៃ MHPរបស់អ្នក មានគំរោងសំរាប់ការអនុញ្ញាតអោយចូលមន្ទីរពេទ្យ MHP នឹងសំរេចអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ មុនពេលដែលអ្នកទៅកាន់មន្ទីរពេទ្យ។ ជាញឹកញាប់ជាងនេះទៀតនេះ មនុស្សទោកាន់មន្ទីរពេទ្យក្នុងភាពអាសន្នមួយ ហើយ MHP និងមន្ទីរពេទ្យ ធ្វើការជាមួយគ្នាដើម្បីសំរេចអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។ អ្នកមិនចាំបាច់ព្រួយបារម្ភអំពី ថាតើ សេវាទាំងឡាយមានភាពចាំបាច់ផ្នែកវេជជ្ជសាស្ត្រីក៏អត់ ប្រសិនបើអ្នកទៅកាន់មន្ទីរពេទ្យក្នុងភាពអាសន្ន (សូមមើលផ្នែករដ្ឋកាលីហ្វ័រញ៉ា ទំព័រទី 6 ដើម្បីមើលពត៌មានបន្ថែម ថាតើភាពបន្ទាន់ទាំងឡាយត្រូវបានធានារ៉ាប់រងដោយរបៀបណា)។

អ្នកមានជំងឺផ្លូវចិត្ត រឺរោគសញ្ញាជំងឺផ្លូវចិត្ត ហើយអ្នកមិនអាចត្រូវបានព្យាបាលដោយសុវត្ថិភាពនៅកំរិតថែទាំដែលទាបជាង ហើយ ដោយសារតែជំងឺផ្លូវចិត្ត រឺ រោគសញ្ញាជំងឺផ្លូវចិត្ត អ្នកៈ

- ធ្វើជាតំណាងអោយគ្រោះថ្នាក់បច្ចុប្បន្នចំពោះខ្លួនអ្នក រឺអ្នកដទៃ រឺការបំផ្លាញទ្រព្យសម្បត្តិយ៉ាងខ្លាំងក្លា
- ត្រូវបានការពារមិនអោយផ្តល់ រឺប្រើប្រាស់ម្ហូបអាហារ សំលៀកបំពាក់ រឺទីជំរក
- បង្ហាញពីគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពផ្លូវកាយរបស់អ្នក
- មានការអន់ថយចុះយ៉ាងខ្លាំងក្លា នាពេលថ្មីៗនេះ ខាងផ្នែកសមត្ថភាពដើម្បីប្រព្រឹត្តសកម្មភាព និង
- ត្រូវការការវាយតំលៃ ការព្យាបាលដោយប្រើឱសថ រឺការព្យាបាលដទៃទៀតដែលអាចត្រូវបានផ្តល់អោយតែនៅក្នុងមន្ទីរពេទ្យ។

MHP នៃតំបន់របស់អ្នក

នឹងបង់ថ្លៃសំរាប់ការស្នាក់នៅដែលវែងជាងនៅក្នុងមន្ទីរពេទ្យសំរាប់អ្នកជំងឺដែលសំរាកខាងក្នុងដែលមានជំងឺផ្លូវចិត្ត ប្រសិនបើអ្នកមានចំណុចណាមួយដូចខាងក្រោមៈ

- ភាពកើតមានឡើងជាបន្តនៃលក្ខណៈសម្បត្តិនៃ "ភាពសំខាន់ផ្នែកវេជ្ជសាស្ត្រ" ដូចដែលបានពិពណ៌នាខាងលើ។
- ប្រតិកម្មជាអវិជ្ជមាន និងធ្ងន់ធ្ងរចំពោះឱសថ និតិវិធីព្យាបាល រឺការព្យាបាលផ្សេងៗ ដែលទាមទារនូវការសំរាកក្នុងមន្ទីរពេទ្យជាបន្ត
- វត្តមាននៃបញ្ហាថ្មីៗដែលឆ្លើយតបនឹងលក្ខណៈចាំបាច់ផ្នែកវេជ្ជសាស្ត្រ
- តំរូវការការវាយតំលៃផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលដែលអាចត្រូវបានផ្តល់នៅមន្ទីរពេទ្យសំរាប់អ្នកជំងឺផ្លូវចិត្តសំរាក

*ប្រសិនបើអ្នកត្រូវការសេវាមន្ទីរពេទ្យទាំងនេះ **MHP** របស់អ្នក អាចបង់ថ្លៃសំរាប់ការអនុញ្ញាតអោយចូលមន្ទីរពេទ្យ ប្រសិនបើអ្នកឆ្លើយតបតាមលក្ខ័ណ្ឌ ខាងស្តាំនេះ ដែលត្រូវបានហៅថា លក្ខណលសម្បត្តិនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។*

MHP នៃតំបន់របស់អ្នកអោយអ្នកត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យសំរាប់អ្នកជំងឺផ្លូវចិត្តសំរាក (សំរាកមួយយប់) នៅពេលដែលវេជ្ជបណ្ឌិតរបស់អ្នក និយាយថាអ្នកមានស្ថេរភាពហើយ។ នេះមានន័យថា នៅពេលដែលវេជ្ជបណ្ឌិតរំពឹងថាអ្នកនឹងមានស្ថានភាពកាន់តែដុនដាប ប្រសិនបើអ្នកត្រូវបានផ្ទេរចេញពីមន្ទីរពេទ្យ។

តើអ្វីជាសេចក្តីជូនដំណឹងពីវិធានការណ៍?

សេចក្តីជូនដំណឹងពីវិធានការណ៍ (Notice of Action) ដែលជួនកាលត្រូវបានគេហៅថា NOA គឺជាទំរង់មួយដែល MHP នៃតំបន់របស់អ្នកប្រើប្រាស់ ដើម្បីប្រាប់អ្នក នៅពេលដែល MHP ធ្វើការសំរេចចិត្តអំពីថាតើអ្នកនឹងទទួលសេវាសុខភាពផ្លូវចិត្តឯកទេសរបស់ Medi-Cal ដែររឺអត់។ A Notice of Action ក៏ត្រូវបានប្រើដើម្បីប្រាប់អ្នកទាំងឡាយអំពី ថាតើសាទុក្ខ ការប្តឹងឧទ្ធរណ៍ រឺការប្តឹងឧទ្ធរណ៍របស់អ្នកដែលមិនត្រូវបានពន្លឿន មិនត្រូវបានដោះស្រាយទាន់ពេលវេលា រឺ ប្រសិន បើអ្នកមិនបានទទួលសេវាផ្សេងៗក្នុងស្តង់ដាក្របខ័ណ្ឌពេលវេលារបស់ MHP ចំពោះការផ្តល់សេវាទាំងឡាយ។

តើនៅពេលណាដែលខ្ញុំទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ (Notice Of Action)?

អ្នកនឹងទទួលសេចក្តីជូនដំណឹងពីវិធានការណ៍:

- ប្រសិនបើ MHP របស់អ្នក រឺអ្នកផ្តល់សេវាមួយក្នុងចំណោមអ្នកផ្តល់សេវាទាំងឡាយរបស់ MHP សំរេចថាអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលសេវាសុខភាពផ្លូវចិត្តឯកទេសណាមួយរបស់ Medi-Cal ពីព្រោះអ្នកមិនបានឆ្លើយតបតាមលក្ខណៈសម្បត្តិចាំបាច់តាមផ្នែកវេជ្ជសាស្ត្រ។ សូមមើលទំព័រទី 17 ដើម្បីរកពត៌មានបន្ថែមអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។
- ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកគិតថាអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេសមួយហើយស្នើសុំពី MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP មិនយល់ព្រមហើយនិយាយថា "ទេ" ចំពោះសំណើរសុំរបស់អ្នកផ្តល់សេវា រឺប្តូរប្រភេទ រឺភាពញឹកញាប់នៃសេវា។ ភាគច្រើន អ្នកនឹងទទួលសេចក្តីជូនដំណឹងនៃវិធានការណ៍ មុនពេលដែលអ្នកទទួលសេវា ប៉ុន្តែជួនកាលសេចក្តីជុនដំណឹងពីវិធានការណ៍ នឹងមកក្នុងពេលបន្ទាប់ពីអ្នកបានទទួលសេវារួចទោហើយ។ ប្រសិនបើអ្នកទទួលសេចក្តីជូនដំណឹងពីវិធានការណ៍បន្ទាប់ពីអ្នកបានទទួលសេវារួចហើយ អ្នកមិនបាច់បង់ថ្លៃសេវាទេ។
- ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក បានស្នើរសុំ MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP ត្រូវការនូវពត៌មានបន្ថែមទៀតដើម្បីធ្វើការសំរេចចិត្ត និងមិនបំពេញដំណើរការអនុម័តយល់ព្រមទាន់ពេលវេលា។
- ប្រសិនបើ MHP របស់អ្នក មិនផ្តល់នូវសេវាទាំងឡាយទៅអោយអ្នក ដោយផ្អែកលើក្របខ័ណ្ឌពេលវេលាដែល MHP បានបង្កើតឡើង។ សូមទូរស័ព្ទទៅ MHP នៃតំបន់របស់អ្នកដើម្បីមើលថាតើ MHP បានបង្កើតនូវកំរិតស្តង់ដាពេលវេលាដែររឺទេ។
- ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងសាទុក្ខ ទៅ MHP ហើយ MHP មិនឆ្លើយតបមកអ្នកវិញជាដោយការសំរេចចិត្តជាលាយល័ក្ខអក្សរស្តីពីបណឹងសាទុក្ខរបស់អ្នកក្នុងរយៈពេល 60 ថ្ងៃ។ សូមមើលទំព័រទី 28 ដើម្បីរកពត៌មានបន្ថែមស្តីពីសាទុក្ខ។
- ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ទៅ MHP ហើយ MHP មិនឆ្លើតតបមកកាន់អ្នកវិញជាមួយនឹងការសំរេចចិត្តជាលាយល័ក្ខអក្សរស្តីពីឧទ្ធណ៍របស់អ្នកក្នុងរយៈពេល 45 ថ្ងៃទេ រឺ

ប្រសិនបើអ្នកបានប្ដឹងនូវឧទ្ធរណ៍ដែលមិនត្រូវបានពន្លឿន ក្នុងរយៈពេលបីថ្ងៃធ្វើការ។ សូមមើលទំព័រទី 23 ដើម្បីបានពត៌មានបន្ថែមស្តីពីការប្ដឹងឧទ្ធរណ៍។

តើខ្ញុំតែងតែទទួលនូវសេចក្តីជូនដំណឹងពីវិធានការណ៍ នៅពេលដែលខ្ញុំមិនបានទទួលសេវាដែលខ្ញុំចង់បាន?

ចមាននូវសេវាខ្លះៗដែលអ្នកមិនអាចទទួលនូវសេចក្តីជូនដំណឹងពីវិធានការណ៍។ ប្រសិនបើអ្នក និងអ្នកផ្តល់សេវាមិនយល់ព្រមលើសេវាទាំងឡាយដែលអ្នកត្រូវការ អ្នកនឹងមិនអាចទទួលនូវសេចក្តីជូនដំណឹងពីវិធានការណ៍ពី MHP ឡើយ។ ប្រសិនបើអ្នកគិតថា MHP មិនកំពុងផ្តល់សេវាដល់អ្នកបានឆាប់រហ័សគ្រប់គ្រាន់ទេ ប៉ុន្តែ MHP មិនបានកំណត់ក្របខ័ណ្ឌពេលវេលាទេ អ្នកនឹងមិនទទួលនូវសេចក្តីជូនដំណឹងស្តីពីវិធានការណ៍ឡើយ។

សូមមើលផ្នែកបន្ទាប់នៅក្នុងសៀវភៅណែនាំនេះលើផ្នែកដំណើរការដោះស្រាយបញ្ហាដើម្បីបានពត៌មានបន្ថែម ស្តីពីសារទុក្ខ ឧទ្ធរណ៍ និងរដ្ឋសាវនាការ។

អ្នកអាចនៅតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅ MHP រឺស្នើសុំនូវសាវនាការយុត្តិធម៌ នៅពេលដែលរឿងទាំងនេះកើតឡើង។ ពត៌មានស្តីពីរបៀបដាក់ពាក្យប្តឹងឧទ្ធរណ៍ រឺស្នើរសុំសាវនាករយុត្តិធម៌ត្រូវបានរាប់បញ្ចូលក្នុងនៅក្នុងសៀវភៅនេះ ដែលចាប់ផ្តើមលើទំព័រទី 22។ ពត៌មានគួរតែមានផងដែរនៅក្នុងការិយាល័យអ្នកផ្តល់សេវារបស់អ្នក។

តើអ្វីដែលសេចក្តីជូនដំណឹងពីវិធានការណ៍នឹងប្រាប់ខ្ញុំ?

សេចក្តីជូនដំណឹងពីវិធានការណ៍នឹងប្រាប់អ្នកនូវៈ

- អ្វីដែល MHP នៃតំបន់របស់អ្នកបានធ្វើ ដែលប៉ះពាល់ទៅនឹងអ្នក និងសមត្ថភាពរបស់អ្នកដើម្បីទទួលសេវាទាំងនេះ។
- កាលបរិច្ឆេទដែលមានប្រសិទ្ធភាពនៃការសំរេចចិត្តនេះ និងហេតុផលដែល MHP បានធ្វើការសំរេចចិត្តរបស់ខ្លួន។
- ច្បាប់រដ្ឋ រឺសហព័ន្ធដែល MHP បានកំពុងអនុវត្តន៏តាម គឺនៅពេលដែលគេបានធ្វើការសំរេចចិត្ត។
- អ្វីដែលជាសិទ្ធរបស់អ្នក គឺប្រសិនបើអ្នកមិនយល់ព្រមនឹងអ្វីដែល MHP បានធ្វើ។
- របៀបធ្វើការប្តឹងបណ្តឹងសាទុក្ខទៅ MHP។
- របៀបស្នើសុំសាវនាការយុត្តិធម៌។
- របៀបស្នើសុំការប្តឹងឧទ្ធរណ៍ដែលត្រូវបានពន្លឿន រឺសាវនាការយុត្តិធម៌ដែលពន្លឿន។
- របៀបទទួលជំនួយក្នុងការធ្វើការប្តឹងពីឧទ្ធរណ៍ រឺស្នើសុំសាវនាការយុត្តិធម៌។
- រយៈពេលដែលអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក រឺស្នើសុំសាវនាការយុត្តិធម៌។
- ប្រសិនបើអ្នកមានសិទ្ធគ្រប់គ្រាន់ក្នុងការបន្តទទួលសេវាទាំងឡាយនៅពេលដែលអ្នករង់ចាំការសំរេចចិត្តនៃរដ្ឋសាវនាការយុត្តិធម៌។
- នៅពេលដែលអ្នកត្រូវដាក់ការស្នើសុំរដ្ឋសាវនាការយុត្តិធម៌របស់អ្នក ប្រសិនបើអ្នកចង់អោយសេវាទាំងឡាយបន្ត។

តើអ្វីដែលខ្ញុំគួរតែធ្វើនៅពេលដែលខ្ញុំទទួលបាននូវសេចក្តីជុនដំណឹងពីវិធានការណ៍?

នៅពេលដែលអ្នកទទួលសេចក្តីជូនដំណឹងពីវិធានការណ៍
អ្នកគួរតែអានពត៏មានទាំងអស់នេះបន្តដោយប្រុងប្រយ័ត្ន។ ប្រសិនបើអ្នកមិនយល់ពីពាក្យសុំទេ MHP អាចជួយអ្នកបាន។ អ្នកអាចសុំអ្នកណាម្នាក់ទៀតអោយជួយអ្នកផងដែរ។

ប្រសិនបើពាក្យបែបបទនៃសេចក្តីជូនដំណឹងសាទុក្ខ
ប្រាប់អ្នកថាអ្នកអាចបន្តសេវាទាំងឡាយនៅពេលដែលអ្នកកំពុងរង់ចាំ
ការសំរេចចិត្តនៃរដ្ឋសាវនាការយុត្តិធម៏ អ្នកត្រូវតែស្នើសុំរដ្ឋសាវនាការយុត្តិធម៏ក្នុងអំឡុង 10ថ្ងៃ
ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងពីវិធានការណ៍ ត្រូវបានផ្ញើទៅអោយ រឺអោយៈអ្នកដោយផ្ទាល់ដៃ រឺ
ប្រសិនបើសេចក្តីជុនដំណឹងពីវិធានការណ៍ត្រូវបានផ្ញើទោកាន់អ្នកក្នុងរយៈពេលយូរជាង 10ថ្ងៃ
មុនកាលបរិច្ឆេទដែលមានប្រសិទ្ធភាពសំរាប់ការបួស់ផ្តូរសេវាផ្សេង។
មុនកាលបរិច្ឆេទនៃការបួស់ផ្តូរដែលមានប្រសិទ្ធភាព។

តើយ៉ាងដូចម្តេច បើខ្ញុំមិនទទួលសេវាដែលខ្ញុំចង់បានពី MHP នៃតំបន់របស់ខ្ញុំ?

MHPនៃតំបន់របស់អ្នកមានរបៀបមួយសំរាប់អ្នកដើម្បីធ្វើការដោះស្រាយបញ្ហាអំពីបញ្ហាអ្វីដែលទាក់ទងនឹងសេវាសុខភាពផ្លូវចិត្តឯកទេសដែលអ្នកកំពុងទទួល។ នេះត្រូវបានគេហៅថាដំណើរការដោះស្រាយបញ្ហា ហើយវាអាចធ្វើអោយមានការជាប់ទាក់ទងនឹង:

1. **ដំណើរការឧទ្ធរណ៍**- ការពិនិត្យសើរើការសំរេចចិត្ត (ការបដិសេធន៍ រឺការប្តូរចំពោះសេវា) ដែលត្រូវបានធ្វើឡើងស្តីពីសេវាសុខភាពផ្លូវចិត្តឯកទេសរបស់អ្នក ដោយ MHPរឺ អ្នកផ្តល់សេវារបស់អ្នក។
2. **ដំណើការរដ្ឋសាវនាការយុត្តិធម៌** -ពិនិត្យសើរើដើម្បីមើលអោយច្បាស់ថាអ្នកទទួលនូវសេវាសុខភាពផ្លូវចិត្ត ដែលអ្នកមានសិទ្ធទទួលនៅក្រោមកម្មវិធីរបស់ Medi-Cal។
3. **ដំណើរការសាទុក្ខ**-
   ការបង្ហាញពីភាពមិនសប្បាយអំពីអ្វីដែលទាក់ទងនឹងសេវាសុខភាពផ្លូវចិត្តឯកទេសដែលមិនមែនជាបញ្ហាមួយក្នុងចំណោមដែលត្រូវបានរ៉ាប់រងដោយឧទ្ធរណ៍ និងដំណើរការរដ្ឋសាវនាការយុត្តិធម៌។

MHP របស់អ្នក នឹងផ្តល់នូវសាទុក្ខ និងពាក្យសុំប្តឹងឧទ្ធរណ៍ និងស្រោមសំបុត្រដែលត្រូវដាក់អាស័យដ្ឋានដោយខ្លួនឯង សំរាប់អ្នកនៅតាមកន្លែងផ្តល់សេវាទាំងអស់ ហើយអ្នកមិនគួរសុំពីនរណាម្នាក់ឡើយ។ MHPនៃតំបន់របស់អ្នក ត្រូវតែបិទសេចក្តីប្រកាសផ្សេងៗដែលពន្យល់ពីសាទុក្ខ និងនិតិវិធីដំណើរការប្តឹងឧទ្ធរណ៍នៅតាមទីកន្លែងនៃទីតាំងផ្តល់សេវាទាំងអស់ ហើយរៀបចំអោយមានសេវាបកប្រែភាសាមានអាចរកបានដោយឥតគិតថ្លៃ ព្រមជាមួយនឹងលេខទូរស័ព្ទដោយឥតគិតថ្លៃដើម្បីជួយអ្នកម៉ោងធ្វើការធម្មតា។

*សេវាផ្នែកតំណាង **Ombudsman** នៃសុខភាពផ្លូវចិត្តរបស់រដ្ឋ អាចត្រូវបានទាក់ទងតាមទូរស័ព្ទលេខ **(800) 896-4042** ក (សេវាអ្នកបកប្រែអាចមានរកបាន) រឺ**TTY (800) 896-2512** ដោយផ្ញើ ទូរសារទៅកាន់លេខ**(916) 653-9194** រឺដោអ៊ីម៉ែលទៅកាន់ **ombudsmn@dmhhq.state.ca.us** ។*

អ្នកនឹងមិនត្រូវបានដាក់ទណ្ឌកម្មចំពោះការប្តឹងសាទុក្ខ រឺឧទ្ធរណ៍ រឺរដ្ឋសាវនាការឡើយ។ នៅពេលដែលសាទុក្ខ រឺឧទ្ធរណ៍របស់អ្នកចប់សព្វគ្រប់ MHPនៃតំបន់របស់អ្នកនឹងជំរាបជូនអ្នក និងអ្នកដទៃទាំងឡាយដែលជាប់ពាក់ព័ន្ធ អំពីលទ្ធផលចុងក្រោយ។ នៅពេលដែលរដ្ឋសាវនាការ ចប់សព្វគ្រប់ ការិយាល័យនឹងជំរាបជូនអ្នកនិងអ្នកដទៃដែលពាក់ព័ន្ធ អំពីលទ្ធផលចុងក្រោយ។

តើខ្ញុំអាចទទួលជំនួយក្នុងការប្តឹងឧទ្ធរណ៍ សាទុក្ខ រឺរដ្ឋសាវនាការយុត្តិធម៌ដែររឺទេ?

MHP នៃតំបន់របស់អ្នក នឹងមានមនុស្សចាំពន្យល់ពីដំណើរការទាំងនេះដល់អ្នក និងដើម្បីជួយអ្នករាយការណ៍ពីបញ្ហក្នុងទំរង់ជា ឧទ្ធរណ៍ សាទុក្ខ រឺជាសំណើរសុំរដ្ឋសាវនាការយុត្តិធម៌។ ពួកគេក៏អាចជួយអ្នកដឹងផងដែរ ថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលអ្វីដែះហៅថាដំណើរការ “ពន្លឿន” (expedited) ដែលមានន័យថា វានឹងត្រូវបានពិនិត្យសើរើកាន់តែឆាប់រហ័ស ដោយសារតែសុខភាព

រឺស្ថេរភាពរបស់អ្នកស្ថិតក្នុងភាពគ្រោះថ្នាក់។ អ្នកអាចអនុញ្ញាតផងដែរអោយមនុស្សម្នាក់ទៀត ធ្វើអ្វីៗក្នុងនាមជារូបអ្នក ដែលរាប់បញ្ចូលទាំងអ្នកផ្តល់សេវាថែទាំសុខភាពផ្លូវចិត្តរបស់អ្នកផងដែរ។

តើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំត្រូវការជំនួយក្នុងការដោះស្រាយបញ្ហាមួយជាមួយនឹង MHP ប៉ុន្តែមិនចង់ធ្វើការប្តឹងសាទុក្ខ រឺឧទ្ធរណ៍?

អ្នកអាចទទួលជំនួយពីរដ្ឋ ប្រសិនបើអ្នកកំពុងមានបញ្ហាក្នុងការស្វែងរកមនុស្សដែលត្រឹមត្រូវនៅឯ MHP ដើម្បីជួយអ្នកក្នុងការស្វែងរកមធ្យោបាយរបស់អ្នក ដើម្បីឆ្លងកាត់តាមរយៈប្រព័ន្ធ MHP។ រដ្ឋមានកម្មវិធីសេវាការិយាល័យតំណាង (Ombudsman) ផ្នែកសុខភាពផ្លូវចិត្ត ដែលអាចផ្តល់អោយអ្នកនូវពត៌មានថាតើ MHP មានដំណើរប្រព្រឹត្តទៅដោយរបៀបណា ពន្យល់ពីសិទ្ធរបស់អ្នក និងជំរើសផ្សេងៗ ជួយអ្នកដោះស្រាយបញ្ហាផ្សេងៗជាមួយនឹងការទទួលសេវាទាំងឡាយដែលអ្នកត្រូវការ និងណែនាំអ្នកទៅអ្នកដទៃនៅឯ MHP រឺក្នុងសហគមន៍របស់អ្នកដែលអាចជំនួយបាន។

MHPរបស់អ្នក មានទំនួលខុសត្រូវក្នុងការអនុញ្ញាតអោយអ្នកស្នើសុំនូវការពិនិត្យសើរើការសំរេចចិត្តដែលត្រូវបានធ្វើឡើងស្តីពីសេវាសុខភាពផ្លូវចិត្តឯកទេសដោយ MHP រឺអ្នកផ្តល់សេវារបស់អ្នក។ មានមធ្យោបាយពីរយ៉ាងដែលអ្នកអាចស្នើរសុំនូវការពិនិត្យសើររើ។ មធ្យោបាយមួយគឺការប្រើដំណើរការឧទ្ធរណ៍តាមកំរិតស្តង់ដា។ មធ្យោបាយទីពីរគឺដោយប្រើដំណើរការឧទ្ធរណ៍ដែលពន្លឿន។ មធ្យោបាយទាំងពីរនេះមានភាពស្រដៀងគ្នា។ ទោះបីយ៉ាងណាក៏ដោយ មាននូវសេចក្តីតំរូវច្បាស់លាស់ដើម្បីគ្រប់លក្ខណៈសម្បត្តិដើម្បីទទួលបាននូវឧទ្ធរណ៍ដែលពន្លឿន។ សេចក្តីត្រូវការជាក់លាក់ ត្រូវបានពន្យល់ខាងក្រោម។

តើអ្វីជាឧទ្ធរណ៍តាមកំរិតស្តង់ដា?

ឧទ្ធរណ៍តាមកំរិតស្តង់ដា (Standard Appeal) គឺជាសំណើរមួយសំរាប់ការពិនិត្យសើរើនៃបញ្ហាមួយដែលអ្នកមានជាមួយនឹង MHP រឺអ្នកផ្តល់សេវា របស់អ្នក ដែលទាក់ទិននឹងការបដិសេធន៍ រឺការប្តូរចំពោះសេវាដែលអ្នកគិតថាអ្នកត្រូវការនោះ។ ប្រសិនបើអ្នកស្នើសុំឧទ្ធរណ៍តាមកំរិតស្តង់ដា MHPអាចត្រូវការរហូតដល់ 45ថ្ងៃ ដើម្បីពិនិត្យសើរើវា។ ប្រសិនបើអ្នកគិតថាការរង់ចាំរយៈពេល 45ថ្ងៃ នឹងធ្វើអោយសុខភាពរបស់អ្នកស្ថិតក្នុងសភាពគ្រោះថ្នាក់ អ្នកគួរតែស្នើសុំ "ឧទ្ធរណ៍ដែលពន្លឿន" (expedited appeal)។

ដំណើរការនៃឧទ្ធរណ៍ស្តង់ដា នឹង:

- អនុញ្ញាតអោយអ្នកដាក់ពាក្យប្តឹងឧទ្ធរណ៍ដោយផ្ទាល់មុខ រឺតាមទុរស័ព្ទ រឺដោយសរសេរជាលាយល័ក្ខអក្សរ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នកដោយផ្ទាល់មុខ រឺដោយទូរស័ព្ទ អ្នកត្រូវតែដាក់តាមក្រោយវាដោយឧទ្ធរណ៍ជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខា។ ប្រសិនបើអ្នកមិនដាក់តាមពីក្រោយនូវឧទ្ធរណ៍ជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខាទេ ឧទ្ធរណ៍របស់អ្នកនឹងមិនត្រូវបានដោះស្រាយឡើយ។ ទោះបីយ៉ាងណាក៏ដោយ កាលបរិច្ឆេទដែលអ្នកបានដាក់ឧទ្ធរណ៍ដោយផ្ទាល់មាត់ គឺត្រូវយកជាកាលបរិច្ឆេទប្តឹងឧទ្ធរណ៍។
- ធានាអោយបានថា ការដាក់ពាក្យប្តឹងឧទ្ធរណ៍ នឹងមិនយកទៅប្រឆាំងទប់ទល់នឹងអ្នក រឺអ្នកផ្តល់សេវារបស់អ្នកក្នុងរូបភាពណាមួយឡើយ។
- អោយអ្នក អនុញ្ញាតអ្នកដទៃម្នាក់ទៀតអោយដើរតួនាទីក្នុងនាមជារូបអ្នក ដោយរាប់បញ្ចូលទាំងអ្នកផ្តល់សេវាផងដែរ។ ប្រសិនបើអ្នកអនុញ្ញាតងោយនរណាម្នាក់ដើរតួនាទីក្នុងនាមជារូបអ្នក MHPអាចស្នើរសុំអោយអ្នកចុះហត្ថលេខាលើពាក្យសុំមួយដែលអនុញ្ញាតអោយ MHP បញ្ចេញពត៌មានផ្សេងៗទៅមនុស្សនោះ។

- ធានាអោយបានថាបុគ្គលដែលធ្វើការសំរេចចិត្តមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើដូច្នោះ ហើយមិនមានការពាក់ព័ន្ធនឹងកំរិតនៃការសើរើ រឺការសំរេចចិត្តកាលពីមុន។
- អនិញ្ញាតអោយអ្នក រឺអ្នកតំណាងរបស់អ្នក ពិនិត្យសំណុំរឿងនៃករណីរបស់អ្នក ដែលរួមមានទាំងកំណត់ត្រាផ្នែកវេជ្ជសាស្រ្តរបស់អ្នក និងឯកសារដទៃផ្សេងទៀត រឺកំណត់ត្រាផ្សេងៗដែលត្រូវបានគេពិចារណាក្នុងអំឡុងដំណើរការឧទ្ធរណ៍ ពីមុននិងក្នុងអំឡុងពេលដំណើរការឧទ្ធរណ៍។
- អនុញ្ញាតអោយអ្នក ទទួលនូវឱកាសសមហេតុផលដើម្បីដាក់ជូននូវភស្តុតាង និងការចោទប្រកាន់ផ្សេងៗអំពីហេតុការណ៍ រឺផ្លូវច្បាប់ ដោយផ្ទាល់មុខ រឺជាលាយល័ក្ខអក្សរ។
- អនុញ្ញាតអោយអ្នក អ្នកតំណាងរបស់អ្នក រឺអ្នកតំណាងផ្លូវច្បាប់ដទៃទៀតនៃទ្រព្យធនរបស់អ្នកទទួលអត្ថប្រយោជន៏ដែលបានស្លាប់ទៅ ដែលត្រូវបានរាប់បញ្ចូលជាភាគីដើម្បីធ្វើការប្តឹងឧទ្ធរណ៍។
- អនុញ្ញាតអោយអ្នកដឹងថាឧទ្ធរណ៍របស់អ្នកកំពុងត្រូវបានពិនិត្យសើរើ ដោយផ្ញើរអោយអ្នកនូវការបញ្ជាក់ជាលាយល័ក្ខអក្សរ។
- ជំរាបអ្នកពីសិទ្ធរបស់អ្នកដើម្បីស្នើសុំរដ្ឋសាវនាការយុត្តិធម៌ នៅគ្រប់ពេលវេលា ក្នុងអំឡុងដំណើរការឧទ្ធរណ៍។

តើនៅពេលណាដែលខ្ញុំអាចដាក់ពាក្យប្តឹងឧទ្ធរណ៍?

អ្នកអាចដាក់ពាក្យប្តឹងឧទ្ធរណ៍ទៅ MHP នៃតំបន់របស់អ្នកៈ

- ប្រសិនបើ MHP របស់អ្នក រឺអ្នកផ្តល់សេវាម្នាក់ក្នុងចំណោមអ្នកផ្តល់សេវារបស់ MHP សំរេចថាអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលសេវាសុខភាពផ្លូវចិត្តឯកទេសរបស់ Medi-Cal ទាំងឡាយ ដោយសារអ្នកមិនឆ្លើយតបតាមលក្ខណៈសម្បត្តិភាពចាំបាច់ផ្នែកវេជ្ជសាស្រ្ត។ (សូមមើលទំព័រទី 17 ដើម្បីរកពត៏មានបន្ថែមអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្រ្ត)។
- ប្រសិនបើអ្នកផ្តល់សេវាគិតថា អ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេស និងសុំពី MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP មិនយាល់ព្រម ហើយនិយាយថា "ទេ"ចំពោះសំណើររបស់អ្នកផ្តល់សេវារបស់អ្នក រឺប្តូរប្រភេទ រឺភាពញឹកញាប់នៃសេវា។
- ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក បានសុំ MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP ត្រូវការនូវពត៏មានបន្ថែមដើម្បីធ្វើការសំរេចចិត្ត ហើយមិនបានបំពេញដំណើរការអនុម័តយល់ព្រមអោយចប់សព្វគ្រប់ទាន់ពេលវេលាទេ។
- ប្រសិនបើ MHP របស់អ្នក មិនផ្តល់សេវាអោយអ្នកដោយផ្អែកលើក្របខ័ណ្ឌពេលវេលាដែល MHP បានកំណត់ឡើង។
- ប្រសិនបើអ្នកមិនគិតថា MHP កំពុងផ្តល់នូវសេវាផ្សេងៗអោយបានឆាប់គ្រប់គ្រាន់ល្មមដើម្បីឆ្លើយតបតាមតំរូវការរបស់អ្នក។
- ប្រសិនបើសាទុក្ខ ឧទ្ធរណ៍ រឺឧទ្ធរណ៍ពន្លឿន មិនត្រូវបានដោះស្រាយទាន់ពេលវេលា។

- ប្រសិនបើអ្នក និងអ្នកផ្តល់សេវារបស់អ្នក មិនយល់ព្រមលើសេវាទាំងឡាយដែលអ្នកត្រូវការ។

តើខ្ញុំអាចប្តឹងឧទ្ធរណ៍ដោយរបៀបណា?

សូមមើលផ្នែកខាងមុខនៃសៀវភៅនេះ ដើម្បីរកពត៌មានបន្ថែមស្តីពីរបៀបដាក់ពាក្យប្តឹងឧទ្ធរណ៍ទៅ MHPរបស់អ្នក។ អ្នកអាចទូរស័ព្ទទៅលេខទូរស័ព្ទឥតគិតថ្លៃនៃ MHPនៃតំបន់របស់អ្នក (ដែលត្រូវបានដាក់បញ្ចូលក្នុងផ្នែកខាងមុខនៃសៀវភៅនេះ) ដើម្បីទទួលជំនួយជាមួយនឹងការដាក់ពាក្យប្តឹងឧទ្ធរណ៍។ MHP នឹងផ្តល់ស្រោមសំបុត្រដែលមានចុះអាស័យដ្ឋានរបស់ខ្លួននៅតាមគ្រប់កន្លែងនៃអ្នកផ្តល់សេវាទាំងអស់សំរាប់អ្នកអ្នកផ្ញើរមកវិញនូវឧទ្ធរណ៍របស់អ្នក។

តើខ្ញុំដឹងថាតើឧទ្ធរណ៍របស់ខ្ញុំត្រូវបានសំរេចដោយរបៀបណា?

MHP របស់អ្នក នឹងជំរាបអ្នក រឺអ្នកតំណាងរបស់អ្នកជាលាយល័ក្ខអក្សរអំពីការសំរេចចិត្តរបស់អ្នក។ សេចក្តីជូនដំណឹងនឹងមាននូវពត៌មានដូចខាងក្រោមៈ

- លទ្ធផលនៃដំណើរការដោះស្រាយឧទ្ធរណ៍
- កាលបរិច្ឆេទដែលការសំរេចចិត្តលើឧទ្ធរណ៍ត្រូវបានធ្វើឡើង
- ប្រសិនបើឧទ្ធរណ៍មិនត្រូវបានដោះស្រាយទាំងស្រុងតាមបំណងរបស់អ្នកទេ សេចក្តីជូនដំណឹងនឹងមានផងដែរនូវពត៌មានដែលទាក់ទងនឹងសិទ្ធរបស់អ្នក ចំពោះរដ្ឋសាវនាការយុត្តិធម៌ និងនិតិវិធីសំរាប់ការដាក់បណ្តឹងរដ្ឋសាវនាការយុត្តិធម៌។

តើមានកាលបរិច្ឆេទដើម្បីដាក់បណ្តឹងឧទ្ធរណ៍ដែររឺទេ?

អ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 90ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃញ្ញត្តិដែលអ្នកកំពុងប្តឹងឧទ្ធរណ៍ នៅពេលដែលអ្នកទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ (notice of action) (សូមមើលទំព័រទី 20)។ សូមចងចាំក្នុងចិត្តថា អ្នកនឹងមិនទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ជានិច្ចកាលនោះទេ។

ពុំមានកាលបរិច្ឆេទផុតកំណត់សំរាប់ការប្តឹងឧទ្ធរណ៍នៅពេលដែលអ្នកមិនទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ទេ ដូចច្នេះអ្នកអាចប្តឹងគ្រប់ពេលវេលា។

តើនៅពេលណាដែលសេចក្តីសំរេចចិត្តមួយត្រូវបានធ្វើឡើងអំពីការប្តឹងឧទ្ធរណ៍របស់ខ្ញុំ?

MHP ត្រូវតែសំរេចលើឧទ្ធរណ៍របស់អ្នកក្នុងអំឡុង 45ថ្ងៃប្រតិទិន ចាប់ពីពេលដែល MHPទទួលបានសំណើរសុំប្តឹងឧទ្ធរណ៍របស់អ្នក។ ក្របខ័ណ្ឌពេលវេលា អាចត្រូវបានពន្យារហួតដល់ 14ថ្ងៃប្រតិទិន ប្រសិនបើអ្នកស្នើសុំការពន្យា រឺប្រសិនបើ MHP មានអារម្មណ៍ថា មានសេចក្តីត្រូវការពត៌មានបន្ថែម ហើយថាការពន្យា មិនមែនជាអត្ថប្រយោជន៍របស់អ្នកទេ។ ឧទាហរណ៍ពីពេលដែលការពន្យាសំរាប់អត្ថប្រយោជន៍របស់អ្នក គឺនៅពេលដែល MHP គិតថាគេអាចអនុម័តយល់ព្រមចំពោះឧទ្ធរណ៍របស់អ្នក ប្រសិនបើ MHP មានពេលវេលាច្រើនបន្តិចទៀតដើម្បីទទួលពត៌មានពីអ្នក រឺអ្នកផ្តល់សេវារបស់អ្នក។

តើដូចម្តេច ប្រសិនបើខ្ញុំមិនអាចរង់ចាំរយៈពេល 45ថ្ងៃ ដើម្បីទទួលការសំរេចចិត្តនៃឧទ្ធរណ៍របស់ខ្ញុំ?

ដំណើរការនៃឧទ្ធរណ៍ អាចមានរយៈពេលលឿនជាង ប្រសិនបើវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលដំណើរការពន្លឿន។ (សូមមើលផ្នែកស្តីពីឧទ្ធរណ៍ពន្លឿនទាំងឡាយខាងក្រោម)។ អ្នកមានសិទ្ធស្នើសុំ រដ្ឋសាវនាការយុត្តិធម៌នៅគ្រប់ពេលវេលា ក្នុងអំឡុងដំណើរការនៃឧទ្ធរណ៍។

តើអ្វីជាឧទ្ធរណ៍ដែលមានការពន្លឿន?

ឧទ្ធរណ៍ដែលពន្លឿន ជាវិធីលឿនជាងក្នុងការសំរេចឧទ្ធរណ៍មួយ។ ដំណើរការឧទ្ធរណ៍ដែលពន្លឿនអនុវត្តន៍តាមដំណើរដែលមានភាពស្រដៀងគ្នា ជាងដំណើរការឧទ្ធរណ៍តាមកំរិតស្តង់ដា។ ទោះបីយ៉ាងណាក៏ដោយ

- ឧទ្ធរណ៍របស់អ្នក ត្រូវតែឆ្លើយតបតំរូវការមួយចំនួន (សូមមើលខាងក្រោម)។
- ដំណើរការប្តឹងឧទ្ធរណ៍ដែលពន្លឿន ក៏អនុវត្តន៍តាមកាលបរិច្ឆេទផ្សេងៗគ្នាជាងឧទ្ធរណ៍ស្តង់ដា។
- អ្នកអាចស្នើសុំដោយផ្ទាល់មាត់នូវឧទ្ធរណ៍ដែលពន្លឿន។ អ្នកមិនចាំបាច់ត្រូវតែដាក់ឧទ្ធរណ៍របស់អ្នកជាលាយល័ក្ខអក្សរឡើយ។

តើនៅពេលណាដែលខ្ញុំអាចដាក់ពាក្យប្តឹងឧទ្ធរណ៍ដែលពនឿន?

ប្រសិនបើអ្នកគិតថា ការរង់ចាំរហូតដល់ 45 ថ្ងៃដើម្បីទទួលសេចក្តីសំរេចចិត្តឧទ្ធរណ៍ស្តង់ដា នឹងបណ្តាលអោយមានគ្រោះថ្នាក់ដល់ជីវិត សុខភាព រឺសមត្ថភាពក្នុងការទទួល រក្សា រឺទទួលឡើងវិញនូវដំណើការជាអតិបរមារបស់អ្នក អ្នកអាចស្នើរសុំនូវឧទ្ធរណ៍ពន្លឿនបាន។ ប្រសិនបើ MHP យល់ព្រមថាឧទ្ធរណ៍របស់អ្នកឆ្លើយតបតាមសេចក្តីត្រូវការចំពោះឧទ្ធរណ៍ពន្លឿន MHP របស់អ្នកនឹងដោះស្រាយឧទ្ធរណ៍ពន្លឿនរបស់អ្នក ក្នុងអំឡុង 3 ថ្ងៃធ្វើការ បន្ទាប់ពី MHP ទទួលឧទ្ធរណ៍ដែលពន្លឿន។ ក្របខ័ណ្ឌពេលវេលាអាចត្រូវបានពន្យារហូតដល់ 14 ថ្ងៃប្រតិទិន ប្រសិនបើអ្នកស្នើរសុំការពន្យា រឺប្រសិនបើ MHP គិតថាមានសេចក្តីត្រូវការពត៌មានបន្ថែម និងថាការពន្យាស្ថិតក្នុងផលប្រយោជន៍របស់អ្នក។ ប្រសិនបើ MHP ពន្យាពេលលើសពីក្របខ័ណ្ឌពេលវេលា MHP នឹងផ្តល់អោយអ្នកនូវការពន្យល់ជាលាយល័ក្ខអក្សរដោយថាតើហេតុអ្វីបានជាក្របខ័ណ្ឌពេលវេលាត្រូវ បានពន្យា។

ប្រសិនបើ MHP សំរេចថាឧទ្ធរណ៍របស់អ្នក មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះឧទ្ធរណ៍ពន្លឿន MHP របស់អ្នកនឹងជំរាបជូនអ្នកភ្លាមដោយផ្ទាល់មាត់ ហើយនឹងជំរាបជុនអ្នកជាលាយល័ក្ខអក្សរក្នុងរយៈពេល 2 ថ្ងៃប្រតិទិន។ ឧទ្ធរណ៍របស់អ្នកនឹងអនុវត្តន៍តាមក្របខ័ណ្ឌឧទ្ធរណ៍ស្តង់ដាដែលបញ្ជាក់ពីដំបូងនៅក្នុងផ្នែកនេះ។ ប្រសិនបើអ្នកមិនយល់ព្រមនឹងការសំរេចចិត្តរបស់ MHPE ដែលថាឧទ្ធរណ៍របស់អ្នកមិនឆ្លើយតបនឹងលក្ខណៈសម្បត្តិឧទ្ធរណ៍ពន្លឿនទេ អ្នកអាចដាក់បណ្តឹងសាទុក្ខបាន (សូមមើលការពិពណ៌នានៅក្នុងដំណើរការប្តឹងសាទុក្ខខាងក្រោម)។

នៅពេលដែល MHP របស់អ្នកដោះស្រាយឧទ្ធរណ៍ដែលពន្លឿនរបស់អ្នក MHP នឹងជំរាបជូនអ្នក និងភាគីដែលប៉ះពាល់ទាំងអស់ដោយផ្ទាល់មាត់ និងជាលាយល័ក្ខអក្សរ។

ដំណើរការផ្សេងៗនៃរដ្ឋសាវនាការយុត្តិធម៌

(សង់ដា និងពនឿន)

តើអ្វីជារដ្ឋសាវនាការយុត្តិធម៌?

រដ្ឋសាវនាការយុត្តិធម៌ គឺជាការពិនិត្យសើរើឯករាជ្យដែលត្រូវបានធ្វើឡើងដោយក្រសួងសេវាសង្គមរបស់រដ្ឋកាលីហ្វ័រញ៉ា ដើម្បីធានាថាអ្នកទទួលបានទូវសេវាសុខភាពឯកទេស ដែលអ្នកមានសិទ្ធទទួលនៅក្រោមកម្មវិធីរបស់ Medi-Cal។



តើអ្វីជាសិទ្ធិផ្នែករដ្ឋសាវនាការយុត្តិធម៌របស់ខ្ញុំ?

អ្នកមានសិទ្ធទទួល :

- សាវនាការយុត្តិធម៌ នៅចំពោះមុខក្រសួងសេវាសង្គមរបស់រដ្ឋកាលីហ្វ័រញ៉ា (ដូចគ្នាផងដែរត្រូវបានហៅថារដ្ឋសាវនាការយុត្តិធម៌)
- ត្រូវបានប្រាប់អំពីរបៀបសុំរដ្ឋសាវនាការយុត្តិធម៌
- ត្រូវបានប្រាប់អំពីច្បាប់ដែលដឹកនាំការតំណាងនៅឯរដ្ឋសាវនាការយុត្តិធម៌
- មានអត្ថប្រយោជន៍របស់អ្នកបន្ត តាមសំណើរក្នុងអំឡុងដំណើរការរដ្ឋសាវនាការយុត្តិធម៌ ប្រសិនបើអ្នកស្នើសុំសាវនាការយុត្តិធម៌ក្នុងអំឡុងក្របខ័ណ្ឌពេលវេលាដែលទាមទារ
- សុំរដ្ឋសាវនាការយុត្តិធម៌ ទោះជាអ្នកប្រើដំណើរការឧទ្ធរណ៍របស់ MHP រឺក៏អត់ និងទោះជាអ្នកបានទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ (Notice of Action) ដូចដែលបានពិពណ៌នាពីដំបូងក្នុងសៀវភៅនេះរឺអត់ក៏ដោយ។

តើនៅពេលណាខ្ញុំអាចដាក់ពាក្យសុំរដ្ឋសាវនាការយុត្តិធម៌?

អ្នកអាចដាក់ពាក្យសុំរដ្ឋសាវនាការយុត្តិធម៌បាន:

- ប្រសិនបើ MHPរបស់អ្នក រឺអ្នកផ្តល់សេវាមួយក្នុងចំណោមអ្នកផ្តល់សេវារបស់ MHP សំរេចថាអ្នកមិនមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ក្នុងការទទួលសេវាសុខភាពផ្លូវចិត្តឯកទេសរបស់ Medi-Cal ពីព្រោះថាអ្នកមិនឆ្លើយតបតាមលក្ខណ:សម្បត្តិភាពចាំបាច់ផ្នែកវេជជសាស្រ្ត។ (សូមមើលទំព័រទី 17 ដើម្បីបានពត៌មានបន្ថែមអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្រ្ត)
- ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក គិតថាអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេស និងសុំ MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP មិនយល់ព្រម ហើយនិយាយថា "ទេ" ចំពោះសំណើររបស់អ្នកផ្តល់សេវារបស់អ្នក រឺប្តូរសផ្លូវប្រភេទ រឺភាពញឹកញាប់នៃសេវា។
- ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកបានសុំ MHP នូវការអនុម័តយល់ព្រម ប៉ុន្តែ MHP ត្រូវការពត៌មានបន្ថែមទៀតដើម្បីធ្វើការសំរេចចិត្ត ហើយមិនបានបំពេញការអនុម័តយល់ព្រមអោយបានពេញលេញទាន់ពេលវេលាទេ។
- ប្រសិនបើ MHP មិនផ្តល់សេវាអោយអ្នកអាស្រ័យលើក្របខ័ណ្ឌពេលវេលា ដែល MHP បានរៀបចំឡើង។

- ប្រសិនបើអ្នកមិនគិតថា MHP កំពុងផ្តល់នូវសេវាបានឆាប់រហ័សគ្រប់គ្រាន់ល្មមដើម្បីឆ្លើយតបតាមតំរូវការរបស់អ្នក។
- ប្រសិនបើសារទុក្ខ ឧទ្ធរណ៍ រឺឧទ្ធរណ៍ពន្លឿនរបស់អ្នក មិនត្រូវបានដោះស្រាយទាន់ពេលទេ។
- ប្រសិនបើអ្នក និងអ្នកផ្តល់សេវារបស់អ្នក មិនយល់ព្រមលើសេវាផ្សេងៗដែលអ្នកត្រូវការ

តើខ្ញុំស្នើសុំរដ្ឋសាវនាការយុត្តិធម៌មួយដោយរបៀបណា?

អ្នកអាចស្នើសុំរដ្ឋសាវនាការយុត្តិធម៌ដោយផ្ទាល់ពីក្រសួងសេវាសង្គមរបស់រដ្ឋកាលីហ្វ័រញ៉ា។ អ្នកអាចសុំរដ្ឋសាវនាការយុត្តិធម៌មួយបានដោយសរសេរទៅកាន់:

State Hearing Division
California Department of Social Services
P.O. Box 9424443, Mail Station 19-37
Sacramento, CA 94244-2430

ដើម្បីស្នើសុំរដ្ឋសាវនាការយុត្តិធម៌មួយ អ្នកអាចទូរស័ព្ទផងដែរទៅលេខ (800) 952-5253 ផ្ញើរទូរសារទៅ (916) 229-4110 រឺសរសេរទៅកាន់ក្រសួងសេវាសង្គម/ ផ្នែករដ្ឋសាវនាការតាម: P.O. Box 944243, Mail Station 19-37, Sacramento, CA 94244-2430។

តើមានកាលបរិច្ឆេទផុតកំណត់សំរាប់ការដាក់ពាក្យសុំរដ្ឋសាវនាការដែររឺទេ?

ប្រសិនបើអ្នក មិនបានទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ទេ រឺដាក់ពាក្យឧទ្ធរណ៍ទៅ MHP អ្នកអាចដាក់ពាក្យសុំរដ្ឋសាវនាការយុត្តិធម៌មួយបានគ្រប់ពេលវេលា។

ប្រសិនបើអ្នកទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ ហើយសំរេចថាដាក់ពាក្យសុំសាវនាការយុត្តិធម៌ជាជំនួស រឺដោយបនែថមទៅលើការដាក់ពាក្យសុំឧទ្ធរណ៍ទៅ MHP អ្នកអាចដាក់ពាក្យសុំសាវនាការយុត្តិធម៌ក្នុងអំឡុង 90 ថ្ងៃ ចាប់ពីកាលបរិច្ឆេទសេចក្តីជូនដំណឹងពីវិធានការណ៍របស់អ្នកត្រូវបានផ្ញើរឺអោយអ្នកដោយផ្ទាល់ដៃមក។

ប្រសិនបើអ្នកប្តឹងឧទ្ធរណ៍ទៅ MHP ហើយចង់ប្តឹងសុំរដ្ឋសាវនាការយុត្តិធម៌ បន្ទាប់ពីអ្នកទទួលការសំរេចចិត្តរបស់ MHP លើការអនុម័តយល់ព្រមរបស់អ្នក អ្នកត្រូវតែដាក់ពាក្យសុំរដ្ឋសាវនាការយុត្តិធម៌ក្នុងអំឡុង 90 ថ្ងៃ ចាប់ពីកាលបរិច្ឆេទចុះលើស្រោមសំបុត្រនៃការសំរេចឧទ្ធរណ៍របស់ MHP។

តើខ្ញុំអាចបន្តសេវាទាំងឡាយនៅពេលដែលខ្ញុំកំពុងរង់ចាំការសំរេចនៃរដ្ឋសាវនាការយុត្តិធម៏ដែររឺទេ?

អ្នកអាចបន្តសេវាទាំងឡាយនៅពេលដែលអ្នកកំពុងរង់ចាំរដ្ឋសាវនាការយុត្តិធម៌
ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក
គិតថាសេវាសុខភាពផ្លូវចិត្តឯកទេសដែលអ្នកកំពុងតែទទួលរួចទៅហើយត្រូវការបន្ត ហើយសុំ MHP នូវការអនុម័តយល់ព្រមអោយបន្ត ប៉ុន្តែ MHP មិនយល់ព្រម ហើយនិយាយថា "ទេ" ចំពោះសំណើររបស់អ្នកផ្តល់សេវា រឺប្តូរផ្លាស់ប្រភេទ រឺភាពញឹកញាប់នៃសេវាដែលអ្នក

ផ្តល់សេវាបានស្នើសុំ។ អ្នកនឹងតែងតែទទួលសេចក្តីជូនដំណឹងពី MHP ជានិច្ចនៅពេលដែលប្រការនេះកើតឡើង។ លើសពីនេះទៅទៀត អ្នកនឹងមិនចាំបាច់បង់ថ្លៃសេវាទាំងឡាយដែលផ្តល់នៅពេលរដ្ឋសាវនាការនៅកំពុងរង់ចាំឡើយ។

តើអ្វីដែលខ្ញុំត្រូវធ្វើ ប្រសិនបើខ្ញុំចង់បន្តសេវាទាំងឡាយ នៅពេលដែលខ្ញុំកំពុងរង់ចាំការសំរេចចិត្តនៃរដ្ឋសាវនាការយុត្តិធម៌?

ប្រសិនបើអ្នកចង់អោយសេវាទាំងឡាយនៅបន្តក្នុងអំឡុងដំណើរការរដ្ឋសាវនាការយុត្តិធម៌ អ្នកត្រូវតែស្នើសុំរដ្ឋសាវនាការយុត្តិធម៌ក្នុងអំឡុង 10 ថ្ងៃពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងពីវិធានការណ៍របស់អ្នកត្រូវបានផ្ញើ រឺប្រគល់អោយអ្នកផ្ទាល់ដៃ។

តើដូចម្តេច ប្រសិនបើខ្ញុំរង់ចាំរយៈពេល 90 ថ្ងៃ ដើម្បីទទួលការសំរេចចិត្តលើរដ្ឋសាវនាការយុត្តិធម៌?

អ្នកអាចស្នើសុំរដ្ឋសាវនាការយុត្តិធម៌ដែលពន្លឿន (លឿនជាងធម្មតា) ប្រសិនបើអ្នកគិតថាក្របខ័ណ្ឌពេលវេលាធម្មតារយៈពេល 90-ថ្ងៃ និងបង្កអោយមានបញ្ហាធ្ងន់ធ្ងរចំពោះសុខភាពផ្លូវចិត្តរបស់អ្នក ដែលរួមមានបញ្ហាជាមួយនឹងសមត្ថភាពរបស់អ្នកក្នុងការទទួល រក្សា រឺទទួលឡើងវិញនូវតួនាទីសំខាន់នៃជីវិត។ ក្រសួងសេវាសង្គម ផ្នែករដ្ឋសាវនាការ នឹងពិនិត្យសើររើសំណើររបស់អ្នកសុំនូវរដ្ឋសាវនាការយុត្តិធម៌ពន្លឿន និងសំរេចថាតើវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែររឺទេ។

ប្រសិនបើសំណើរសុំសាវនាការពន្លឿនតរបស់អ្នកត្រូវបានយល់ព្រម សាវនាការមួយនឹងត្រូវបានធ្វើឡើង ហើយសេចក្តីសំរេចចិត្តនៃសាវនាការនឹងត្រូវបានចេញក្នុងអំឡុង 3 ថ្ងៃធ្វើការ ចាប់ពីកាលបរិច្ឆេទដែលសំណើររបស់អ្នកត្រូវបានទទួលដោយផ្នែករដ្ឋសាវនាការ (State Hearings Division)។

ប្រសិនបើអ្នកទទួលសេចក្តីជូនដំណឹងពីវិធានការណ៍ ហើយសំរេចថាត្រូវដាក់ពាក្យបណ្តឹងរដ្ឋសាវនាការយុត្តិធម៌ជំនួសនឹង រឺបន្ថែមទៅលើការប្តឹងឧទ្ធរណ៍ទៅ **MHP** *អ្នកត្រូវតែរដ្ឋសាវនាការយុត្តិធម៌ក្នុងអំឡុងពេល 90 ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងពីវិធានការណ៍ត្រូវបានផ្ញើ រឺប្រគល់អោយអ្នកដោយផ្ទាល់ដៃ។*

ដំណើរការសាទុក្ខ

ក្នុងឆ្នាំ 2003 ពាក្យខ្លះដែលត្រូវបានប្រើដើម្បីពិពណ៌នាពីដំណើរការនៃMHP ដើម្បីជួយអ្នកដោះស្រាយបញ្ហាជាមួយ MHP បានផ្លាស់ប្តូរហើយ។ សូមចំណាំថារដ្ឋសាវនាការយុត្តិធម៌មិនអាចជួយអ្នកជាមួយនឹងបញ្ហាដែលអ្នកអាចប្តឹងសាទុក្ខនោះឡើយ។ អ្នកអាចស្នើនូវរដ្ឋសាវនាការយុត្តិធម៌នៅពេលណាក៏បានក្នុងអំឡុងដំណើរការសាទុក្ខឡើយ។ ទោះបីយ៉ាងណាក៏ដោយអ្នកអាចស្នើសុំនូវរដ្ឋសាវនាការយុត្តិធម៌ក្នុងពេលដំណើរការឧទ្ធរណ៍។

តើអ្វីជាសាទុក្ខ?

សាទុក្ខគឺជាការសំដែងនូវភាពមិនសប្បាយចិត្តអំពីអ្វីដែលដែលទាក់ទងនឹងសេវាសុខភាពផ្លូវចិត្តឯកទេសរបស់អ្នកដែលមិនមែនជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងឡាយដែលត្រូវបានរ៉ាប់រងដោយដំណើរការរដ្ឋសាវនាការយុត្តិធម៌ (សូមមើលទំព័រទី 23 និង 26 ដើម្បីបានពត៌មានបន្ថែមស្តីពីដំណើរការឧទ្ធរណ៍ និងរដ្ឋសាវនាការយុត្តិធម៌)។

ដំណើរការសាទុក្ខនឹង:

- រាប់បញ្ចូលទាំងនិតិវិធីដែលត្រូវបានយល់យ៉ាងងាយដែលអនុញ្ញាតអោយអ្នក ដាក់ជូនសាទុក្ខរបស់អ្នកដោយផ្ទាល់មាត់ រឺជាលាយល័ក្ខអក្សរ។
- មិនយកទៅប្រឆាំងនឹងអ្នក រឺអ្នកផ្តល់សេវារបស់អ្នកក្នុងលក្ខណៈណាមួយឡើយ។
- អនុញ្ញាតអោយអ្នកអនុញ្ញាតមនុស្សម្នាក់ផ្សេងទៀតដើរតួនាទីក្នុងនាមជារូបអ្នក ដោយរួមមានទាំងអ្នកផ្តល់សេវាផង។ ប្រសិនបើអ្នកអនុញ្ញាតិមនុស្សម្នាក់ទៀតដើរតួនាទីក្នុងនាមជាអ្នក MHP អាចស្នើអោយអ្នកចុះហត្ថលេខាលើពាក្យមួយអនុញ្ញាតអោយ MHP បញ្ចេញពត៌មានទៅមនុស្សម្នាក់នោះ។
- ធានាអោយបានថា បុគ្គលទាំងឡាយដែលធ្វើការសំរេចចិត្តមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើដូច្នោះ ហើយមិនមានពាក់ព័ន្ធនឹងកំរិតពិនិត្យសើរើមុនៗ រឺការធ្វើការសំរេចចិត្តឡើយ។
- បញ្ជាក់ពីតួនាទី និងទំនួលខុសត្រូវរបស់អ្នក MHPរបស់អ្នក និងអ្នកផ្តល់សេវារបស់អ្នក។
- ផ្តល់ដំណោះស្រាយសំរាប់សាទុក្ខនៅក្នុងក្របខ័ណ្ឌពេលវេលាដែលទាមទារ។

តើនៅពេលណាខ្ញុំអាចដាក់ពាក្យប្តឹងសាទុក្ខ?

អ្នកអាចដាក់ពាក្យបណ្តឹងសាទុក្ខទៅ MHP ប្រសិនបើអ្នកមិនសប្បាយចិត្តនឹងសេវាសុខភាពផ្លូវចិត្តឯកទេសដែលអ្នកកំពុងទទួលពី MHP រឺមានការព្រួយបារម្ភទាក់ទិនទៅនឹង MHP។

តើខ្ញុំអាចដាក់ពាក្យបណ្តឹងសាទុក្ខដោយរបៀបណា?

អ្នកអាចទូរស័ព្ទទៅ MHPនៃតំបន់របស់អ្នកតាមលេខទូរស័ព្ទឥតគិតថ្លៃដើម្បីទទួលជំនួយជាមួយនឹងការធ្វើបណ្តឹងសាទុក្ខ។ MHP នឹងផ្តល់នូវស្រោមសំបុត្រដែលមានដាក់អាស័យដ្ឋានរបស់ខ្លួននៅតាមកន្លែងរបស់អ្នកផ្តល់សេវាទាំងអស់សំរាប់អ្នកដើម្បីផ្ញើសាទុក្ខរបស់អ្នកមកវិញ។ សាទុក្ខ អាចត្រូវធ្វើឡើងដោយផ្ទាល់មាត់ រឺជាលាយល័ក្ខអក្សរ។ បណ្តឹងសាទុក្ខផ្ទាល់មាត់ មិនចាំបាច់ដាក់តាមពីក្រោយជាលាយលក្ខអក្សរឡើយ។

ែ

តើខ្ញុំដឹងថាតើ MHP បានទទួលសាទុក្ខរបស់ខ្ញុំរឺអត់ ដោយរបៀបណា?

MHPរបស់អ្នក នឹងអនុញ្ញាតអោយអ្នកដឹងថាខ្លួនបានទទួលសាទុក្ខរបស់អ្នក ដោយផ្ញើរអោយអ្នកនូវការបញ្ជាក់ជាលាយល័ក្ខអក្សរ។

តើនៅពេលទើបសាទុក្ខរបស់ខ្ញុំត្រូវបានដោះស្រាយ?

MHP ត្រូវតែដោះស្រាយសាទុក្ខរបស់អ្នកក្នុងអំឡុង 60 ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលអ្នកបានប្តឹងសាទុក្ខមក។ ក្របខ័ណ្ឌពេលវេលា អាចត្រូវបានពន្យារហួតដល់ 14 ថ្ងៃប្រតិទិន ប្រសិនបើអ្នកស្នើសុំការពន្យា រឺប្រសិនបើ MHP គិតថា មាននូវតំរូវការពត៌មានបន្ថែម ហើយថាការពន្យាស្ថិតក្នុងអត្ថប្រយោជន៍ប្រសើរបំផុតចំពោះអ្នក។

តើខ្ញុំដឹងថាតើ MHP បានធ្វើការសំរេចចិត្តអំពីសាទុក្ខរបស់ខ្ញុំដោយរបៀបណា?

នៅពេលដែលការំរេចចិត្តមួយត្រូវបានធ្វើឡើងទាក់ទិនទៅនឹងសាទុក្ខរបស់អ្នក MHP នឹងជំរាបអ្នក រឺអ្នកតំណាងរបស់អ្នកជាលាយល័ក្ខអក្សរអំពីការសំរេចចិត្ត។ ប្រសិនបើ MHP មិនបានជំរាបជូនអ្នក រឺភាគីដែលទាក់ទិន អំពីការសំរេចចិត្តលើសាទុក្ខទាន់ពេលវេលា នៅពេលនោះ MHP នឹងផ្តល់អោយអ្នកនូវសេចក្តីជូនដំណឹងពីការសំរេចចិត្ត ដែលជំរាបអ្នកអំពីសិទ្ធស្នើសុំរដ្ឋសាវនាការយុត្តិធម៌របស់អ្នក។ MHPរបស់អ្នក នឹងផ្តល់អោយអ្នកនូវសេចក្តីជុនដំណឹងពីវិធានការណ៍នៅថ្ងៃដែលក្របខ័ណ្ឌពេលវេលាដល់ពេលផុតកំណត់។

តើមានកាលផុតកំណត់ក្នុងការដាក់ពាក្យបណ្តឹងសាទុក្ខដែររឺទេ?

អ្នកអាចដាក់ពក្យបណ្តឹងសាទុក្ខនៅគ្រប់ពេលវេលា។

តើនៅពេលណាទើបសាទុក្ខរបស់ខ្ញុំត្រូវបានសំរេច?

MHPត្រូវតែធ្វើការសំរេចចិត្តអំពីសាទុក្ខរបស់អ្នកក្នុងអំឡុង 60 ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលអ្នកបានដាក់បណ្តឹងសាទុក្ខរបស់អ្នក។ ក្របខ័ណ្ឌពេលវេលា អាចត្រូវបានពន្យាត្រឹមរយៈពេលរហួតដល់ 14 ថ្ងៃប្រតិទិន ប្រសិនបើអ្នកស្នើសុំការពន្យា រឺប្រសិនបើ MHP គិតថាមាននូវតំរូតការពត៌មានបន្ថែម ហើយថា ការពន្យាគឺសំរាប់អត្ថប្រយោជន៍របស់អ្នក។

ឧទាហរណ៍នៃពេលដែលការពន្យាអាចជាអត្ថប្រយោជន៍របស់អ្នក គឺនៅពេល MHP គិតថាគេអាចអនុម័តយល់ព្រមនឹងសាទុក្ខរបស់អ្នក ប្រសិនបើ MHP មានពេលវេលាច្រើនបន្តិចដើម្បីទទួលពត៌មានពីអ្នក រឺអ្នកដទៃដែលពាក់ព័ន្ធ។

តើខ្ញុំមានសិទ្ធិអ្វីខ្លះ ?

ក្នុងនាមជាបុគ្គលម្នាក់មានលក្ខណៈសម្បត្តិទទួលសេវាពី Medi-Cal លោកអ្នកមានសិទ្ធិទទួលសេវាសុខភាព ឯកទេសផ្លូវចិត្តដែលចាំបាច់ ជាលក្ខណៈវេជ្ជសាស្ត្រពី MHP ។ ពេលទទួលសេវាទាំងនេះ លោកអ្នកមានសិទ្ធិ :

- ទទួលការព្យាបាលដោយមានការគោរពជាបុគ្គល និងការគោរពលើភាពថ្លៃថ្នូរ ព្រមទាំងលើភាពឯកជន របស់លោកអ្នកផង ។
- ទទួលបានពត៌មានអំពីជំរើសព្យាបាលផ្សេងៗ ព្រមទាំងទទួលការពន្យល់បង្ហាញអំពីជំរើសព្យាបាលទាំងនោះ តាមរបៀបមួយដែលលោកអ្នកអាចយល់បាន ។
- ចូលរួមធ្វើការសំរេចចិត្ត ទាក់ទងនឹងការថែទាំសុខភាពផ្លូវចិត្តរបស់លោកអ្នក រួមទាំងសិទ្ធិបដិសេធការព្យា បាលផងដែរ ។
- រួចផុតពីគ្រប់រូបភាពនៃការដាក់កំហិត រឺការដាក់ឱ្យនៅដាច់ដោយឡែកពីគេ ដែលត្រូវគេប្រើជាមធ្យោបាយ សំរាប់បង្ខិតបង្ខំ ដាក់វិន័យ ធ្វើឱ្យមានផាសុខភាព ផ្តន្ទាទោស រឺសងសឹក ដូចមានចែង នៅក្នុងច្បាប់សហព័ន្ធ ស្តីការប្រើប្រាស់ការដាក់កំហិត និងការដាក់ឱ្យនៅដាច់ដោយឡែកនៅក្នុងសម្បទានានា ដូចជាមន្ទីរពេទ្យ កន្លែងមើលថែទាំជម្ងឺ និងកន្លែងស្នាក់នៅព្យាបាលរោគវិកលចរិក ដែលលោកអ្នកត្រូវស្នាក់នៅមួយរាត្រី ដើម្បីទទួលការព្យាបាលជម្ងឺ ជាដើម ។
- ស្នើសុំ និងទទួលបានច្បាប់ចំលងនៃកំណត់ត្រាសុខភាពរបស់លោកអ្នក និងស្នើសុំធ្វើការកែប្រែ រឺការកែតំរូវ លើកំណត់ត្រាសុខាភាពទាំងនោះ ។
- ទទួលបានពត៌មាន នៅក្នុងកូនសៀវភៅនេះ អំពីសេវាផ្សេងៗ ដែលត្រូវផ្តល់ដោយ MHP កាតព្វកិច្ចដទៃ ទៀតរបស់ MHP ព្រមទាំងសិទ្ធិនានារបស់លោកអ្នក ដូចមានចែងនៅក្នុងឯកសារនេះ ។ លោកអ្នកក៏មាន សិទ្ធិទទួលបានពត៌មាននេះ និងពត៌មានដទៃទៀត ដែលៈភ ត្រូវផ្តល់ជូនលោកអ្នក តាមទំរង់មួយដែល លោកអ្នកងាយយល់ ។ ត្រង់នេះ មានន័យថា MHP ត្រូវរៀបចំពត៌មានជាលាយលក្ខណ៍អក្សរ ជាភាសារ ផ្សេងៗដែល មានអតិថិជនរបស់ MHP នៅក្នុងប្រទេសយ៉ាងតិច 5ភាគរយ រឺ3000 នាក់ រឺ អាចតិចជាង នេះប្រើប្រាស់ ព្រមទាំងផ្តល់សេវាបកប្រែផ្ទាល់មាត់ ជូនអតិថិជនដែលចេះភាសាផ្សេងៗ ដោយឥតគិតថ្លៃ ទៀតផង ។ នេះក៏មានន័យផងដែរថា MHP ត្រូវផ្តល់ជូនសំភារៈផ្សេងៗ ដល់អតិថិជន ដែលមានតំរូវការ ពិសេស ដូចជាអ្នកពិការភ្នែក រឺមើលមិនសូវឃើញ ពិបាកអានអក្សរ ជាដើម ។
- ទទួលបានសេវាសុខភាពឯកទេសផ្លូវចិត្តពី ៈភ ដែលស្របតាមលក្ខខណ្ឌតំរូវការនៃកិច្ចសន្យាជាមួយរដ្ឋ ទៅតាមផ្នែកដែលមានសេវា ការធារ៉ាប់រងសមត្ថភាពនិងសេវាគ្រប់គ្រាន់ ការសំរបសំរួល និងការបន្តការថែ ទាំ ព្រមទាំងវិសាលភាព និងការនុញ្ញាតិ នៃសេវានានា ។ MHP ត្រូវតំរូវអោយមាន"
  - រៀបចំ រឺមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ជាមួយអ្នកផ្តល់សេវាឱ្យបានគ្រប់គ្រាន់ ដើម្បីធានា ឱ្យបុគ្គលដែលមានសិទ្ធិទទួលសេវាពី Medi-Cal ទាំងអស់អាចទទួលសេវាសុខភាពឯកទេស ផ្លូវចិត្តទាន់ពេលវេលា ។

- រ៉ាប់រងផ្តល់សេវាសុខភាពចាំបាច់នៅក្រៅបណ្តាញ ដល់លោកអ្នកឱ្យទាន់ពេលវេលា ប្រសិនបើ MHP គ្មាននិយោជិត រឺជួលអ្នកផ្តល់សេវា ដែលអាចផ្តល់សេវាបាន ។ “អ្នកផ្តល់សេវានៅក្រៅ បណ្តាញ” មានន័យថា អ្នកផ្តល់សេវាដែលមិនមាននៅក្នុងបញ្ជីឈ្មោះអ្នកផ្តល់សេវារបស់ MHP ។ MHP ត្រូវធានាថា លោកអ្នកមិនត្រូវចំណាយអ្វីផ្សេងទៀតទេ សំរាប់ការជួបជាមួយអ្នកផ្តល់ សេវាក្រៅបណ្តាញឡើយ ។
- ធានាថា អ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីផ្តល់សេវាសុខភាពឯកទេសផ្លូវចិត្ត ដែលអ្នកផ្តល់សេវាបានព្រមព្រៀងធានារ៉ាប់រង ។
- ធានាថា សេវាសុភាពឯកទេសផ្លូវចិត្តដែល MHP ធានារ៉ាប់រង មានចំនួន រយៈពេល និងវិសាល ភាពគ្រប់គ្រាន់ ដើម្បីបំពេញតាមតំរូវការរបស់អតិថិជនដែលមានគ្រប់លក្ខណៈរបស់ Medi-Cal ដែល Medi-Cal ត្រូវបំរើ ។ នេះរួមទាំងការធានាថា ប្រព័ន្ធអនុញ្ញាតអោយបង់ថ្លៃសេវា ធ្វើ ឡើងដោយផ្អែកតាមភាពចាំបាច់នៃសុខភាព រឺប្រើប្រាស់ដំណើរការ ដែលធានាអោយមានការ អនុវត្តន៍យ៉ាងត្រឹមត្រូវ នូវលក្ខណៈវិនិច្ឆ័យចាំបាច់ផ្នែកវេជ្ជសាស្ត្រ ។
- ធានាថាអ្នកផ្តល់សេវារបស់ខ្លួន ធ្វើការវាយតំលៃឱ្យបានគ្រប់គ្រាន់លើអតិថិជនដែលអាចទទួល សេវា ហើយត្រូវធ្វើការជាមួយអថិតិជនដែលនឹងទទួលសេវា ដើម្បីរៀបចំផែនការព្យាបាល ដោយ រាប់បញ្ចូលទាំងគោលដៅនៃការព្យាបាល ព្រមទាំងសេវាដែលត្រូវផ្តល់ជូនផងដែរ ។
- រៀបចំត្រៀមសំរាប់យោបល់ទីពីរ ពីអ្នកមានវិជ្ជាជីវៈផ្នែកថែទាំសុខភាព មានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ នៅក្នុងបណ្តាញ MHP រឺនរណាម្នាក់នៅក្រៅបណ្តាញ ដោយពុំយកថ្លៃបន្ថែមពីលោក អ្នកឡើយ ។
- ក្នុងករណីចាំបាច់ សំរបសំរួលសេវាដែលខ្លួនផ្តល់ជូន ជាមួយសេវាដែលកំពុងត្រូវផ្តល់ជូនដល់អតិថិ ជន តាមរយៈគំរោងសុខភាពដែលមានការថែទាំរបស់ Medi-Cal រឺជាមួយអ្នកផ្តល់ការថែទាំ ចំបងរបស់លោកអ្នក ដើម្បីធានាការពារភាពឯកជនជូនអតិថិជនដែលទទួលសេវា ដូចមានបញ្ជាក់ នៅក្នុងច្បាប់សហព័ន្ធ ស្តីអំពីភាពឯជននៃពត៌មានសុខភាព ។
- ផ្តល់លទ្ធភាពទទួលការថែទាំទាន់ពេលវេលា រួមទាំងការរៀបចំឱ្យមានសេវា 24 ម៉ោង ក្នុង ១ថ្ងៃ 7 ថ្ងៃក្នុង១សប្តាហ៍ ក្នុងកពេលចាំបាច់ត្រូវព្យាបាលជម្ងឺវិកលចរិកក្នុងករណីបន្ទាន់ រឺក្នុងស្ថានភាព បន្ទាន់ រឺមានវិបត្តិ ។
- ចូលរួមជាមួយកិច្ចប្រឹងប្រែងរបស់រដ្ឋ ដើម្បីលើកកំពស់ការផ្តល់សេវា ឱ្យស្របតាមសមត្ថភាព វប្បធម៌ ដល់អ្នកចុះឈ្មោះទទួលសេវាទាំងអស់ រាប់បញ្ចូលទាំងអ្នកចេះភាសាអង់គ្លេសតិចតួច និង អ្នកដែលមានប្រវត្តិជាតិព័ន្ធ និងវប្បធម៌ផ្សេងៗគ្នាផងដែរ

MHP របស់លោកអ្នក ត្រូវធានាថា ការព្យាបាលរបស់លោកអ្នកគ្មានផលប៉ះពាល់អាក្រក់ ដែលបណ្តាលមកពី ការប្រើប្រាស់សិទ្ធិរបស់លោកអ្នកឡើយ ។ គំរោងសុខភាពផ្លូវចិត្តរបស់លោកអ្នក

ត្រូវស្របទៅតាមច្បាប់ សហព័ន្ធ និងច្បាប់រដ្ឋកំពុងមានប្រសិទ្ធិភាពអនុវត្តដទៃទៀត (ដូចជា : ផ្នែកទី VI នៃច្បាប់សិទ្ធិរដ្ឋប្បវេណីឆ្នាំ 1964 ដែលបានអនុវត្តតាមបទបញ្ញា 45 CFR ផ្នែកទី80 ច្បាប់ស្តីពីការប្រកាន់អាយុឆ្នាំ 1975 ដែលបានអនុវត្តតាមបទបញ្ញា 45 CFR ផ្នែកទី91 ច្បាប់ស្តីអំពីនីតិសម្បទាឆ្នាំ1973 និងផ្នែកទ II និងទ III នៃច្បាប់ស្តីអំពីជនពិការអាមេកាំង) ព្រមទាំងសិទ្ធិនានាដែលមានចែងនៅក្នុងឯកសារ ។ លោកអ្នកអាចមាន សិទ្ធិបន្ថែមទៀត នៅក្នុងច្បាប់រដ្ឋស្តីអំពីការព្យាបាលសុខភាពផ្លូវចិត្ត ហើយលោកអ្នក អាចទាក់ទងមេធាវីការពារសិទ្ធិអ្នកជម្ងឺក្នុងតំបន់របស់លោកអ្នកបាន ដើម្បីសួរនាំសំណួរនានា (សូមទូរស័ព្ទទៅកាន់នាយកដ្ឋានសុខភាពផ្លូវ ចិត្តក្នុងតំបន់របស់លោកអ្នក ដែលមានឈ្មោះក្នុងសៀវភៅលេខទូរស័ព្ទក្នុងស្រុក និងសួរនាំ ដល់មេធាវីការពារ សិទ្ធិអ្នកជម្ងឺ) ។

អ្វីទៅជាសេចក្តីបង្គាប់ជាមុន ?

លោកអ្នកមានសិទ្ធិទទួលបានសេចក្តីបង្គាប់ជាមុន ។ សេចក្តីបង្គាប់ជាមុន គឺជាការណែនាំជាលាយលក្ខណ៍អក្សរ អំពីការថែទាំសុខភាពរបស់លោកអ្នក ដែលបានទទួលស្គាល់តាមច្បាប់រដ្ឋកាលីហ្វ័រញ៉ា ។ ជាធម្មតា សេចក្តីបង្គាប់ នេះ បញ្ជាក់អំពីរបៀបដែលលោកអ្នកចង់ទទួលសេវា រឺថែងអំពីការសំរេចចិត្តផ្សេងៗ ដែលលោកអ្នកត្រូវធ្វើ ប្រសិនបើ រឺនៅពេលលោកអ្នកមិនអាចបញ្ចេញមតិដោយខ្លួនឯងបាន ។ ជូនកាល លោកអ្នកអាចលឺគេពន្យល់ពី សេចក្តីបង្គាប់ជាមុន ថាជាឯកសារបដិសេធការពារព្យាបាលនៅពេលដឹងថាខ្លួនមិនរស់តទៅទៀតបាន ១លិវិនង៏លលថ វីលិខិតផ្ទេរសិទ្ធិឱ្យអ្នកផ្សេងចាត់ចែងការងារបន្តពេលខ្លួនអសមត្ថភាព ១ដុរាបលេ ជឿរៀថ ាតតៀនយេច ។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ា ឱ្យនិយមន័យសេចក្តីបង្គាប់ជាមុនថាជា ការណែនាំស្តីអំពីការថែទាំសុខភាពដោយផ្ទាល់ មាត់ រឺជាលាយលក្ខណ៍អក្សរចំពោះបុគ្គល រឺជាការផ្ទេរសិទ្ធិ (ឯកសារជាលាយលក្ខណ៍អក្សរផ្តល់សិទ្ធិឱ្យនរណា ម្នាក់ ដើម្បីធ្វើការសំរេចចិត្តជំនួសលោកអ្នក) ។ MHPs ទាំងអស់ តំរូវឱ្យមានគោលនយោបាយស្តីពីសេចក្តីបង្គាប់ជាមុននៅនឹងដៃ ។ MHP របស់លោកអ្នក ត្រូវផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរអំពីគោលនយោបាយ សេចក្តីបង្គាប់ជាមុន និងសេចក្តីពណ៌នាអំពីច្បាប់រដ្ឋដែលកំពុងអនុវត្ត ដល់គ្រប់មនុស្សពេញវ័យ ដែលមានសិទ្ធិ ទទួលសេវាពី Medi-Cal រឺបើមនុស្សពេញវ័យនោះ ស្នើសុំពត៌មាននោះ .

សេចក្តីបង្គាប់ជាមុន ត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតឱ្យមនុស្សគ្រប់គ្រងការព្យាបាលរបស់ខ្លួនផ្ទាល់ ជាពិសេស នៅពេលគេមិនអាចផ្តល់ការណែនាំអំពីការថែទាំសុខភាពរបស់ខ្លួនគេផ្ទាល់បាន ។ វាជាឯកសារស្របច្បាប់ ដែល អនុញ្ញាតឱ្យមនុស្សបញ្ជាក់ ជាមុន នូវបំណងប្រាថ្នារបស់ខ្លួន មុនពេលពួកគេមិនអាចធ្វើការសំរេចចិត្តទាក់ទិនឹង ការថែទាំសុខភាពរបស់ខ្លួនបាន ។ សេចក្តីនេះរាប់បញ្ចូលទាំងសិទ្ធិទទួល រឺបដិសេធការព្យាបាល ផ្នែកវេជ្ជសាស្ត្រ ការវះកាត់ រឺការជ្រើសរើសការថែទាំសុខភាពផ្សេងៗទៀតផងដែរ ។ នៅរដ្ឋកាលីហ្វ័រញ៉ា សេចក្តីបង្គាប់ជាមុន មានពីរផ្នែក :

1. ការតែងតាំងភ្នាក់ងារ (បុគ្គលម្នាក់) ឱ្យធ្វើការសំរេចចិត្តអំពីការថែទាំសុខភាពរបស់លោកអ្នក និង
2. ការណែនាំអំពីការថែទាំសុខភាពជាបុគ្គលរបស់លោកអ្នក ។

ប្រសិនបើ លោកអ្នកចង់ធ្វើបណ្តឹងទាក់ទងនឹងលក្ខខណ្ឌនៃសេចក្តីបង្គាប់ជាមុននេះ

លោកអ្នកអាចទាក់ទង នាយកដ្ឋានសេវាសុខភាព ផ្នែកអាជ្ញាប័ណ្ណ និងវិញ្ញាបនប័ត្រក្នុងរដ្ឋកាលីហ្វ័រញ៉ា

តាមរយៈទូរស័ព្ទលេខ **(800)236-9747** រឺផ្ញើរសំបុត្រតាមអាសយដ្ឋាន

California Department of Public Health, Licensing and Certification Division,
PO Box 997434, MS 3202, Sacramento, CA 95899-7434.



ហេតុអ្វីបានជាគិតគូរផ្នែកវប្បធម៌ និងការប្រើប្រាស់ភាសា មានសារៈសំខាន់ ?

ប្រព័ន្ធសុខភាពផ្លូវចិត្តដែលមានសមត្ថភាពផ្នែកវប្បធម៌ ត្រូវមាន ជំនាញ អាកប្បកិរិយា និងគោលនយោបាយ ដែលធានាដោះស្រាយតំរូវការរបស់មនុស្សគ្រប់រូប នៅក្នុងសង្គមដែលមានគុណតំលៃ ជំនឿ និងការតំរង់ទិស ចំរុះ ព្រមទាំងមានពូជសាសន៍ សាសនា និងភាសាខុសៗគ្នា ។ វាគឺជាប្រព័ន្ធមួយ ដែលកែលំអគុណភាពនៃការថែ ទាំសុខភាព សំរាប់ប្រជាជនដ៏ច្រើនខុសៗគ្នា នៃរដ្ឋកាលីហ្វ័រញ៉ា និងផ្តល់ជូនពួកគេនូវការយោគយល់គ្នា និងការគោរពភាពខុសៗគ្នារបស់ពួកគេទៅវិញទៅមក ។

MHP នៅក្នុងតំបន់របស់លោកអ្នក ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ជូនប្រជាជន ដែលខ្លួនបំរើនូវសេវាសុខភាព ឯកទេសផ្លូវចិត្តដែលមានសមត្ថភាពផ្នែកវប្បធម៌ និងផ្នែកភាសា ។ ឧទាហរណ៍ : អ្នកមិនចេះ រឺមិនសូវចេះ និយាយភាសាអង់គ្លេស មានសិទ្ធិទទួលសេវាជាភាសាដែលខ្លួនពេញចិត្ត និងមានសិទ្ធិស្នើសុំអ្នកបកប្រែបាន ។ ប្រសិនបើមានការស្នើសុំ ត្រូវផ្តល់អ្នកបកប្រែទៅឱ្យអ្នកស្នើសុំនោះ ដោយឥតគិតថ្លៃ ។ អ្នកមកស្វែងរកសេវា មិនចាំបាច់នាំអ្នកបកប្រែផ្ទាល់ខ្លួនមកជាមួយទេ ។ ការបកប្រែផ្ទាល់មាត់ អំពីសិទ្ធិ ផលប្រយោជន៍ និងការ ព្យាបាល គឺជាសិទ្ធិដែលលោកអ្នកត្រូវទទួលបាន តាមភាសាដែលលោកអ្នកពេញចិត្ត ។ គេក៏អាចរកពត៌មានបាន នៅក្នុងទំរង់ផ្សេងៗ ប្រសិនបើ នរណាម្នាក់មិនចេះអាន រឺមានបញ្ហាភ្នែកមើលមិនសូវឃើញ ។ ផ្នែកមុខរបស់កូន សៀវភៅនេះ ប្រាប់លោកអ្នកឱ្យដឹងអំពីរបៀបទទួលពត៌មាននេះ ។

MHP នៅក្នុងតំបន់របស់លោកអ្នក តំរូវឱ្យ :

- ផ្តល់សេវាសុខភាពឯកទេសផ្លូវចិត្ត ជាភាសាដែលលោកអ្នកពេញចិត្ត ។
- ផ្តល់ការពិនិត្យ និងព្យាបាលសមស្របតាមវប្បធម៌ ។
- ផ្តល់វិធីសាស្ត្ររួមគ្នាជាក់លាក់មួយផ្នែកតាមវប្បធម៌ផ្សេងៗ ដើម្បីដោះស្រាយតំរូវការតាមវប្បធម៌ ផ្សេងៗ ដែលមាននៅក្នុងតំបន់របស់ ៈភ ដើម្បីបង្កើតឱ្យមានជាប្រព័ន្ធមួយប្រកបដោយ សុវត្ថិភាព និងឆ្លើយតបទៅតាមវប្បធម៌នីមួយៗ ។
- ខិតខំកាត់បន្ថយឧបសគ្គផ្នែកភាសា ។
- ខិតខំដោះស្រាយតំរូវការតាមវប្បធម៌នីមួយៗ របស់បុគ្គលដែលទទួលសេវា ។
- ផ្តល់សេវាប្រកបដោយការគិតគូរអំពីទស្សនៈវប្បធម៌ ចំពោះជម្ងឺ និង រឺសុខភាព ។
- យកចិត្តទុកដាក់ពិចារណាចំពោះការយល់ឃើញរបស់លោកអ្នក ក្នុងការផ្តល់សេវាសុភាពឯកទេស ផ្លូវចិត្តជូនលោកអ្នក ។
- មាននីតិវិធីសំរាប់បង្រៀននិយោជិត និងអ្នកម៉ៅការរបស់ ៈភ អំពីអត្ថន័យនៃការរស់នៅជា មួយជម្ងឺផ្លូវចិត្ត តាមទស្សនៈរបស់អ្នកជម្ងឺផ្លូវចិត្ត ។
- ផ្តល់បញ្ជីសេវាដែលពាក់ព័ន្ធនឹងវប្បធម៌ រឺភាសាដែល ៈភ របស់លោកអ្នកអាចផ្តល់ជូនបាន ។

អ្នកមិនចេះភាសាអង់គ្លេស
វីចេះនិយាយភាសាអង់គ្លេស
តិចតួច
មានសិទ្ធិទទួលសេវា
ជាភាសាដែលខ្លួនពេញចិត្ត
និងមានសិទ្ធិ ស្នើសុំអ្នក
បកប្រែបាន ។

- ផ្តល់បញ្ជីសេវាសុខភាពឯកទេសផ្លូវចិត្ត និងសេវាផ្សេងៗទៀតដែលៈភ អាចផ្តល់ជូនតាមរយៈ ភាសាទីមួយរបស់លោកអ្នក (ដោយមានរៀបចំទៅតាមទីតាំង និងសេវាដែលផ្តល់ជូន) ។
- ផ្តល់សេវាបកប្រែផ្ទាល់មាត់ ដោយឥតគិតថ្លៃ ។ សេវាបកប្រែផ្ទាល់មាត់នេះ ត្រូវអនុវត្តចំពោះអ្នក មិនចេះភាសាអង់គ្លេសទាំងអស់ ។
- ផ្តល់ពតិមានជាលាយលក្ខណ៍អក្សរ ជាភាសាយាន ជាទំរង់ផ្សេងៗ និងតាមរបៀបមួយសមស្រប ដែលគិតគួរដល់តំរូវការពិសេសៗ របស់អ្នកមានបញ្ហាភ្នែកមើលមិនសូវឃើញ វីអ្នកមិនសូវចេះ អានជាដើម ។
- ផ្តល់លេខទូរស័ព្ទដែលឥតគិតថ្លៃ ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍នៅទូទាំងរដ្ឋ ដែលមាន សមត្ថភាពអាចផ្តល់ពតិមានជាភាសារបស់លោកអ្នក អំពីរបៀបទទួលសេវាសុភាពឯកទេសផ្លូវចិត្ត ។ នេះរាប់បញ្ចូលទាំងសេវា ដែលត្រូវការជាចាំបាច់ ដើម្បីព្យាបាលបញ្ហាសុខភាពជាបន្ទាន់របស់លោកអ្នក និងរបៀបប្រើប្រាស់ដំណោះស្រាយបញ្ហារបស់ MHP និងដំណើរការសវនការប្រកបដោយយុត្តិធម៌ របស់រដ្ឋផងដែរ ។
- ពិនិត្យមើលយ៉ាងហោចមួយឆ្នាំម្តង ថាតើប្រជាជននៅក្នុងសហគមន៍ដែលមានវប្បធម៌ ជាតិពន្ធ និង ភាសាចំរុះគ្នា យល់ថា ពួកគេបានទទួលបានផលប្រយោជន៍ដូចគាពីសេវានេះ ដូចប្រជាជនទូទៅផងដែរ ។

តើខ្ញុំត្រូវទទួលសេវាសុខភាពឯកទេសផ្លូវចិត្ត ដោយរបៀបណា ?

ប្រសិនបើលោកអ្នកគិតថា លោកអ្នកត្រូវការសេវាសុភាពឯកទេសផ្លូវចិត្ត លោកអ្នកអាចទទួលសេវានោះ ដោយ សួរនាំ MHP រកសេវាដោយខ្លួនឯងបាន ។ លោកអ្នកអាចទូរស័ព្ទទៅសួរតាមរយៈលេខទូរស័ព្ទឥតគិតថ្លៃរបស់ MHP ដែលមានភ្ជាប់ជូននៅក្នុងផ្នែកខាងមុខនៃកូនសៀវភៅនេះ ។ ផ្នែកខាងមុខនៃកូនសៀវភៅនេះ និងផ្នែក ដែលមានចំណងជើងថា "*សេវា*" នៅលើទំព័រទី 9 នៃកូនសៀវភៅនេះ មានផ្តល់ពត៌មានអំពីសេវាផ្សេងៗ និង អំពីរបៀបស្វែងរកសេវាទាំងនោះ ពី MHP ។

លោកអ្នកក៏អាចត្រូវបញ្ជូនទៅកាន់ MHP របស់លោកអ្នក ដើម្បីទទួលសេវាសុភាពឯកទេសផ្លូវចិត្ត តាមរបៀប ផ្សេងទៀតផងដែរ ។ MHP របស់លោកអ្នក ត្រូវតែរូវឱ្យទទួលយកការបញ្ជូនសុំសេវាសុភាពឯកទេសផ្លូវចិត្ត ពីវេជ្ជបណ្ឌិត និងអ្នកផ្តល់ការថែទាំសុខភាពបឋមផ្សេងៗទៀត ដែលយល់ឃើញថា លោកអ្នកអាចត្រូវការសេវា ទាំងនេះ និងពីគំរោងសុខភាពដែលមានការថែទាំរបស់ Medi-Cal បាន ប្រសិនបើលោកអ្នកជាសមាជិក ។ តាមធម្មតា អ្នកផ្តល់សេវា រឺគំរោងសុភាពដែលមានការថែទាំរបស់ Medi-Cal នឹងត្រូវការការអនុញ្ញាតពី លោកអ្នក រឺការអនុញ្ញាតពីឪពុកម្តាយ រឺអាណាព្យាបាលរបស់កុមារ ដើម្បីធ្វើការបញ្ជូន លើកលែងតែក្នុងករណី ចាំបាច់ប៉ុណ្ណោះ ។ មនុស្ស រឺអង្គភាពដទៃទៀត ដូចជាសាលារៀន នាយកដ្ឋានសុខមាលភាព រឺសេវាសង្គម ក្នុងតំបន់ អ្នកមើលខុសត្រូវ អាណាព្យាបាលរឺសមាជិកគ្រួសារ និងទីភ្នាក់អនុវត្តច្បាប់ជាដើម ក៏អាចធ្វើការបញ្ជូន អ្នកជម្ងឺមកកាន់ MHP បានដែរ ។

សូមមើលសៀវភៅអ្នកផ្តល់សេវា នៅផ្នែកបន្ទាប់ ដើម្បីទទួលពត៌មានបន្ថែមអំពីប្រធានបទនេះ រឺផ្នែកខាងមុខនៃកូនសៀវភៅនេះ ដែលស្តីអំពីពត៌មានក្នុងការផ្តល់ការយល់ព្រម និងការបញ្ជូនជម្ងឺជាក់លាក់ណាមួយរបស MHP *។*

តើខ្ញុំត្រូវស្វែងរកអ្នកផ្តល់សេវាសុភាពឯកទេសផ្លូវចិត្ត ដែលខ្ញុំត្រូវការ តាមរបៀបណា ?

មាន MHPs ខ្លះ តំរូវឱ្យលោកអ្នកមានការយល់ព្រមពី ះភ ក្នុងតំបន់របស់លោកអ្នកជាមុនសិន មុននឹង លោកអ្នកទាក់ទងអ្នកផ្តល់សេវាណាមួយ ។ MHP ខ្លះ នឹងបញ្ជូនលោកអ្នកទៅរកអ្នកផ្តល់សេវា ដែលត្រៀម ចាំជួបលោកអ្នកជាស្រេច ។ ចំណែកឯ MHP ដទៃទៀត អនុញ្ញាតឱ្យលោកអ្នកទាក់ទងអ្នកផ្តល់សេវា ដោយ ផ្ទាល់តែម្តង ។

MHP អាចដាក់កំហិតមួយចំនួន លើការជ្រើសរើសអ្នកផ្តល់សេវារបស់លោកអ្នក ។ MHP ក្នុងតំបន់របស់ លោកអ្នក ត្រូវតែផ្តល់ឱកាសឱ្យលោកអ្នកជ្រើសរើស យ៉ាងហោចអ្នកផ្តល់សេវាពីរនាក់ នៅពេលលោកអ្នក ចាប់ផ្តើមទទួលសេវាជាលើកដំបូង លើកលែងតែ MHP មានហេតុផលសមរម្យ បញ្ជាក់ពីមូលហេតុដែលខ្លួន មិនអាចផ្តល់ជំរើសបាន ឧទាហរណ៍ ដូចជា ករណីមានអ្នកផ្តល់សេវាតែមួយ ដែលអាចផ្តល់សេវាដែលលោកអ្នក ត្រូវការ ។ MHP របស់លោកអ្នក ក៏ត្រូវតែអនុញ្ញាតឱ្យលោកអ្នកផ្លាស់ប្តូរអ្នកផ្តល់សេវាផងដែរ ។ នៅពេល លោកអ្នក សុំប្តូរអ្នកផ្តល់សេវា MHP ត្រូវតែអនុញ្ញាតឱ្យលោកអ្នក ជ្រើសរើសយ៉ាងហោចអ្នកផ្តល់សេវាពីរនាក់ លើកលែងតែមានហេតុផលសមរម្យ បញ្ជាក់ថា មិនអាចធ្វើដូច្នេះបាន ។

ជូនកាល MHP ត្រូវចុះសន្យាឱ្យអ្នកផ្តល់សេវាចាកចេញពី MHP ដោយខ្លួនឯង រឺតាមការទាមទាររបស់ MHP ។ នៅពេលមានករណីនេះកើតឡើង MHP ត្រូវខិតខំឱ្យអស់ពីសមត្ថភាព

ដើម្បីជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការបញ្ចប់ការងារនៃអ្នកផ្តល់សេវាតាមកិច្ចសន្យារបស់ MHP ក្នុងរយៈពេល15ថ្ងៃ ក្រោយពីបានទទួល រឺ ពីពេលចេញសេចក្តីជូនដំណឹង អំពីការបញ្ចប់ការងារនេះ ដល់បុគ្គលម្នាក់ៗដែលបានកំពុងទទួលសេវាសុខភាព ឯកទេសផ្លូចិត្ត ពីអ្នកផ្តល់សេវា ។

នៅពេលខ្ញុំរកបានអ្នកផ្តល់សេវា តើ MHP អាចប្រាប់អ្នកផ្តល់សេវានោះ អំពីសេវាដែលខ្ញុំត្រូវការបាន រឺទេ ?

លោកអ្នក អ្នកផ្តល់សេវា និង MHP គឺជាអ្នកចូលរួមក្នុងការសំរេចចិត្តអំពីសេវា ដែលលោកអ្នកត្រូវទទួល តាមរយៈ MHP ដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័យវេជ្ជសាស្រ្តចាំបាច់ និងបញ្ជីសេវា ដែលស្ថិតក្រោមការធានា រ៉ាប់រង (សូមមើលទំព័រទី 17 និង 10). ជួនកាល MHP នឹងទុកឱ្យលោកអ្នក និងអ្នកផ្តល់សេវា ជាអ្នកធ្វើការ សំរេចចិត្ត ។ ជួនកាលទៀត MHP អាចតំរូវឱ្យអ្នកផ្តល់សេវារបស់លោកអ្នកឱ្យប្រាប់ MHP ឱ្យពិនិត្យមើល ហេតុផលឡើងវិញដែលអ្នកផ្តល់សេវាយល់ឃើញថា លោកអ្នកត្រូវការសេវាណាមួយ មុននឹងផ្តល់ជូនសេវាទាំង នោះ ។ MHP ត្រូវតែប្រើអ្នកមានអាជីពផ្នែកសុខភាពផ្លូវចិត្តមានលក្ខណៈត្រឹមត្រូវ ដើម្បីធ្វើការពិនិត្យឡើង វិញនេះ ។ ដំណើរការនេះ ហៅថា ដំណើរការអនុញ្ញាតការទូទាត់ចំណាយរបស់ MHP . រដ្ឋតំរូវឱ្យ MHP អនុវត្តដំណើរការផ្តល់ការអនុញ្ញាតបង់ថ្លៃសេវា ព្យាបាលដោយយកចិត្តទុកដាក់ខ្ពស់ ការស្តារនីតិសម្បទាពេលថ្ងៃ និងសេវាព្យាបាលអាកប្បកិរិយា (therapeutic behavioral services-(TBS) .

ដំណើរការផ្តល់ការអនុញ្ញាតិរបស់ MHP ត្រូវអនុលោមទៅតាមកាលកំណត់ជាក់លាក់ ។ ចំពោះការផ្តល់ការ អនុញ្ញាតិ ជាស្តង់ដារ MHP ត្រូវធ្វើការសំរេចចិត្ត តាមការស្នើសុំរបស់អ្នកផ្តល់សេវារបស់លោកអ្នក ក្នុងរយៈ ពេល14ថ្ងៃប្រតិទិន ។ ប្រសិនបើ លោកអ្នក រឺអ្នកផ្តល់សេវារបស់លោកអ្នកស្នើសុំ រឺប្រសិនបើ MHP យល់ ឃើញថា វាមានប្រយោជន៍ដល់លោកអ្នកក្នុងការទទួលបានពត៌មានថែមទៀត ពីអ្នកផ្តល់សេវារបស់លោកអ្នក កាលកំណត់នេះ អាចពន្យាចំនួន14ថ្ងៃប្រតិទិនទៀត ។ ឧទាហរណ៍ នៃការពន្យាពេលដែលអាចមានប្រយោជន៍ ដល់លោកអ្នក គឺនៅពេល MHP គិតថា ខ្លួនអាចយល់ព្រមចំពោះការស្នើសុំការអនុញ្ញាត ប្រសិនបើ MHP មានពត៌មានបន្ថែមពីអ្នកផ្តល់សេវារបស់លោកអក ហើយអាចបដិសេធចំពោះសំណើនោះ ដោយពុំចាំបាច់មាន ពត៌មាន ។ ប្រសិនបើ MHP ត្រូវពន្យាពេលកំណត់ MHP នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការពន្យា ពេលនោះ ដល់លោកអ្នក ។

ប្រសិនបើលោកអ្នកមិនទទួលបានបញ្ជីឈ្មោះអ្នកផ្តល់សេវា ដែលមានក្នុងកូនសៀវនេះទេ លោកអ្នកអាចទាក់ទង ៉ះភ ឱ្យផ្ញើរបញ្ជីឈ្មោះនោះ មួយច្បាប់ជូនលោកអ្នក តាមលេខទូរស័ព្ទដែលឥតគិតថ្លៃ នៅផ្នែកខាងមុខនៃ កូនសៀវភៅនេះ ។

ប្រសិនបើ អ្នកផ្តល់សេវា រឺ MHP យល់ឃើញថា ជីវិត សុខភាព រឺសមត្ថភាពរបស់លោកអ្នក ដើម្បីទទួលបាន មាន រឺបានមកវិញនូវមុខងារធម្មតាជាអតិបរមា នឹងស្ថិតក្នុងភាពអន្តរាយក្នុងកាលកំណត់14ថ្ងៃនោះ MHP ត្រូវតែធ្វើការសំរេចចិត្តក្នុងរយៈពេល 3ថ្ងៃធ្វើការងារ ។ ប្រសិនបើលោកអ្នក រឺអ្នកផ្តល់សេវា ស្នើរសុំ រឺ MHP យល់ឃើញមានប្រយោជន៍ ដល់លោកអ្នក ក្នុងការទទួលបានពត៌មានបន្ថែមពីអ្នកផ្តល់សេវារបស់លោកអ្នក ពេល កំណត់នេះ អាចត្រូវពន្យាពេលចំនួន14ថ្ងៃប្រតិទិនបន្ថែមទៀត ។

ប្រសិនបើ MHP មិនបានធ្វើការសំរេចចិត្តក្នុងពេលកំណត់ដែលកំនត់អោយមានតាមស្តង់ដារ
វីតាមការស្នើរសុំ ការអនុញ្ញាតដោយប្រញាប់ប្រញាល់ទេនោះ MHP
ត្រូវតែផ្ញើរការជូនដំណឹងអំពីវិធានការឱ្យលោកអ្នកឱ្យដឹងថា សេវានានា ត្រូវគេបដិសេធ
ហើយលោកអ្នកអាចប្តឹងឧទ្ធរណ៍ ឬសុំឱ្យមានសវនការមួយដ៏យុត្តិធម៌របស់រដ្ឋបាន ។ (សូមមើលទំព័រ
26)

លោកអ្នកអាចសួរនាំ MHP សុំពត៌មានបន្ថែម អំពីដំណើរការផ្តល់សិទ្ធិរបស MHP បាន ។
សូមពិនិត្យមើល ផ្នែកខាងមុខនៃកូនសៀវភៅនេះ ដើម្បីមើលរបៀបស្នើសុំពត៌មាននេះ ។
ប្រសិនបើលោកអ្នកមិនយល់ស្របជា មួយនឹងការសំរេចចិត្តរបស់ ៈភ អំពីដំណើរការផ្តល់ការអនុញ្ញាត
លោកអ្នកអាចប្តឹងឧទ្ធរណ៍ជំទាស់នឹង MHP ឬសុំអោយមានសវនការមួយដ៏យុត្តិធម៌របស់រដ្ឋបាន
(សូមមើលទំព័រ 26) ។

តើ MHP របស់ខ្ញុំ ប្រើអ្នកផ្តល់សេវាណាខ្លះ ?

**MHP ភាគច្រើនប្រើអ្នកផ្តល់សេវាបួនប្រភេទផ្សេងគ្នា ដើម្បីផ្តល់សេវាសុខភាពឯកទេសផ្លូវចិត្ត ។
អ្នកផ្តល់សេវាទាំងនេះ រួមាន :**

អ្នកផ្តល់សេវាជាបុគ្គល : អ្នកមានវិជ្ជាជីវៈខាងសុខភាពផ្លូវចិត្ត ដូចជា វេជ្ជបណ្ឌិត ដែលចុះកិច្ចសន្យា
ជាមួយ MHP ក្នុងតំបន់របស់លោកអ្នក ដើម្បីផ្តល់សេវាសុខភាពឯកទេសផ្លូវចិត្ត នៅតាមការិយាល័យ
និង វីតាម សហគមន៍ ។

អ្នកផ្តល់សេវាជាក្រុម : អ្នកទាំងនេះ គឺជាក្រុមមនុស្សដែលមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្ត
ដែលចុះកិច្ច សន្យា ជាមួយ MHP ក្នុងតំបន់របស់លោកអ្នក
ដើម្បីផ្តល់សេវាសុខភាពឯកទេសផ្លូវចិត្តតាមការិយាល័យ និង វីតាមសហគមន៍ ។

អ្នកផ្តល់សេវាជាអង្គភាព : នេះជាគ្លីនិកសុខភាពចិត្ត ទីភ្នាក់ងារ វីកន្លែងព្យាបាលជម្ងឺ ដែលជាកម្មសិទ្ធិ វី
គ្រប់គ្រងដោយ MHP វីដែលបានចុះកិច្ចសន្យាជាមួយ MHP ក្នុងតំបន់របស់លោកអ្នក ដើម្បីផ្តល់សេវា
នៅតាមគ្លីនិក និង វីតាមសហគមន៍ ។

មន្ទីរពេទ្យដែលផ្តល់សេវា : លោកអ្នកអាចទទួលការថែទាំ វីសេវានៅតាមមន្ទីរពេទ្យបាន ។
នេះអាចជាផ្នែក មួយនៃការព្យាបាលជាលក្ខណៈបន្ទាន់ វីដោយសារ MHP
របស់លោកអ្នកត្រូវផ្តល់សេវាជូនលោកអ្នកតាម របៀបនេះ ។

ប្រសិនបើលោកអ្នកពុំទាន់ស្គាល់ MHP នៅផ្នែកបន្ទាប់នៃសៀវភៅនេះ មានបញ្ជីអ្នកផ្តល់សេវានៅក្នុងតំបន់របស់លោកអ្នក មាននិយាយអំពីទីតាំងនៃអ្នកផ្តល់សេវា សេវាសុខភាពឯកទេសផ្លូវចិត្តដែល ពួកគេផ្តល់ ព្រមទាំងពត៌មានផ្សេងៗទៀត ដើម្បីជួយលោកអ្នកទទួលការថែទាំ ដូចជាពត៌មានអំពីសេវាវប្បធម៌ និងភាសា ជាដើម ដែលអ្នកផ្តល់សេវាទាំងនោះ អាចផ្តល់ជូន ។ ប្រសិនបើលោកអ្នកមានចម្ងល់ទាក់ទងនឹងអ្នក ផ្តល់សេវា សូមទូរស័ព្ទមកកាន់លេខដែលឥតគិតថ្លៃរបស់ MHP ដែលមានភ្ជាប់ជូននៅក្នុងផ្នែកខាងមុខនៃកូនសៀវភៅនេះ ។

សំណោ :

Web Links

កម្មវិធី ម៉េឌី-ខាល រដ្ឋកាលីហ្វ័រញ៉ា (California’s Medi-Cal program)
http://www.dhs.ca.gov/mcs/medi-calhome

ក្រសួងសុខភាពផ្លូវចិត្ត រដ្ឋកាលីហ្វ័រញ៉ា (State of California Department of Mental Health):
http://www.dmh.ca.gov

នាយកដ្ឋានសេវាសុខភាពរដ្ឋកាលីហ្វ័រញ៉ា (State of California Department of Health Services):
http://www.dhs.ca.gov

ធនធានសុខភាពតាមប្រព័ន្ធអ៊ីនធឺណិត (Online Health Resources):
http://www.dhs.ca.gov/home/hsites/

ក្រសួងសុខាភិបាល និងសេវាបំរើមនុស្សនៃសហរដ្ឋអាមេរិច (U.S. Department of Health and Human Services):
http://www.os.dhhs.gov

ក្រសួងសុខាភិបាល និងសេវាបំរើមនុស្ស គ្រប់គ្រងគ្រឿងញៀន និងសេវាសុខភាពផ្លូវចិត្ត (U.S. Department of Health and Human Services, Substance abuse and Mental Health Services Administration) :
http://www.samhsa.gov